ស.អ.ក

CAMBODIA RICE FEDERATION

# សហព័ន្ធស្រូវអង្ករកម្ពុជា

## អាណត្តិទី១




ឧសភា ២០១៤ - ឧសភា ២០១៦

ចេញផ្សាយដោយ

**សហពន្ធ័ស្រូវអង្ករកម្ពុជា**


អាសយដ្ឋាន៖ អគារពាណិជ្ជកម្មសូម៉ា ជាន់ទី ៧
អាគារលេខ ២C ផ្លូវលេខ ១២០ សង្កាត់ ផ្សារថ្មី II
ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
គេហទំព័រ៖ www.crf.org.kh
សារអេឡិចត្រូនិក៖ info@crf.org.kh
ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ៥៥៩ ៨៩៩៩
+៨៥៥ (0) ៨៧ ៥៥៩ ៨៩៩

និពន្ធ និងចងក្រងដោយ

ក្រុមការងារលេខាធិការដ្ឋានសហពន្ធ័ស្រូវអង្ករកម្ពុជា


**ឧបត្ថម្ភធំដោយ**

SOMA GROUP

BÜHLER

EZECOM

**សហការឧបត្ថម្ភដោយ**

ANZ Royal

BAYON CEREAL

EDENBRIDGE ASIA

Excellence Agritech Solution Cambodia

SOFITEL PHNOM PENH PHOKEETHRA

# មាតិកា

ទំព័រទី


- **សារប្រធានសហព័ន្ធ** ០៣
- **រចនាសម្ព័ន្ធ** ០៤
- **សមាសភាពថ្នាក់ដឹកនាំសហព័ន្ធ** ០៥
- **អំពីលេខាធិការដ្ឋាន** ០៦

- សមាសភាពលេខាធិការដ្ឋាន ០៦
- ការងារសម្រេចបានរបស់លេខាធិការដ្ឋាន ០៩
- ផែនការយុទ្ធសាស្ត្រ និងសកម្មភាព ១១

- **សមិទ្ធផលការងាររបស់គណៈកម្មាធិការប្រតិបត្តិ** ១២

i. គណៈកម្មាធិការប្រតិបត្តិជំរុញនិងផ្សព្វផ្សាយទីផ្សារអន្តរជាតិ ១២
ii. គណៈកម្មាធិការប្រតិបត្តិកែទម្រង់ថ្លៃដើម ១៤
iii. គណៈកម្មាធិការប្រតិបត្តិផលិតភាពផលិតកម្មស្រូវ និងការកែច្នៃ ១៨
iv. គណៈកម្មាធិការប្រតិប្រត្តិឥណទានជាមួយធនាគារ ២០
v. គណៈកម្មាធិការប្រតិបត្តិវិន័យ និងក្រមសីលធម៌ ២២

- **សមិទ្ធផលនៃកិច្ចសហប្រតិបត្តិការ** ២៦

- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នថ្នាក់ជាតិ ២៦
- កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ២៨
- កិច្ចសហការ និងការយកចិត្តទុកដាក់ចំពោះសមាជិក ២៩

- **ព្រឹត្តិការណ៍ធំៗដែលសហព័ន្ធស្រូវអង្ករកម្ពុជាបានរៀបចំ** ៣៣
- **ការងារកំពុងតែវិវឌ្ឍ** ៣៦

- គម្រោងកំណត់ទីតាំងភូមិសាស្ត្រ និងណែនាំបច្ចេកវិទ្យាថ្មីៗ ៣៦
- ការបែងចែកការគ្រប់គ្រងតាមតំបន់ធំៗទាំងប្រាំ ( 5 Zones) ៣៧

- **អំពីសមាជិក** ៤០
- **ឧបសម្ព័ន្ធ** ៤២
- **ស្ថិតិនៃរបាយការណ៍នាំចេញអង្ករកម្ពុជា** ៥៤

## សាររបស់ឯកឧត្តម សុខ ពុទ្ធិវុធ ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន អង្គការ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា ដែលបានសហការគាំទ្រដល់សកម្មភាពរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ពិសេសចំពោះសមាជិកសហព័ន្ធដែលបានចូលរួមយ៉ាងសកម្មក្នុងការធ្វើឲ្យសហព័ន្ធសម្រេចបាននូវសមិទ្ធផលផ្សេងៗ និងពង្រឹងបាននូវតួនាទីរបស់សហព័ន្ធក្នុងការចូលរួម។

បន្ទាប់ពីបដិសន្ធិនៅឆ្នាំ២០១៤ មក ក្នុងកំឡុងរយៈពេល២ ឆ្នាំនៃអាណត្តិទី១ នេះ សហព័ន្ធស្រូវអង្ករកម្ពុជាយើង រក្សាបាននូវសាមគ្គីភាពរបស់សមាជិកក្នុងការធ្វើជាតំណាង សំលេងតែមួយគត់នៃវិស័យឯកជនទាក់ទងនឹងវិស័យស្រូវអង្ករ។ យើងបានធ្វើការងារជាច្រើន ក្នុងនោះរួមមាន៖ការរៀបចំស្ថាប័ន ការពង្រឹងសាមគ្គីភាពរបស់សមាជិកអោយជិះទូកតែមួយជាមួយគ្នាហើយដំណោះស្រាយដូចបញ្ហាប្រឈមនានា និងពង្រីកនិងពង្រឹងការសហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋ វិស័យឯកជននិងដៃគូអភិវឌ្ឍន៍នានា។

សំរាប់ការរៀបចំស្ថាប័នយើងបានរៀបចំនូវលេខាធិការដ្ឋានមួយ ដើម្បីធ្វើការងារសម្របសម្រួល និងអនុវត្តនូវផែនការនានា ដែលដាក់ចេញដោយក្រុមប្រឹក្សាភិបាល ឲ្យបានប្រសិទ្ធភាពខ្ពស់ និងមានតម្លាភាព។

ក្នុងរយៈពេល២ ឆ្នាំនេះ ក្រុមប្រឹក្សាភិបាលសហព័ន្ធបានស្វែងយល់ពីបញ្ហាប្រឈមចំបងៗក្នុងវិស័យស្រូវអង្ករ ដូចជា ការជំរុញការប្រើប្រាស់គ្រប់ពូជសុទ្ធ ឃ្លាំង ម៉ាស៊ីន សម្ងួត ទីផ្សារ ទុនបង្វិលសម្រាប់ការប្រមូលទិញស្រូវ ភ្លើងអគ្គិសនីថ្លៃ ការដឹកជញ្ជូន តម្លៃស្រូវជាដើម ។ ល ។ ហើយបានលើកនូវបញ្ហាទាំងនោះ ជាមួយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍និង វិស័យឯកជន ដើម្បីស្វែងរកនូវដំណោះស្រាយ សម្រាប់ជំរុញវិស័យស្រូវអង្ករ។ បើទោះជាបញ្ហាប្រឈមទាំងអស់នោះ មានបញ្ហាខ្លះត្រូវការដោះស្រាយក្នុងរយៈពេលមធ្យមឬវែង ឬត្រូវការពិភាក្សាបន្ថែមទៀតជាមួយភាគីពាក់ព័ន្ធក៏ដោយ សហព័ន្ធយើងបានខិតខំក្នុងការធ្វើការដោះស្រាយបញ្ហាប្រឈមរបស់វិស័យស្រូវអង្ករ ហើយបានទទួលនូវលទ្ធផលមួយចំនួនជាវិជ្ជមាន ដូចជា ការបន្ធូរបន្ថយតម្លៃភ្លើងអគ្គិសនីមកត្រឹម១៦សេនក្នុងមួយគីឡូវ៉ាត់ម៉ោង ការបញ្ចុះតម្លៃលើកដាក់នៅកំពង់ផែនិងកម្រៃកុងទីន័រ ការលើកពន្ធលើតម្លៃបន្ថែម ជាដើម ។ល។

ជាមួយគ្នានេះ យើងក៏បានសិក្សាផងដែរនូវគំរូផ្សេងៗនៃការធ្វើកសិកម្មតាមកិច្ចសន្យា ហើយកំពុងរៀបចំនូវប្រព័ន្ធមួយក្នុងការសម្របសម្រួលដើម្បីឲ្យការអនុវត្តការធ្វើកិច្ចសន្យាកសិកម្មកាន់តែសន្ទុះខ្លាំងជាងមុន និងទទួលបានជោគជ័យ សំដៅពង្រឹងការទុកចិត្តគ្នា និងជួយលើកនូវតម្លៃស្រូវនិងទីផ្សារសម្រាប់កសិករ ក៏ដូចជាបង្កនូវភាពងាយស្រួលក្នុងការប្រមូលទិញស្រូវរបស់រោងម៉ាស៊ីន តាមតម្រូវការអង្ករនៅក្នុងទីផ្សារ។ ក្នុងការពង្រីកទីផ្សារអង្ករកម្ពុជានៅទីផ្សារអន្តរជាតិ សហព័ន្ធបានធ្វើការយ៉ាងសកម្មជាមួយក្រសួងពាណិជ្ជកម្ម ក្រសួងមន្ទីរស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដូចជាការផ្គូផ្គងពាណិជ្ជកម្មនៅក្នុងនិងក្រៅប្រទេស ដូចជា សហគមន៍អឺរ៉ុប សហរដ្ឋអាមេរិច ចិន គុយវ៉ែត ។ល។ សំដៅពង្រីកទីផ្សាររបស់កម្ពុជា អោយបានកាន់តែធំបន្ថែមទៀត។
ជាក់ស្តែងនៅឆ្នាំ២០១៤ ការនាំចេញអង្ករមានចំនួនត្រឹមតែ ៣៨ម៉ឺនតោនប៉ុណ្ណោះ ចំនួននេះបានកើនឡើងដល់ ៥៣ម៉ឺនតោននៅឆ្នាំ២០១៥។
ជាមួយនឹងការទទួលជោគជ័យ៣ ឆ្នាំជាប់ៗគ្នារបស់អង្ករកម្ពុជា យើងក៏បានបង្កើតនូវម៉ាកសញ្ញារួមរបស់អង្ករប្រណីតកម្ពុជា ដោយមានការសហការជាមួយដៃគូអភិវឌ្ឍន៍នានា សំដៅការពារឈ្មោះ និងពង្រីកទីផ្សារអង្ករមានគុណភាពប្រណីតរបស់កម្ពុជា។ បច្ចុប្បន្ន យើងកំពុងចុះឈ្មោះម៉ាកអង្ករួមនេះនៅក្រសួងពាណិជ្ជកម្ម ហើយសង្ឃឹមថា ជាមួយម៉ាកសញ្ញា រួមជាមួយបទដ្ឋានគតិយុត្តិនានាដើម្បីការពារម៉ាកសញ្ញានេះ យើងនឹងមានមូលដ្ឋានមួយរឹងមាំ ក្នុងការធ្វើទីផ្សារក៏ដូចជាលើកស្ទួយអង្ករប្រណីតរបស់កម្ពុជានៅលើឆាកអន្តរជាតិកាន់តែមានប្រសិទ្ធភាព។ ជាមួយគ្នានេះ សហព័ន្ធក៏បានធ្វើការជាមួយដៃគូអភិវឌ្ឍន៍នានា ដូចជា IFC AFD USAID GIZ CAVACជាដើម ។ល។ ក្នុងការធ្វើការជាមួយសហគមន៍កសិកម្ម រោងម៉ាស៊ីន និងអ្នកនាំចេញ ដោយគ្រោងនឹងបង្កើតគណៈកម្មាធិការរួមមួយជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីងាយស្រួលក្នុងការពង្រឹងប្រសិទ្ធភាពនៃគម្រោងនីមួយៗ ធ្វើយ៉ាងណាឲ្យចំគោលដៅដែលវិស័យស្រូវអង្ករត្រូវការចាំបាច់។ យើងក៏បានធ្វើជាមួយរាជរដ្ឋាភិបាល ដោយបានធ្វើជំនួបពិភាក្សាជាមួយស្ថាប័នរដ្ឋដែលពាក់ព័ន្ធនានា និងផ្តើមជាប្រចាំជាមួយក្រសួងពាណិជ្ជកម្ម សំដៅដោះស្រាយបញ្ហាដែលសមាជិកយើងបានលើកឡើង។

តាមរយៈវេទិកាស្រូវអង្ករកម្ពុជាលើកទី៥ យើងបានប្រមូលមតិយោបល់ជាច្រើន ពីសមាជិកនិងស្ថាប័នពាក់ព័ន្ធ យើងក៏បានបញ្ចូលនូវព័ត៌មានទាំងនោះក្នុងផែនការយុទ្ធសាស្ត្រនិងសកម្មភាពរយៈពេល៥ ឆ្នាំរបស់សហព័ន្ធ ដែលយើងសង្ឃឹមថាតាមរយៈផែនការនេះយើងអាចធ្វើទំនើបកម្មវិស័យស្រូវអង្ករកម្ពុជា អោយឈានយ៉ាងមួយកំរិតទៀត និងពង្រឹងបានខ្សែចង្វាក់ផលិតកម្មស្រូវអង្ករឲ្យកាន់តែរឹងមាំ។

នៅទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ សមាជិកសហព័ន្ធ និងអ្នកធ្វើការពាក់ព័ន្ធទាំងអស់ក្នុងវិស័យស្រូវអង្ករ សូមទទួលបាននូវជោគជ័យនៅគ្រប់ភារកិច្ចដែលបានខិតខំប្រឹងប្រែង ដើម្បីជំរុញឲ្យវិស័យស្រូវអង្ករកម្ពុជាមាននូវអនាគតដ៏ភ្លឺស្វាង និងឈានមុខគេ៕

សូមអរគុណ!

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦
ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា

**សុខ ពុទ្ធិវុធ**

## រចនាសម្ព័ន្ធសហព័ន្ធស្រូវអង្ករកម្ពុជា




## រចនាសម្ព័ន្ធលេខាធិការដ្ឋាន



# សមាសភាពក្រុមប្រឹក្សាភិបាល



ឯកឧត្តម សុខ ពុទ្ធីវុធ

ប្រធាន

|  |  |  |  |  |  |  |  |
|---|---|---|---|---|---|---|---|
| ឧកញ៉ា គឹម សាវុធ | ឧកញ៉ា ហ៊ុន ឡាក់ | ឧកញ៉ា លឹម ប៊ុនហេង | លោកជំទាវ កែវ ម៉ាលី | ឧកញ៉ា តួ ពុយ | លោក ឈិត ប៊ុនថន | ឧកញ៉ា សុង សារ៉ន | ឧកញ៉ា ចាន់ សុឃាំង |
| អនុប្រធាន | អនុប្រធាន | អនុប្រធាន | សមាជិក | សមាជិក | សមាជិក | សមាជិក | សមាជិក |

|  |  |  |  |  |  |  |  |
|---|---|---|---|---|---|---|---|
| ឧកញ៉ា តែ តាំងប៉ | លោក ហ៊ាង វុត្ថា | លោក សំអាត វាសនា | ឧកញ៉ា វង្ស ប៊ុនហេង | លោក ម៉ូវ ណាម | ឧកញ៉ា ឡាយ ស៊ា | លោក ហេង ផេង | លោក នង វាសនា |
| សមាជិក | សមាជិក | សមាជិក | សមាជិក | សមាជិក | សមាជិក | សមាជិក | សមាជិក |

**សហព័ន្ធស្រូវអង្ករកម្ពុជា** (ស.អ.ក) ជាស្ថាប័នឯកជនដែលមានសំឡេងតែមួយគត់នៃឧស្សាហកម្មស្រូវអង្ករកម្ពុជាដោយបានបង្កើតឡើងតាមរយៈការបោះឆ្នោតនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ដោយសមាជិកស្ថាបនិកចំនួន **២១៣ រូប** តំណាងឲ្យសហព័ន្ធអ្នកនាំចេញអង្ករ សហគមន៍កសិករ សមាគមម្ចាស់រោងម៉ាស៊ីនកិនស្រូវរបស់ក្រុមហ៊ុននាំចេញអង្ករ ក្រុមហ៊ុនដឹកជញ្ជូន ។ល។ ក្នុងរយៈពេលចុងក្រោយនេះ ក៏មានក្រុមហ៊ុនថ្មីៗចូលសមាជិក ស.អ.ក បន្ថែមទៀត ដែលចំនួនសរុបមកដល់បច្ចុប្បន្នមាន៖ **២៤៨រូប** ។

ក្រុមប្រឹក្សាភិបាលមាន **១៧រូប** ត្រូវបោះឆ្នោតដើម្បីធ្វើជាតំណាង ហើយត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចេញអនុក្រឹត្យ លេខ ២២៨អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ ទទួលស្គាល់សហព័ន្ធស្រូវអង្ករកម្ពុជាជាដៃគូតែមួយគត់សម្រាប់ការពិភាក្សាគោលនយោបាយ និងជាអ្នកតំណាងវិស័យស្រូវអង្ករបស់កម្ពុជានៅលើឆាកអន្តរជាតិ ហើយក៏ជាស្ថាប័នមួយដែលត្រូវអភិវឌ្ឍរៀបចំវេទិកាដើម្បីលើកកម្ពស់វិស័យ ស្រូវអង្ករកម្ពុជាទាំងក្នុងស្រុក និងឆាកអន្តរជាតិ៕

# អំពីលេខាធិការដ្ឋាន

ការបង្កើតលេខាធិការដ្ឋានឲ្យចេញជារូបរាងពិតប្រាកដ ជារឿងលំបាកមួយក្នុងចំណោមរឿងរ៉ាវលំបាកៗជាច្រើនក្នុងអាណត្តិទីមួយ ព្រោះអ្វីៗត្រូវចាប់ផ្តើមថ្មីទាំងអស់។ ឆ្លងកាត់ការលំបាកជាច្រើន បច្ចុប្បន្នលេខាធិការដ្ឋានបានលេចរូបរាងឡើង ហើយកំពុងបំពេញការងារយ៉ាងសកម្មដើម្បីក្លាយជាមណ្ឌលព័ត៌មានមួយដ៏ចាំបាច់បំផុតសម្រាប់សមាជិក ទាំងអស់ទាំងក្នុងទីក្រុងនិងនៅតាមបណ្តាខេត្តនានាទំនាក់ទំនងសាកសួរព័ត៌មាន និង ស្នើសុំជួយអន្តរាគមន៍លើបញ្ហាដែលកើតមានចំពោះប្រតិបត្តិការក្នុងអាជីវកម្មរបស់ខ្លួន។

ថ្វីបើមន្ត្រីលេខាធិការដ្ឋាននាពេលបច្ចុប្បន្នមានគ្នាតិចមិនទាន់អាច ឆ្លើយតបទៅលើបញ្ហាទាំងមូលដែលកើតមានក្នុងវិស័យស្រូវអង្ករដើម្បីផ្តល់ដំណោះស្រាយភ្លាមៗ ដល់សមាជិករបស់សហព័ន្ធ ដែលជួបប្រទះបញ្ហាក្នុងការងាររបស់ខ្លួន តែប្រាកដណាស់ពួកគេទាំងអស់សុទ្ធតែមានជំនាញនិងសមត្ថភាពសម្រាប់ប្រសិទ្ធភាពការងារនិងលើកស្ទួយសហព័ន្ធស្រូវអង្ករកម្ពុជាទៅក្នុងថ្ងៃអនាគត។
បុគ្គលិកលេខាធិការដ្ឋានធានាអនុវត្តការងារប្រកបដោយតម្លាភាព សុច្ចរិតភាព ភាពស្មោះត្រង់ ដែលជាគ្រឹះដ៏រឹងមាំសម្រាប់លើកស្ទួយវិស័យស្រូវអង្ករកម្ពុជា ឆ្ពោះទៅរក សាមគ្គីភាពពិតប្រាកដ ភាពជោគជ័យ និង សុខដុមរមនាទៅថ្ងៃអនាគត ស្របនឹងបាវចនាថ្មី ដែលថា «**រួមគ្នាជាកម្លាំង** = Stronger Together»៕

## សមាសភាពលេខាធិការដ្ឋាន



**លោក មូល សារិទ្ធិ**

**កំរិតវប្បធម៌៖** អនុបណ្ឌិតផ្នែកការទូត អនុបណ្ឌិត ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម បរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ចប្រទេសថៃ និង វិញ្ញាបនបត្រមន្ត្រីជាន់ខ្ពស់ផ្នែករដ្ឋបាល។

**ជំនាញ៖** គ្រប់គ្រងពាណិជ្ជកម្ម និង រដ្ឋបាលទូទៅ និងទំនាក់ទំនងការទូត និងរដ្ឋាភិបាល។

**តួនាទី៖** អគ្គលេខាធិការ និងជាមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ និងទំនាក់ទំនងរដ្ឋាភិបាល ។

**ភារៈទទួលខុសត្រូវ៖** ទទួលខុសត្រូវលើដំណើរការក្នុងលេខាធិការដ្ឋានសហព័ន្ធ ជារៀងរាល់ថ្ងៃដើម្បីឆ្លើយតបទៅនឹងផែនការសហព័ន្ធ សម្របសម្រួលដល់សមាជិកលើការងារផ្លូវច្បាប់ និងទំនាក់ទំនងជាមួយរដ្ឋាភិបាល សម្របសម្រួលដល់ក្រុមការងារទី៩ និងចូលរួមជាមួយក្រុមការងារត្រួតពិនិត្យ និងវាយតំលៃការអនុវត្តន៍ឯកសារគោលនយោបាយ ស្តីពី ការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។ល។



**លោក ហ៊ន ឆារ៉ា**

**កំរិតវប្បធម៌៖** បណ្ឌិតផ្នែកសេដ្ឋកិច្ច ពីសាកលវិទ្យាល័យអូសាកា ប្រទេសជប៉ុន។

**ជំនាញ៖** សេដ្ឋកិច្ច។

**តួនាទី៖** ជំនួយការប្រធាន និងជាមន្ត្រីជំនាញផ្នែកហិរញ្ញវត្ថុ

**ភារៈទទួលខុសត្រូវ៖** ជំនួយការរបស់ប្រធានសហព័ន្ធ ការស្រាវជ្រាវសម្របសម្រួលការបណ្តុះបណ្តាលទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និង សម្របសម្រួលគណៈកម្មាធិការដោះស្រាយហិរញ្ញវត្ថុនិងធនាគារ។



**លោក ពៅ ម៉ុនរិទ្ធ**

**កំរិតវប្បធម៌៖** អនុបណ្ឌិតផ្នែកគ្រប់-គ្រងពាណិជ្ជកម្ម ពីប្រទេសអូស្ត្រាលី។

**ជំនាញ៖** គ្រប់គ្រងគំរោង ពាណិជ្ជកម្មទីផ្សារ ការនាំចេញ និងការធ្វើពាណិជ្ជកម្មស្បៀង។

**តួនាទី៖** ប្រធានផ្នែកជម្រុញនិងផ្សព្វផ្សាយទីផ្សារ

**ភារៈទទួលខុសត្រូវ៖** សម្របសម្រួល និងដឹកនាំរៀបចំពិព័ណ៌ក្នុងនិងក្រៅប្រទេស ចងក្រងទិន្នន័យព័ត៌មានទាក់ទងនឹងតម្លៃទីផ្សារ រៀបចំយុទ្ធសាស្ត្រដើម្បីផ្សព្វផ្សាយអង្ករកម្ពុជា និង សម្របសម្រួលគណៈកម្មាធិការប្រតិបត្តិជម្រុញផ្សព្វផ្សាយទីផ្សារអន្តរជាតិ។



**លោក ផង់ ផល្លា**

**កំរិតវប្បធម៌៖** អនុបណ្ឌិតផ្នែកគ្រប់-គ្រងពាណិជ្ជកម្ម

**ជំនាញ៖** គ្រប់ពាណិជ្ជកម្ម គ្រប់គ្រងហិរញ្ញវត្ថុនិងគ្រប់គ្រងកសិពាណិជ្ជកម្ម។

**តួនាទី៖** ប្រធានផ្នែកអភិវឌ្ឍន៍ពូជ និងផលិតផលស្រូវ

**ភារទទួលខុសត្រូវ៖** រៀបចំផែនការសកម្មភាពផ្នែកពូជ និងផលិតកម្មស្រូវ សម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ដើម្បីសហការក្នុងការអនុវិត្តន៍ផែនការសកម្មភាព គាំទ្រកសិករមូលដ្ឋានដើម្បីអភិវឌ្ឍការប្រតិបត្តិរបស់ពួកគេឲ្យមានលក្ខណៈស្តង់ដាពាណិជ្ជកម្ម និង សម្របសម្រួលគណៈកម្មាធិការប្រតិបត្តិផលិតភាពផលិតកម្មស្រូវ និងការកែច្នៃ។



**លោក អ៊ុច ចាន់ថុល**

**កំរិតវប្បធម៌៖** អនុបណ្ឌិតគ្រប់គ្រងការអភិវឌ្ឍ ពីសាកលវិទ្យាល័យន័រតុនប្រទេសកម្ពុជា និងបរិញ្ញាបត្រវិទ្យាសាស្ត្រក្សេត្រសាស្ត្រ ពីសាលាជាតិកសិកម្ម។

**ជំនាញ៖** ក្សេត្រសាស្ត្រ

**តួនាទី៖** ប្រធានផ្នែកគ្រប់គ្រងតំបន់

**ភារទទួលខុសត្រូវ៖** រៀបចំផែនការ និងដឹកនាំការអនុវត្តសកម្មភាពនៅតាមតំបន់នីមួយៗសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម មន្ទីរកសិកម្មខេត្ត និង ស្ថាប័ន នានាដើម្បីគាំទ្រនិងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និង ស្វែងរកកិច្ចសហការល្អពីដៃគូអភិវឌ្ឍន៍ និងស្ថាប័ននានាក្នុងវិស័យស្រូវអង្ករ។



**លោក មុយ ថាន់**

**កំរិតវប្បធម៌៖** អនុបណ្ឌិតផ្នែកការគ្រប់គ្រងចំរុះ សំរាប់ការអភិវឌ្ឍន៍កសិកម្ម និងជនបទ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

**ជំនាញ៖** គ្រប់គ្រងចំរុះសំរាប់ការអភិវឌ្ឍន៍កសិកម្ម

**តួនាទី៖** លេខាធិការនៃក្រុមការងារពិសេសរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ប្រចាំខេត្ត កំពង់ឆ្នាំង

**ភារទទួលខុសត្រូវ៖** រៀបចំកម្មវិធីនិងទិសដៅការងារប្រចាំខែរបស់លេខាអិការដ្ឋានជូនថ្នាក់ដឹកនាំ សិក្សានិងប្រមូលទិន្នន័យអំពីសក្តានុពលភាពនៃផលិតកម្ម តាមដានស្ថានភាពនៃការធ្វើចរាចរ និងព័ត៌មានទីផ្សារ ស្រូវ អង្ករក្នុងខេត្ត និងសហការជាមួយមន្ទីរជំនាញ អាជ្ញាធរមូលដ្ឋាន។



**លោក គុន ខេមរា**

**កំរិតវប្បធម៌៖** បរិញ្ញាបត្រ ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។

**ជំនាញ៖** គ្រប់គ្រងពាណិជ្ជកម្ម

**តួនាទី៖** មន្ត្រីផ្នែកគ្រប់គ្រងធនធានមនុស្ស និងជំនួយការអគ្គលេខាធិការ

**ភារទទួលខុសត្រូវ៖** សម្របសម្រួលផ្នែកបុគ្គលិកទូទៅ ជ្រើសរើសបុគ្គលិកបន្ថែម ទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងសម្របសម្រួលក្រុមការងារទី ៩។



**លោក សាន ឱត្យ**

**កំរិតវប្បធម៌៖** បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

**ជំនាញ៖** រៀបចំដែនដី និងរដ្ឋបាលដីធ្លី

**តួនាទី៖** មន្ត្រីផ្នែកស្រាវជ្រាវ និងរៀបចំដែនទី

**ភារទទួលខុសត្រូវ៖** សម្របសម្រួលប្រព័ន្ធព័ត៌មានភូមិសាស្ត្រ បណ្តុះបណ្តាលជំនាញភូមិសាស្ត្រ ស្រាវជ្រាវ និងកិច្ចការផ្សេងៗទៀតដែលថ្នាក់លើតម្រូវ។



**កញ្ញា សេង ថាវី**

**កំរិតវប្បធម៌៖** បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ នៅសាកលវិទ្យាល័យភូមិភ្នំពេញ

**ជំនាញ៖** គណិតវិទ្យា

**តួនាទី៖** មន្ត្រីផ្នែករដ្ឋបាល និងកិច្ចការទូទៅ

**ភារទទួលខុសត្រូវ៖** សម្របសម្រួលការងាររដ្ឋបាលនៅក្នុងការិយាល័យ រៀបចំកម្មវិធីផ្សេងៗដូចជា៖ កិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ទំនាក់ទំនងជាមួយសមាជិក និងស្ថាប័នពាក់ព័ន្ធ និងកិច្ចការផ្សេងៗទៀតដែលមានភាពចាំបាច់ និងអាទិភាព។



**កញ្ញា ធឿន សុខឡុនា**

**កំរិតវប្បធម៌៖** ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ នៅវិទ្យាស្ថានវ៉ាន់ដាគណនេយ្យ។

**ជំនាញ៖** គណនេយ្យ

**តួនាទី៖** មន្ត្រីផ្នែកគណនេយ្យ

**ភារទទួលខុសត្រូវ៖** គ្រប់គ្រងការកត់ត្រាចំណូលចំណាយទូទៅ ប្រតិបត្តិការហិរញ្ញវត្ថុ និងកិច្ចការផ្សេងៗទៀតដែលថ្នាក់លើតម្រូវ។



**លោកស្រី វណ្ណ សោភ័ណ្ឌ**

**កំរិតវប្បធម៌៖** បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងវិញ្ញាបនបត្រមូលដ្ឋាន ផ្នែកគ្រប់គ្រងព័ត៌មានវិទ្យា ពីវិទ្យាស្ថានស៊ីតិក។

**ជំនាញ៖** នីតិទូទៅ និងគ្រប់គ្រងព័ត៌មានវិទ្យា

**តួនាទី៖** មន្ត្រីផ្នែកទំនាក់ទំនង

**ភារទទួលខុសត្រូវ៖** សម្របសម្រួលផ្នែកទំនាក់ទំនងក្នុង និងក្រៅស្ថាប័ន គ្រប់គ្រងប្រព័ន្ធទំនាក់ទំនងបណ្តាញសង្គមរួមទាំងគេហទំព័រ ប្រមូលចងក្រង ផលិត និងផ្សព្វផ្សាយព័ត៌មានរបស់សហព័ន្ធ តាម Online និង បោះពុម្ពផ្សាយថតរូប ថតវីដេអូឯកសារ ឌីសាញ និងកិច្ចការផ្សេងៗទៀតដែលមានភាពចាំបាច់ និងអាទិភាព។

# ការងារសម្រេចបានរបស់លេខាធិការដ្ឋាន

## សង្ខេបខ្លឹមសារ ការងារសម្រេចបានរបស់លេខាធិការដ្ឋាន

### ១. ការទទួលខុសត្រូវលើដំណើរការប្រចាំថ្ងៃរបស់លេខាធិការដ្ឋាន៖

ដើម្បីធ្វើឲ្យសហព័ន្ធក្លាយជាស្ថាប័នដែលមានប្រសិទ្ធភាព ដែលអាចឆ្លើយតបរាល់សំណើរបស់សមាជិក និងការចែកចាយព័ត៌មានដែលមានតាមរយៈគ្រប់មធ្យោបាយទាំងអស់ ដើម្បីជួយសម្របសម្រួលផ្តល់នូវព័ត៌មានផ្សេងៗ និងការប្រមូលនូវបញ្ហាផ្សេងៗពីសមាជិក និងអ្នកពាក់ព័ន្ធក្នុងវិស័យស្រូវអង្ករកម្ពុជា ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ និងពិភាក្សារកដំណោះស្រាយសមស្របសម្រាប់សមាជិក លេខាធិការដ្ឋានតែងបំពេញការងារប្រចាំថ្ងៃដោយយកចិត្តទុកដាក់តាមរយៈសកម្មភាពដូចខាងក្រោម៖

- ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកសហព័ន្ធទាំងអស់
- ការជួយអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ស្វែងរកនិងផ្តល់នូវឯកសារផ្លូវច្បាប់ ដូចជា ប្រកាស បទបញ្ញត្តិផ្សេងៗរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជូនដល់សមាជិកសហព័ន្ធតាមតម្រូវការ និងទាន់ពេលវេលា
- ជួយសម្របសម្រួលពិគ្រោះយោបល់ និងទំនាក់ទំនងផ្សេងៗទៀតសម្រាប់សមាជិកយើងនៅពេលត្រូវការ ទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗ
- ការងារផ្សេងៗទៀត ដែលថ្នាក់ដឹកនាំ និងសមាជិកទាំងអស់មានកង្វល់ និងស្វែងរកដំណោះស្រាយ

### ២. ការធ្វើបច្ចុប្បន្នភាពរបស់សមាជិក ការសិក្សាថ្លៃដើម និងការគូសផែនទីពីទីតាំងរោងម៉ាស៊ីន និងសហគមន៍កសិកម្មផលិតពូជ៖

- ធ្វើបច្ចុប្បន្នភាពពីសមាជិករបស់សហព័ន្ធ៖ កំលាំងផលិត បរិមាណផលិត លទ្ធភាពឃ្លាំងដែលអាចស្តុកបាន របស់សមាជិករោងម៉ាស៊ីន និងក្រុមហ៊ុននាំចេញ ប្រព័ន្ធទំនាក់ទំនង ដើម្បីងាយស្រួលក្នុងការផ្តល់ព័ត៌មានពីសកម្មភាពផ្សេងៗ ដូចជា អញ្ជើញចូលរួមគ្រប់សកម្មភាពទាំងអស់របស់សហព័ន្ធ ដូចជា ប្រជុំ សិក្ខាសាលា វេទិកាស្រូវអង្ករ ពិធីបុណ្យអង្ករ និងមហាសន្និបាត ជាដើម
- សិក្សាពីបរិមាណតម្រូវការឥណទានរបស់សមាជិក
- សិក្សាពីបរិមាណការប្រើប្រាស់អគ្គិសនី របស់សមាជិក
- សិក្សាពីថ្លៃដើមនៃការផលិតក្នុងខ្សែសង្វាក់ផលិតកម្មទាំងមូល
- ការគូសផែនទីពីទីតាំងរោងម៉ាស៊ីននិងសហគមន៍កសិកម្មផលិតពូជ ដែលយើងសម្រេចបានជិត ១០០% ដើម្បីងាយស្រួលក្នុងការទំនាក់ទំនង ស្វែងរកទីតាំងបានឆាប់រហ័សសម្រាប់សហព័ន្ធ អ្នកទិញ ដៃគូអភិវឌ្ឍនានា ដែលគេចង់បាន
- ទទួលនូវភ្ញៀវជាតិ និងអន្តរជាតិ ពិសេសដៃគូអភិវឌ្ឍន៍ មកជួបពិភាក្សា និងស្រង់យកទិន្នន័យពីវិស័យស្រូវអង្ករកម្ពុជាតាមរយៈសហព័ន្ធ

### ៣. ការងារសម្របសម្រួលគណៈកម្មាធិការប្រតិបត្តិទាំង៥ ដើម្បីលើកយកគម្រោងផែនការមកអនុវត្ត៖

- មន្ត្រីជាន់ខ្ពស់ចំនួន៥ រូបនៃលេខាធិការដ្ឋានបានធ្វើការងារសម្របមស្រួលដល់សម្រាប់គណៈកម្មាធិការនីមួយៗ ដូចជាជួយសម្រួលក្នុងការរៀបចំឯកសារ កំណត់ពេលវេលា ទីកន្លែង អញ្ជើញសមាជិក សម្របសម្រួលកិច្ចប្រជុំ និងធ្វើរបាយការណ៍ ឬកំណត់ហេតុដើម្បីដាក់ជូនថ្នាក់ដឹកនាំ។
- ធ្វើរបាយការណ៍រាល់កិច្ចប្រជុំដាក់ជូនប្រធានគណៈកម្មាធិការនិងសមាជិកពិនិត្យនិងសម្រេចចុះហត្ថលេខា
- បញ្ជូនរបាយការណ៍ទៅជំនួយការប្រធាន ឬ អគ្គលេខាធិការដើម្បីរាយការណ៍ជូនប្រធានសហព័ន្ធដើម្បីជ្រាបជាព័ត៌មាននិងការវិវត្តនៃកិច្ចប្រជុំនីមួយៗ។

### ៤. រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់សហព័ន្ធ និងរៀបចំផែនការថវិកាប្រចាំឆ្នាំ ២០១៦៖

- យោងតាមការចង្អុលបង្ហាញពីថ្នាក់ដឹកនាំនៃក្រុមប្រឹក្សាភិបាលសហព័ន្ធ លេខាធិការដ្ឋាន បានប្រមូលចងក្រងនូវបញ្ហាទាំងឡាយដែលថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាល ក៏ដូចជាសមាជិក និងអ្នកពាក់ព័ន្ធបានលើកឡើង ដោយបានយកទៅពិភាក្សារួមគ្នា ដោយក្នុងនោះមានដៃគូអភិវឌ្ឍន៍ និងក្រសួងស្ថាប័នពាក់ព័ន្ធ

- តាមរយៈការចុះជួបសំណេះសំណាលផ្ទាល់ជាមួយសមាជិក កិច្ចប្រជុំប្រចាំឆ្នាំ និងសិក្ខាសាលា ជាដើម
- ការផ្តល់ជាគំនិតរបស់គណៈកម្មាធិការនីមួយៗ ដែលបានលើកឡើងក្នុងកិច្ចប្រជុំគណៈកម្មាធិការទាំង៥
- លទ្ធផលនៃការសិក្សាពីទីផ្សារ និងតួលេខការនាំចេញកន្លងមករបស់កម្ពុជា
- លទ្ធផលនៃកិច្ចពិភាក្សាឡើងវិញក្នុងវេទិកាស្រូវអង្ករកម្ពុជា និងពិធីបុណ្យអង្ករកម្ពុជា
- ការផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើកវេទិកាស្រូវអង្ករកម្ពុជាលើកទី៥ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ នៅសណ្ឋាគារសុខាភ្នំពេញ។

**លេខាធិការសហព័ន្ធ បានធ្វើការងារជាមួយអ្នកប្រឹក្សាយោបល់ បានធ្វើការចងក្រងចេញនូវសេចក្តីព្រាងចំនួន៖**

១. សេចក្តីព្រាងផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពរយៈពេល **៥ឆ្នាំ** របស់សហព័ន្ធស្រូវអង្ករកម្ពុជា។
*(សូមមើលឧបសម្ព័ន្ធនៅខាងក្រោយ)*

២. ដោយផ្អែកលើការចំណាយជាក់ស្តែង ផែនការថវិកាឆ្នាំ២០១៥ និងផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពនេះ លេខាធិការដ្ឋានបានរៀបចំនូវគម្រោងផែនកាថវិកាសម្រាប់ឆ្នាំ២០១៦។ ផែនការទាំងពីរបានដាក់ឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យនិងសម្រេច បន្ទាប់មកនឹងត្រូវដាក់ឆ្លងមហាសន្និបាតរបស់សហព័ន្ធស្រូវអង្ករកម្ពុជា។

## ៥. សម្របសម្រួលក្រុមការងារទី៩ នៃវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន ផ្នែកស្រូវអង្ករ

ដោយសារក្រុមការងារទី៩ នៃវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន គឺជាក្រុមការងារមួយសំខាន់ ដែលធ្វើការទាក់ទងនឹងគោលនយោបាយវិស័យស្រូវអង្ករ និងដើម្បីងាយស្រួលក្នុងការលើកឡើងក្នុងសំលេងតែមួយនូវបញ្ហាប្រឈមនានាទាក់ទិនវិស័យស្រូវអង្ករទៅកាន់រាជរដ្ឋាភិបាល កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាលនៃសហព័ន្ធស្រូវអង្ករកម្ពុជា បានប្រជុំពិភាក្សា និងសម្រេចជាឯកច្ឆន្ទជ្រើសរើសឯកឧត្តម សុខ ពុទ្ធីវុធ ប្រធានសហព័ន្ធ ដើម្បីស្នើសុំទៅកាន់រាជរដ្ឋាភិបាល តែងតាំងធ្វើជាប្រធានក្រុមកាងារទី៩ នៃវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន ផ្នែកស្រូវអង្ករ (GSF-WG9) ដោយរដ្ឋាភិបាលបានសេចក្តីសម្រេចក្នុងពេលថ្មីៗនេះ។ តាមរយៈក្រុមការងារនេះ យើងនឹងអាចធ្វើការងារបានជាច្រើន ដោយបញ្ចូលនូវផែនការរបស់សហព័ន្ធ និងធ្វើការសម្របសម្រួលជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍនានា ដែលយើងបាននិងកំពុងធ្វើជាមួយគ្នា ដើម្បីឈានដល់ការសម្រេចបាននូវផែនការសម្រាប់វិស័យស្រូវអង្ករកម្ពុជាទាំងមូលនាពេលខាងមុខ។

ចំណុចសំខាន់ៗ ដែលក្រុមការងារទី៩ និងសហព័ន្ធស្រូវអង្ករកម្ពុជា បានលើកឡើងក្នុងជំនួបពិភាក្សា និងកំពុងធ្វើការជាមួយរដ្ឋាភិបាល រួមមាន៖

**ការនាំចូលអង្ករពីប្រទេសជិតខាង ដោយសហព័ន្ធបានស្នើលើចំណុចដូចខាងក្រោម៖**

- ការនាំចូលអង្ករពីប្រទេសវៀតណាម ត្រូវមានម៉ាក និងប្រភពច្បាស់លាស់
- ការពង្រឹងអភិបាលកិច្ចមន្ត្រីនៅច្រកព្រំដែនទាំងអស់
- ការនាំចូលត្រូវពង្រឹងការបង់ពន្ធគ្រប់ចំនួន និងគួរកែសម្រួលតំឡើងអត្រាពន្ធនាំចូល



*រូបភាពពេលប្រជុំនៅ CDC*

**ហិរញ្ញប្បទាន ឃ្លាំងស្តុក ម៉ាស៊ីនសម្ងួត និងការបញ្ជាំស្តុក**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុញ្ញាតឲ្យសហព័ន្ធស្រូវអង្ករកម្ពុជាចូលរួមក្រុមការងារបច្ចេកទេស ដើម្បីធ្វើការសិក្សា និងវាយតំលៃលើសំណើគម្រោងនៅក្នុងក្របខ័ណ្ឌនៃគម្រោងជុំវិញ ក្រោមហិរញ្ញប្បទានសហប្រតិបត្តិការពីសាធារណរដ្ឋប្រជាមានិតចិន។

**តម្លៃអគ្គិសនី ដោយមានជំនួបជាមួយក្រសួងរ៉ែនិងថាមពល**





**និងអគ្គិសនី៖**

- តម្លៃអគ្គិសនី នឹងចុះនៅឆ្នាំ២០១៦
- ការប្រើប្រាស់អគ្គិសនីពេលយប់តំលៃទាបជាងពេលថ្ងៃ ដោយសហព័ន្ធ នឹងបន្តជម្រុញឲ្យចេញជាលទ្ធផល។
- ការតពីអនុស្ថានីយមានតំលៃទាបជាងការភ្ជាប់សេវាករ ប៉ុន្តែម្ចាស់រោងម៉ាស៊ីនត្រូវចំណាយសេវា និងសំភារៈតបណ្តាញដោយខ្លួនឯង។

**ការបង់ពន្ធ**

- ទទួលបានការលើកលែងអាករលើតំលៃបន្ថែម
- បន្តធ្វើការងារលើពន្ធផ្សេងទៀត

**តំលៃការដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធផ្លូវគោក ផ្លូវដែក និងផ្លូវទឹក ប្រភពទឹក និងប្រព័ន្ធធារាស្ត្រ។**

## ៦. ការងារដឹកនាំ និងពង្រឹងលើលេខាធិការដ្ឋាន ស អ ក ៖

### ៦.១. បង្កើនប្រសិទ្ធភាព និងធ្វើអោយមានភាពប្រសើរឡើង៖

- បង្កើតឲ្យមានភាពច្បាស់លាស់នៅលើបែបបទនីតិវិធី ជាពិសេសតួនាទី និងភារកិច្ចទទួលខុសត្រូវ ពេលវេលាម៉ោងធ្វើការ ការតាមដានវត្តមាន ដោយប្រើម៉ាស៊ីនស្កេនម្រាមដៃ និងក្រមសីលធម៌ របស់មន្រ្តីក្នុងលេខាធិការដ្ឋាន។
- មានកិច្ចប្រជុំទៀងទាត់ប្រចាំសប្តាហ៍ ដើម្បីរាយការណ៍ពីការវិវត្តការងារ និងពិភាក្សាដោះស្រាយបញ្ហាណាដែលមិនអាចដោះស្រាយបាន ដើម្បីលើកសំណើជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច ដោយគោរពទៅតាមលក្ខន្តិកៈនិងបទបញ្ញត្តិផ្ទៃក្នុងរបស់សហព័ន្ធស្រូវអង្ករកម្ពុជា។

### ៦.២. បានរៀបចំនូវគោលនយោបាយ និងប្រព័ន្ធហិរញ្ញវត្ថុ ដែលមានស្តង់ដារអន្តរជាតិ៖

- លេខាធិការដ្ឋានបានធ្វើការជាមួយស្ថាប័នឯករាជមួយដើម្បីរៀបចំតំឡើងនូវគោលនយោបាយនិងប្រព័ន្ធហិរញ្ញវត្ថុ ដែលមានស្តង់ដារត្រឹមត្រូវ ហើយអាចបង្ហាញនូវតម្លាភាពសម្រាប់ការប្រើប្រាស់ហិរញ្ញវត្ថុ ដោយមានការបិទបញ្ជីរៀងរាល់ថ្ងៃទី៣០ នៃខែនីមួយៗ ដោយបានទទួលការឯកភាពពីក្រុមប្រឹក្សាភិបាលផងដែរ។
- សហព័ន្ធ បានជួលក្រុមហ៊ុនសវនកម្មឯករាជ្យមួយ ដើម្បីធ្វើការត្រួតពិនិត្យ វាយតំលៃ និងផ្តល់នូវមតិកែលម្អប្រសិនបើមានករណីណាមួយខុសប្រក្រតី ចំពោះការចំណាយផ្សេងៗក្នុងដំណើរសហព័ន្ធ ដែលនឹងបង្ហាញជូនសមាជិកក្នុងមហាសន្និបាត។

### ៦.៣. បានរៀបចំនូវគោលនយោបាយ និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស៖

- ដើម្បីជួយសម្រួលដល់ដំណើរការការងារនៅក្នុងលេខាធិកាដ្ឋានឲ្យមានភាពរលូន មានតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់ សហព័ន្ធ បានពិនិត្យឡើងវិញ និងរៀបចំលើគោលនយោបាយធនធានមនុស្សក្នុងការដឹកនាំនិងគ្រប់គ្រង។
- ដោយបានរៀបចំបែងចែកការងារ និងភារកិច្ច ទៅតាមជំនាញរៀងៗខ្លួន។ ក្នុងនោះ ការលើកទឹកចិត្តចំពោះបុគ្គលិកទូទៅ និងបុគ្គលិកឆ្នើមគឺជាកត្តាសំខាន់ផងដែរដើម្បីបន្តជម្រុញ និងផ្តល់កំលាំងចិត្តចំពោះអ្នកខិតខំធ្វើការងាររហូតដល់សម្រេចបានតាមផែនការ៕

## ផែនការយុទ្ធសាស្ត្រ និងសកម្មភាព

លេខាធិការដ្ឋានទទួលបន្ទុកការងារស្មុលជាច្រើន សម្រាប់ធានានូវប្រតិបត្តិការការងារ ស្របតាមផែនការសកម្មភាព *(សូមអានឧបសម្ព័ន្ធនៅទំព័រ ៤២ ដល់ ៥៣)* ដែលបានអនុម័តនាពេលកន្លងមក ដោយមហាសន្និបាតរបស់សហព័ន្ធស្រូវអង្ករកម្ពុជា និង កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល។ លើសពីនេះ បុគ្គលិកលេខាធិការដ្ឋានគ្រប់រូបសុទ្ធតែបំពេញការងារយ៉ាងសកម្ម មិនត្រឹមតែការងារដែលបានបែងចែកទៅតាមមុខសញ្ញានោះទេ តែថែមទាំងមានភាពបត់បែនតាមតម្រូវការ និង ស្ថានភាពការងាររបស់សហព័ន្ធដែលទើបចាប់ផ្តើមការងារក្នុងរយៈពេលពីរឆ្នាំនេះ៕

# សមិទ្ធផលការងារនៃគណៈកម្មាធិការជំរុញនិងផ្សព្វផ្សាយទីផ្សារអន្តរជាតិ

## (Global Market Promotion ExCo)

គណៈកម្មាធិការជំរុញ និងផ្សព្វផ្សាយទីផ្សារអន្តរជាតិ ត្រូវបង្កើតមុនគេបង្អស់ក្រោមរូបភាពជាក្រុមការងារពិសេសទទួលបន្ទុកការងាររៀបចំ ស្លាកសញ្ញាអង្ករកម្ពុជាតាំងពីថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០១៤។ ក្រោយមក ក្រុមការងារនេះ ត្រូវបានប្រកាសតែងតាំងជាផ្លូវការ ជាគណៈកម្មាធិការជំរុញផ្សព្វផ្សាយទីផ្សារអន្តរជាតិ តាមរយៈលិខិតរបស់សហព័ន្ធស្រូវអង្ករកម្ពុជាលេខ ២៥/១៥ ស.អ.ក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥។


ជំទាវ **ថេរ សុខា** ទទួលលិខិតថ្លែងអំណរគុណ

ក្រោយពីការបង្កើតជាផ្លូវការ គណៈកម្មាធិការនេះ បានជួបប្រជុំជាច្រើនលើកដើម្បីពិភាក្សាវាយតម្លៃ និង កំណត់ទិសដៅដែលខ្លួនត្រូវធ្វើ ក្នុងន័យលើកស្ទួយម៉ាកសញ្ញាអង្ករកម្ពុជា ដើម្បីបង្កើនទំនុកចិត្តកាន់តែខ្លាំងក្លាបន្ថែមទៀត។

តួនាទីចម្បងរបស់គណៈកម្មាធិការនេះ គឺការរៀបចំស្លាកសញ្ញារួម សម្រាប់អង្ករក្រអូបប្រណិតរបស់កម្ពុជា សម្រាប់ឆ្លើយតបទៅនឹងភាពចាំបាច់ក្នុងការកំណត់អត្តសញ្ញាណ និងការធានាគុណភាពខ្ពស់របស់អង្ករប្រណិតកម្ពុជាទៅកាន់ទីផ្សារពិភពលោក ជាពិសេសដើម្បីងាយស្រួលផ្សព្វផ្សាយ និង ឆាប់ទទួលបានភាពទុកចិត្ត និងពេញនិយមពីសំណាក់អ្នកបរិភោគ។ ក្រៅពីតួនាទីនេះ គណៈកម្មាធិការជំរុញផ្សព្វផ្សាយទីផ្សារអន្តរជាតិ ក៏ដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្ររបស់សហព័ន្ធ ទាក់ទិននឹងបញ្ហាទីផ្សារដូចជា ការបង្កើនទំនាក់ទំនងជាមួយស្ថាប័ននៃបណ្តាប្រទេសនាំចូលអង្ករ ការផ្លាស់ប្តូរបទពិសោធន៍ជាមួយស្ថាប័ននៃប្រទេសនាំចេញអង្ករ និងការផ្សព្វផ្សាយពីអង្ករខ្មែរតាមរយៈការចូលរួម និងរៀបចំសន្និសីទ និងពិព័ណ៌ពាណិជ្ជកម្មនានាទាំងក្នុងប្រទេស និងក្រៅប្រទេស។

បច្ចុប្បន្ន គណៈកម្មាធិការមានសមាសភាពចំនួន ១១ រូបដែលអញ្ជើញមកពីក្រុមហ៊ុននានារបស់សមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា ដោយបានស្ម័គ្រចិត្តលះបង់ពេលវេលា ចំណេះដឹង និងបទពិសោធន៍
ក្នុងបុព្វហេតុរួមរបស់វិស័យអង្ករកម្ពុជា។

ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ គណៈកម្មាធិការជំរុញ និងផ្សព្វផ្សាយទីផ្សារអន្តរជាតិសម្រេចបានសមិទ្ធផលការងារតូចធំជាច្រើនដូចជា៖

- ព្រៀងក្រមសីលធម៌ និងវិន័យរបស់សហព័ន្ធស្រូវអង្ករកម្ពុជា
- កែសម្រួល និងស្នើកិច្ចព្រមព្រៀងពាណិជ្ជកម្មបំពេញបន្ថែមសម្រាប់ការផ្គត់ផ្គង់អង្ករទៅប្រទេសចិន និងប្រទេសឥណ្ឌូនេស៊ី ទៅក្រសួងពាណិជ្ជកម្ម
- សហការដឹកនាំសមាជិក ចូលរួមពាណិជ្ជកម្មនៅទីក្រុងក្វាងចូវ ប្រទេសចិន ចូលរួមសន្និសីទស្រូវអង្ករពិភពលោកលើកទី៧នៅប្រទេសម៉ាឡេស៊ី និងពិព័រណ៍ចំណីអាហារអន្តរជាតិនៅប្រទេសថៃ
- សហការដឹកនាំ សមាជិកធ្វើទស្សនកិច្ច និងបេសសកម្មទីផ្សារទៅប្រទេសចិន និងពង្រឹងទំនាក់ទំនងជាមួយសមាគមអ្នកជំនួញអង្ករនៅទីក្រុងហុងកុង
- ជ្រោមជ្រែងរៀបចំវេទិកាស្រូវអង្ករលើកទី៥ និងបុណ្យស្រូវអង្ករលើកទី៣ ទទួលបានជោគជ័យក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ផ្តួចផ្តើមឲ្យមាន ការប្រកួតស្រូវអង្ករល្អបំផុតថ្នាក់ជាតិ លើកដំបូង
- រៀបចំ និងបង្កើតម៉ាកអង្ករជាតិ ហើយចងក្រងឯកសារចុះជាម៉ាកបញ្ជាក់អំពីចរិកលក្ខណៈទំនិញនិងសេវា(Certification Mark)ដំបូងក្នុងព្រះរាជាណាចក្រកម្ពុជា
- ចងក្រងឯកសារ គ្រោងចុះបញ្ជីម៉ាកអង្ករនៅតាមប្រទេសទីផ្សារគោលដៅសំខាន់
- រៀបចំផែនការយុទ្ធសាស្ត្រ ទីផ្សារ និងបញ្ជ្រាបម៉ាកអង្ករទៅកាន់ទីផ្សារគោលដៅដូចជាប្រទេស

**សមាសភាពគណកម្មាធិការទាំង ១១ រូប៖**

| | |
|---|---|
| ១. ជំទាវ **ថៃ សុខា** | សហប្រធាន |
| ២. លោក **នង វាសនា** | សហប្រធាន |
| ៣. លោក **ចាន់ ពេជ្រ** | សមាជិក |
| ៤. លោក **ជា សុខចាន់** | សមាជិក |
| ៥. លោក **ឈីន ឆារ៉ុម** | សមាជិក |
| ៦. លោក **អ៊ឹង ឆេងស៊ា** | សមាជិក |
| ៧. លោក **អេឌី** | សមាជិក |
| ៨. លោក **សេង ធីសែ** | សមាជិក |
| ៩. លោក **សុខ ដេវីដ** | សមាជិក |
| ១០. លោក **តាន់ គន្ធី** | សមាជិក |
| ១១. លោក **ឡាយ អេនឌី** | សមាជិក |

អ្នកសម្របសម្រួល
លោក **ពៅ បុណ្ណារិទ្ធ**

# ការរៀបចំម៉ាកអង្កររួម និងការជំរុញផ្សព្វផ្សាយម៉ាកអង្ករកម្ពុជា

បរិមាណនៃការនាំចេញអង្កររបស់កម្ពុជា កំពុងមានកំណើនគួរឲ្យកត់សំគាល់ទោះបីកម្ពុជាពុំអាចសម្រេចគោលដៅ១លានឆ្នាំ២០១៥ក៏ដោយ។ ជាមួយគ្នានេះដែរ យើងសង្កេតឃើញថា អង្ករកម្ពុជាមិនទាន់ទទួលបានភាពជឿជាក់ និងទទួលស្គាល់ឲ្យបានទូលំទូលាយ ជាពិសេសពីសំណាក់អ្នកបរិភោគផ្ទាល់នៅទីផ្សារអន្តរជាតិប៉ុន្មាននោះទេ ដែលវាផ្ទុយពីភាពល្បីល្បាញរបស់អង្ករកម្ពុជាតាមរយៈការឈ្នះជាអង្ករល្អបំផុតរបស់ពិភពលោក (World's Best Rice Award) បីឆ្នាំជាប់ៗគ្នា ២០១២ ២០១៣ និង ២០១៤។ ម៉្យាងវិញទៀត តំលៃលក់ជាក់ស្តែងរបស់អង្ករ នៅពុំទាន់មានលំនឹង និងល្អសាកសមនឹងគុណភាពពិតរបស់អង្ករកម្ពុជានៅឡើយទេ។

អាស្រ័យហេតុនេះ សហព័ន្ធ ស្រូវអង្ករកម្ពុជា តាមរយៈគណៈកម្មាធិការជំរុញ និង ផ្សព្វផ្សាយ ទីផ្សារ អន្តរជាតិ (GMP ExCo) របស់ខ្លួន ដោយមានការសហការ និងជ្រោមជ្រែងពីក្រសួងស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងពាណិជ្ជកម្ម IFC និងគំរោងSNEC/AFD បានចាប់ផ្តើមរៀបចំបង្កើតម៉ាក អង្ករជាតិមួយសម្រាប់អង្ករក្រអូបប្រណិតរបស់កម្ពុជាតាំងពីចុងឆ្នាំ២០១៤។




ការបង្កើតម៉ាកអង្ករសម្រាប់អង្ករក្រអូបប្រណិតនេះ បានចប់សព្វគ្រប់ហើយ នៅឆ្នាំ២ ០ ១ ៦ នេះ ដោយបច្ចុប្បន្នបានឈានដល់ដំណាក់កាលចុះបញ្ជីកម្មសិទ្ធិបញ្ញាជាតិជាម៉ាកបញ្ជាក់អំពីចរិកលក្ខណៈទំនិញនិងសេវា (Certification Mark) ព្រមទាំងអាចឲ្យសមាជិកដាក់ពាក្យសុំ និងប្រើប្រាស់បានសម្រាប់រដូវកាលច្រូតកាត់ថ្មីនេះហើយ។

ជាមួយគ្នានេះដែរ ផែនការយុទ្ធសាស្រ្តក្នុងការធ្វើទីផ្សារ និងធ្វើឲ្យម៉ាកអង្ករនេះមានការទទួលស្គាល់និងល្បីល្បាញ ក៏ត្រូវបានរៀបចំរួចរាល់ស្របពេលជាមួយគ្នាដែរ ដោយតាមរយៈផែនការនេះ ទីផ្សារបីសំខាន់ៗត្រូវបានជ្រើសរើសគឺប្រទេសបារាំង ប្រទេសចិន និងសហរដ្ឋអាមេរិច។

ដើម្បីឈានទៅដល់ការកំណត់ឈ្មោះ និងនិមិត្តិសញ្ញា ក៏ដូចជាវិធាននៃការគ្រប់គ្រង និងប្រើប្រាស់ម៉ាកអង្ករនេះ គណៈកម្មាធិការជំរុញ និងផ្សព្វផ្សាយទីផ្សារអន្តរជាតិ ក៏ដូចជាសហព័ន្ធស្រូវអង្ករកម្ពុជាបានធ្វើការពិភាក្សាយ៉ាងល្អិតល្អន់ជាមួយសមាជិក និងភាគីពាក់ព័ន្ធសំខាន់ៗ ព្រមទាំងធ្វើការសាកល្បងជាមួយអតិថិជននៅប្រទេសបារាំង ចិន និងសហរដ្ឋអាមេរិច។ ជាលទ្ធផលឈ្មោះ ANGKOR MALIS (អង្គរម្លិះ) និងពាក្យស្លោក "100% Cambodian Jasmine Rice" ព្រមទាំងរូប ពិតជាឆ្លុះបញ្ចាំងពីអត្តសញ្ញាណរបស់កម្ពុជា ភាពខ្លាំងរបស់អង្ករកម្ពុជា និងតម្រូវតាមការចាប់អារម្មណ៍ចង់បានពីសំណាក់ទីផ្សារអន្តរជាតិ។

គួរបញ្ជាក់ផងដែរថា ម៉ាកអង្ករនេះ នឹងក្លាយជានិមិត្តរូបនៃគុណភាពសម្រាប់អង្ករប្រណិតរបស់កម្ពុជាដោយមិនត្រឹមតែផ្តោតលើរសជាតិ និងគុណភាពប៉ុណ្ណោះទេ គឺយកចិត្តទុកដាក់ទាំងពីសុវត្ថិភាពចំណីអាហារ និងការទទួលចំពោះបរិស្ថាន ព្រមទាំងសមធម៌ផងដែរ។ អ្នកប្រើប្រាស់តម្រូវឲ្យមានការបញ្ជាក់ស្តង់ដាH A C C P បំពេញតាមលក្ខខណ្ឌដទៃទៀត និងឆ្លងកាត់ត្រួតពិនិត្យគុណភាពរាល់ពេលផលិត និងអ្នកចេញដោយក្រុមហ៊ុនជំនាញ និងឯករាជ្យ។

លក្ខណៈទំនិញនិងសេវា "ANGKOR MALIS" រួមជាមួយការជំរុញផ្សព្វផ្សាយនាឆ្នាំខាងមុខនេះ យើងសង្ឃឹមថាអង្ករក្រអូបប្រណិតកម្ពុជានឹងទទួលបានការទទួលស្គាល់ ពេញនិយម និងជឿជាក់យ៉ាងទូលំទូលាយ ព្រមទាំងទទួលបានតំលៃខ្ពស់ពីទីផ្សារអន្តរជាតិ។ លើសពីនេះទៅទៀត វានឹងជួយឲ្យអង្ករកម្ពុជាទាំងមូលមានភាពល្បីល្បាញ បង្កើនបរិមាណនាំចេញ និងឈានទៅលើកស្ទួយជីវភាពកសិករខ្មែរ។៚





# សមិទ្ធផលការងារ របស់គណៈកម្មាធិការ ប្រតិបត្តិកែទម្រង់ ថ្លៃដើម

## (Cost Competitiveness ExCo)

គណៈកម្មាធិការ ប្រតិបត្តិថ្លៃដើមជាគណៈកម្មាធិការមួយដែលសកម្មបំផុតក្នុង អាណត្តិដំបូងនៃការរួបរួមគ្នារបស់ប្រតិបត្តិករផ្នែកឯកជនក្នុងវិស័យស្រូវអង្ករ ដោយផ្តោតលើការ សំខាន់បំផុតគឺការសិក្សាតម្លៃថ្លៃដើមផលិតឲ្យកាន់តែមានប្រសិទ្ធភាព និង ការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធនានា ដើម្បីទទួលបានតម្លៃផលិតកាន់តែពិសេស កាន់តែទាប និង កាន់តែបានផលប្រយោជន៍ដល់ប្រតិបត្តិករក្នុងជំនួញស្រូវអង្ករ។


លោកឧកញ៉ា **គឹម សាវុធ** ទទួលពានកិត្តិយស

ក្នុងអាណត្តិរបស់ខ្លួនរយៈពីរឆ្នាំកន្លងមកនេះ គណៈកម្មាធិការនេះ បានបំពេញការងារយ៉ាងសកម្មដោយជួបប្រជុំផ្ទៃក្នុងផងនិងជួបប្រជុំជាមួយស្ថាប័នខាងក្រៅផង ដើម្បីស្វែងរកដំណោះស្រាយសមស្របផ្សេងៗ សម្រាប់ជាប្រយោជន៍ដល់ សមាជិករបស់សហព័ន្ធស្រូវអង្ករដ៏ក្មេងខ្ចីនេះ។

ទាំងប្រធានសហព័ន្ធឯកឧត្តម **សុខ ពុទ្ធីវុធ** ប្រធានគណៈកម្មាធិការសម្របសម្រួលថ្លៃដើមឧកញ៉ា **គឹម សាវុធ** អ្នកសម្របសម្រួលគណៈកម្មាធិការ និង សមាជិកទាំងអស់ របស់លេខាធិការដ្ឋានហាក់បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការធ្វើការងារនេះឲ្យបានដើរទៅមុខជាបន្តបន្ទាប់។

គណៈកម្មាធិការមួយនេះបាន និងកំពុងនាំមកនូវសមិទ្ធផលប្រែប្រួលយ៉ាងច្រើនក្នុងអាជីវកម្មរបស់សមាជិកដែលជាក្រុមហ៊ុននាំចេញ រោងម៉ាស៊ីនកិនស្រូវ និង សហគមន៍កសិកម្មផងដែរនៅកម្ពុជា។

ក្នុងពេលកន្លងមកនេះ គណៈកម្មាធិការតែងតែបង្កើតឲ្យមានជំនួបជាច្រើនលើកក្នុងចំណោមអ្នកពាក់ព័ន្ធជាច្រើន ក្នុងនោះ មានទាំងជំនួបផ្ទៃក្នុងផង និង ជំនួបជាមួយភាគីពាក់ព័ន្ធខាងក្រៅផង។

ជំនួបផ្ទៃក្នុងផ្តោតសំខាន់ជំនួបជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវ អ្នកនាំអង្ករចេញ ក្នុងបំណងឈ្វេងយល់ពីកត្តាសំខាន់ៗក្នុងការកិន ការកែច្នៃ និង ការដឹកជញ្ជូនទំនិញ រីឯជំនួបខាងក្រៅ គឺជំនួបជាមួយសមាគមដឹកជញ្ជូននានា ហើយជាពិសេសបំផុតគឺជំនួបជាមួយស្ថាប័នរបស់រាជរាជរដ្ឋាភិបាល ដូចជាក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណៈការនិងដឹកជញ្ជូន តំណាងកំពង់ផែភ្នំពេញ និង ខេត្តព្រះសីហនុ អគ្គនាយកពន្ធដា អគ្គនាយកគយនិងរដ្ឋាករ នឹង ជំនួបជាមួយអគ្គិសនីកម្ពុជា (EDC) ជាដើម។

### សមាសភាពគណកម្មាធិការទាំង ១១ រូបៈ

១. ឧកញ៉ា **គឹម សាវុធ** ប្រធាន
២. លោក **នង វាសនា** អនុប្រធាន
៣. លោក **យន់ សុវណ្ណ** សមាជិក
៤. លោក **វង្ស ប៊ុនហេង** សមាជិក
៥. លោក **ខួន លី** សមាជិក
៦. លោក **សេង ធីសៃ** សមាជិក
៧. លោក **ពៅ បុណ្ណារិទ្ធ** សមាជិក
៨. លោក **អួន សម្បត្តិ** សមាជិក
៩. លោក **យ៉េង ស៊ីណារ៉ា** សមាជិក
១០. លោក **ឡេក អំរិន** សមាជិក
១១. លោក **ពេជ្រ ដារ៉ុង** សមាជិក

អ្នកសម្របសម្រួល
លោក **ហ៊ីម ខធៀត**

### ការងារលើវិស័យដឹកជញ្ជូនរបស់សហព័ន្ធស្រូវអង្ករកម្ពុជាៈ

សហព័ន្ធស្រូវអង្ករកម្ពុជាបានចាត់វិស័យដឹកជញ្ជូនជាផ្នែកមួយដ៏សំខាន់បំផុតក្នុងការភ្ជាប់ផលិតកម្មក្នុងស្រុកទៅកាន់ទីផ្សារពិភពលោក។ ក្នុងពេលកន្លង គេដឹងគ្រប់គ្នាថា ការដឹកជញ្ជូនកម្ពុជាមានតម្លៃខ្ពស់ និងសំណូមពរយ៉ាងទទូចដល់មានការបញ្ចុះតម្លៃសេវាដឹកជញ្ជូននេះ។

ក្នុងជំនួបជាមួយ ឯកឧត្តម **ត្រាំ អ៊ីវតឹក** ដែលកាលនោះ ជារដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន និង ក្រុមហ៊ុនដឹកជញ្ជូន និង កំពង់ផែស្វយ័តទាំងពីរ សមាជិកទទួលបាននូវការដោះស្រាយបឋមពីសំណាក់ថ្នាក់ដឹកនាំក្រសួង និងស្ថាប័នពាក់ពន្ធ។

តាមរយៈកិច្ចជំនួបពិភាក្សាគ្នា ឯកឧត្តម **លូ គឹមឈន់** ប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានឯកភាពបញ្ចុះតម្លៃសេវាកម្មលើការលើកដាក់ (LOLO) ស្រូវអង្ករកម្ពុជាសម្រាប់នាំចេញអង្ករឲ្យនៅត្រឹម ២៤ដុល្លារសម្រាប់កុងទីន័រ៤០ហ្វីត ទោះបីជាកុងតែន័រទាំងនោះចូលមកតាមច្រកណាក៏ដោយ ដោយគិតចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៥តទៅ។

សូមបញ្ជាក់ថា ការបញ្ចុះតម្លៃនេះ គឺខាងកំពង់ផែក្រុងព្រះសីហនុផ្តល់ជូនតែសមាជិករបស់សហព័ន្ធស្រូវអង្ករប៉ុណ្ណោះ។


រូបភាពពេលប្រជុំនៅកំពុងផែក្រុងព្រះសីហនុ

ក្រោយមកទៀត នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំ ឧកញ៉ា **គឹម សាវុធ** បានលើកឡើងនូវបញ្ហាត្រង់ៗដែលសហព័ន្ធចង់បានគឺស្នើសុំបញ្ចុះថ្លៃការលើកដាក់អង្ករ (LOLO) និង ការបញ្ចុះថ្លៃលើសេវាកម្មមួយចំនួនទៀត និងការសម្រួលដាក់ម៉ាស៊ីន Scanner នៅចុងទីនៃផ្លូវរថភ្លើងដើម្បីសម្រួលដល់ការត្រួតពិនិត្យទំនិញដោយមិនចាំបាច់ដឹកទៅទីតាំងផ្សេង។

## វិស័យថាមពល

ឆ្លើយតបចំពោះសមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលតែងតែលើកឡើងពីកង្វល់ជុំវិញតម្លៃអគ្គិសនីដែលនៅតែខ្ពស់បង្កឲ្យថ្លៃដើមនៃការផលិត និងកែច្នៃអង្ករនៅខ្ពស់ដែរនោះ សហព័ន្ធស្រូវអង្ករកម្ពុជាបានដឹកនាំ ក្រុមការងារធ្វើជំនួបផ្ទាល់ជាមួយ ថ្នាក់ដឹកនាំក្រសួងរ៉ែនិងថាមពល និងអគ្គិសនីកម្ពុជា ក្នុងនោះមានជំនួបជាមួយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួង រ៉ែ និងថាមពល និងឯកឧត្តម **កែវ រតនៈ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា ដើម្បីសុំបញ្ចុះថ្លៃអគ្គិសនីសម្រាប់រោងម៉ាស៊ីនកិនស្រូវ។



លទ្ធផលជាវិជ្ជមានក្រោយជំនួបគឺថ្នាក់ដឹកនាំអគ្គិសនីកម្ពុជា បានសម្រេចឲ្យម្ចាស់រោងម៉ាស៊ីនកិនស្រូវទាំងឡាយណាដែលមានមូលដ្ឋាន ឬទីតាំងរោងម៉ាស៊ីននៅក្បែរអនុស្ថានីយ៍អគ្គិសនីកម្ពុជា អាចតបណ្តាញចេញពីអនុស្ថានីយ៍អគ្គិសនីផ្ទាល់យកទៅប្រើប្រាស់ដើម្បីទទួលបានអត្រាតម្លៃពិសេស ដោយមិនចាំបាច់តបណ្តាញចេញពីសេវាករអគ្គិសនីដែលទទួលបានសិទ្ធចែកចាយអគ្គិសនីនោះទេ។

លើសពីនេះទៅទៀត អគ្គិសនីកម្ពុជា ក៏សម្រេចផ្តល់តម្លៃពិសេសដល់ម្ចាស់រោងម៉ាស៊ីន ដែលប្រើប្រាស់ថាមពលអគ្គិសនីនៅពេលយប់សម្រាប់ប្រតិបត្តិការការងារ។ ទោះបីមានការផ្តល់ជូនយ៉ាងនេះក៏ដោយ ការអនុវត្តហាក់នៅមិនទាន់ទៅមុខរួច ដោយសារតម្លៃពលកម្មនៅពេលយប់ក៏ខ្ពស់ជាងតម្លៃពលកម្មនៅពេលថ្ងៃ ម្យ៉ាងទៀតការកែច្នៃនៅពេលយប់ប្រឈមសត្វល្អិតច្រើន។

## បញ្ហាបង់ពន្ធដារ

បញ្ហាបង់ពន្ធគឺជាក្តីបារម្ភមួយរបស់រោងម៉ាស៊ីនកិនស្រូវនៅកម្ពុជា។ ក្តីបារម្ភមិនមែនកើតចេញពីការបង់ពន្ធនោះទេ តែវាជាការផ្លាស់ប្តូរទម្លាប់នៃការបង់បពន្ធ។ ការដូររបៀបបង់ពន្ធពីការងារដែលខ្លួនធ្លាប់អនុវត្តជាយូរមកហើយ តាមរបបម៉ៅការ ទៅជាការបង់ពន្ធតាមរបបពិត ឬ របបស្វ័យប្រកាសវិញ គឺជារឿងកង្វល់ខ្ពស់សម្រាប់ប្រតិបត្តិការក្នុងវិស័យស្រូវអង្ករ។ តាមរយៈជំនួបលើកដំបូងនោះ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកពន្ធដារ បានស្នើឲ្យសហព័ន្ធស្រូវអង្ករកម្ពុជាសហការ ជាមួយមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីណែនាំពីរបៀបនៃការបង់ពន្ធឲ្យបានច្បាស់លាស់ ដោយមិនត្រូវបង្កការលំបាកណាមួយ ព្រោះតែមិនយល់ពីរបៀបនៃការបង់ពន្ធនោះទេ។


រូបភាពពេលប្រជុំនៅអគ្គនាយកពន្ធដារ

ក្រោយជំនួបជាច្រើនលើក ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ បានធ្វើបទបង្ហាញខ្លីមួយស្តីពី ពីវិធានប្រមូលពន្ធលើវិស័យស្រូវអង្ករ និងអត្ថប្រយោជន៍ដែលរោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញនឹងទទួលបាន

ពេលចុះបញ្ជីបង់ពន្ធតាមរបបពិត។ បន្ថែមពីនេះ ឯកឧត្តម **គង់ វិបុល** បានស្នើនិងលើកទឹកចិត្តដល់សមាជិក សហព័ន្ធស្រូវអង្ករកម្ពុជាទាំងអស់ ចុះបញ្ជីបង់ពន្ធតាមរបបពិតវិញ ព្រោះការចុះបញ្ជីបង់ពន្ធតាមរបបពិតនឹងទទួលបាននូវអត្ថប្រយោជន៍និងការលើកលែងពន្ធជាច្រើន។

ឯកឧត្តម **គង់ វិបុល** ក៏បានសន្យាថា នឹងផ្តល់ជូនការសម្របសម្រួលមួយជាពិសេស សម្រាប់ការចុះបញ្ជីជាបរបពិត ជូនដល់សមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជា។


*រូបភាពប្រជុំនៅអគ្គនាយកដ្ឋានពន្ធដារ*

## VAT ១០% ត្រូវលុបចោល

ក្នុងជំនួបប្រជុំជាលើកទី៣ របស់សហព័ន្ធស្រូវអង្ករកម្ពុជា ជាមួយអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលដឹកនាំដោយឯកឧត្តម **វ៉ាន់ ពុទ្ធិពល** អគ្គនាយករង នៃអគ្គនាយដ្ឋានពន្ធដារ និងលោកឧកញ៉ា **គឹម សាវុធ** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជានិងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងថ្លៃដើម និងសមាជិក ព្រមទាំងលេខាធិការដ្ឋានរបស់សហព័ន្ធ ថ្នាក់ដឹកនាំសហព័ន្ធបានស្នើលើកលែងការជាប់ពន្ធអាករ ១០% ពីលើវិស័យស្រូវអង្ករ។

តាមរយៈជំនួបនោះ ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ បានសម្រេច លើកលែងអាករបន្ថែម (VAT១០% សម្រាប់ថ្លៃអង្ករ។ តាមការអះអាងទំហំនៃ VAT១០% ដែលប្រមូលបានពីការផលិតអង្ករ គឺស្ទើរស្មើ១% ធៀបនឹងអាករផ្សេងៗទៀត។


*រូបភាពអនុស្សាវរីយ៍ក្រោយប្រជុំចប់ នៅអគ្គនាយកពន្ធដារ*

## ការស្នើសុំទិន្នន័យនាំចូល និងនាំចេញស្រូវអង្ករ

នៅព្រឹកថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ក្រុមការងារសហព័ន្ធស្រូវអង្ករកម្ពុជា ដែលដឹកនាំដោយប្រធានសហព័ន្ធ ឯកឧត្តម **សុខ ពុទ្ធិវុធ** បានជួបប្រជុំពិសេសមួយ ជាមួយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំ ប្រធានសហព័ន្ធស្រូវកម្ពុជា បានលើកឡើងសំណើចំនួន៣ចំណុច រួមមាន៖

- ទី១៖ ស្នើសុំឲ្យមានការលើកលែងតម្លៃ Scan កុងទីន័រ នៅចុងទីនៃផ្លូវរថភ្លើង សម្រាប់ទំនិញអង្ករ ដើម្បីកាត់បន្ថយនូវពេលវេលា និងសោហ៊ុយ
- ទី២៖ សុំឲ្យជួយរឹតបន្តឹងការយកពន្ធឲ្យបានត្រឹមត្រូវចំពោះទំនិញអង្ករដែលនាំចូលពីប្រទេសជិតខាង និង
- ទី៣៖ ស្នើសុំទិន្នន័យនៃលំហូរចេញស្រូវ និង ការនាំចូលអង្ករពីប្រទេសជិតខាងឲ្យបានទៀងទាត់។

ដោយទទួលការណែនាំពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **គុណ ញឹម** អគ្គនាយកដ្ឋានគយ និង រដ្ឋាករ បានសន្យាចាត់ចែងណែនាំទៅដល់មន្ត្រីនៅតាមគ្រប់មាត់ច្រកទាំងអស់ ជាពិសេសគឺច្រកបន្ទាយចក្រី និង ច្រកអន្តរជាតិភ្នំដិន ដែលជាច្រកចេញស្រូវ និងនាំចូលអង្ករដ៏សំខាន់នោះផ្តល់នូវការសហការប្រមូលទិន្នន័យនៃលំហូរស្រូវអង្ករនេះ៕

(ខាងក្រោមនេះជាប្រកាសចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

ស្តីពី

ការអនុគ្រោះពន្ធលើតម្លៃបន្ថែម

លើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១.- គោលបំណង

ប្រការ ២.- គោលដៅ

ប្រការ ៣.- វិសាលភាព

ប្រការ ៤.- និយមន័យ

ប្រការ ៥.- ការលើកលែងពន្ធលើតម្លៃបន្ថែម

ប្រការ ៧.- ការអនុវត្ត

# សមិទ្ធផលការងារ របស់គណៈកម្មាធិការ ប្រតិបត្តិផលិតភាព ផលិតកម្មស្រូវ និងការកែច្នៃ

## (Farming & Milling Productivity ExCo)



*លោកឧកញ៉ា វង្ស ម៉ិនហេង ពេលចុះទៅទស្សកិច្ច*

**សមាសភាពគណកម្មាធិការទាំង ១៣ រូបៈ**

១. ឧកញ៉ា **វង្ស ម៉ិនហេង** ប្រធាន
២. លោក **សំ អាតវាសនា** អនុប្រធាន
៣. លោក **ឈុន ធំ** អនុប្រធាន
៤. លោក **ឈិត ម៉ិនថន** អនុប្រធាន
៥. លោក **រីន សីហា** សមាជិក
៦. លោក **វិញ ជាង** សមាជិក
៧. លោក **តាំង ឈុនងី** សមាជិក
៨. លោក **កែវ សុខា** សមាជិក
៩. លោក **យឹម បយ** សមាជិក
១០. លោក **សាក់ ឿន** សមាជិក
១១. លោក **សែ ឡាឡៃន** សមាជិក
១២. លោក **ពៅ ណម** សមាជិក
១៣. លោក **ស៊ូ សាវ៉ន** សមាជិក

អ្នកសម្របសម្រួល
លោក **ផង់ ផល្លា**

ផលិតកម្មនិងការកែច្នៃជាគ្រឹះក្នុងជំនួញស្រូវអង្ករ ដើម្បីធានាថា ពាណិជ្ជកម្មស្រូវអង្ករបាន ឆ្លើយតបនឹងតម្រូវការទីផ្សារអន្តរជាតិ ដែលកម្ពុជាកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការធ្វើពាណិជ្ជកម្មផលិតផលរបស់ខ្លួន។

ក្រោយសហព័ន្ធស្រូវអង្ករកម្ពុជាសម្រេចបង្កើតគណៈកម្មាធិការផលិតភាពផលិតកម្ម និង ការកែច្នៃ គណៈកម្មាធិការមួយនេះ បានជួបប្រជុំយ៉ាងហោចណាស់៦លើកក្នុងអាណត្តិទីមួយនេះ។

ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និង ប្រធានគណៈកម្មាធិការ ដឹកនាំដោយ ឧកញ៉ា **វង្ស ម៉ិនហេង** និង អនុប្រធាន ៣ រូប រួមមាន លោក **សំអាត វាសនា** លោក **ឈុន ធំ** និង លោក **ឈិត ម៉ិនថន** ព្រមទាំងសមាជិកចំនួន១១រូបផ្សេង តែងតែចូលរួមកិច្ចប្រជុំ ដើម្បីស្វែងយល់ពីគន្លឹះនានាសម្រាប់អភិវឌ្ឍន៍ផលិតកម្ម និង ការកែច្នៃ បានជួបប្រជុំលើកទី១ នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥។

គណៈកម្មាធិការផលិតភាពផលិតកម្ម និងការកែច្នៃ ដែលមានសមាជិកចំនួន ១៣ នាក់ ដែលភាគច្រើនមកពីតំណាងរោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនផលិតពូជស្រូវ សហគមន៍កសិករ អ្នកនាំចេញ។

ថ្នាក់ដឹកនាំគណៈកម្មការនេះ បានធ្វើការដោយស្ម័គ្រចិត្ត ចំណាយពេលវេលាផ្ទាល់ខ្លួន ព្រមទាំងធ្វើដំណើរផ្លូវឆ្ងាយមកពីតាមបណ្តាខេត្តនានា ដើម្បីបំរើការងារក្នុងគណៈកម្មាធិការ ដែលសហព័ន្ធ បានផ្តល់សេចក្តីទុកចិត្ត។

គណកម្មាធិការនេះមានភារៈកិច្ចអនុវត្តការងារ ដោយស្ម័គ្រចិត្តលើកិច្ចការនៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងផែនការ សកម្មភាព ដែលបានអនុម័ត ដោយក្រុមប្រឹក្សាភិបាលសហព័ន្ធ។

តួនាទី និងភារកិច្ចរបស់គណកម្មាធិការៈ

ការបង្កើតគណៈកម្មាធិការមួយនេះ មិនមែនជារឿងចៃដន្យនោះទេ តែជាការសម្លឹងមើលអនាគតដ៏វែងឆ្ងាយក្នុងការអភិវឌ្ឍវិស័យស្រូវអង្ករ ប្រកបដោយវិជ្ជាជីវៈ និង ភាពជឿទុកចិត្តបាន ពីសមាជិករបស់សហព័ន្ធ ពីកសិករនៅទូទាំងប្រទេស និង ជាពិសេសគឺដៃគូរអភិវឌ្ឍន៍ ព្រមទាំងស្ថាប័នពាក់ព័ន្ធនានា។ ចំពោះមុខគណៈកម្មាធិការនេះ មានភារកិច្ចមួយចំនួនដូចជាៈ

- ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាល សហព័ន្ធ ធ្វើការរៀបចំយុទ្ធសាស្ត្រ និងអនុវត្ត កំណត់លើប្រភេទពូជស្រូវ ដែលឆ្លើយតបតាមតម្រូវការទីផ្សារ និងយីហោអង្ករកម្ពុជា សំរាប់ជំរុញផ្សព្វផ្សាយដល់ប្រជាកសិករ និងការដាំដុះ។
- កំណត់នូវយុទ្ធសាស្ត្រ ទិសដៅការងារពូជស្រូវ ថ្នាំសំលាប់សត្វល្អិត ជី និង ការងារក្សេត្រសាស្ត្រ។
- ជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ក្នុងការចចារជាមួយក្រសួង ស្ថាប័នជាតិ អន្តរជាតិ ទីភ្នាក់ងារអភិវឌ្ឍន៍នានា ក្នុងការស្វែងរកនូវកិច្ចប្រតិបត្តិការកៀងគររកនូវជំនួយសំរាប់ជួយដល់ ការធ្វើសកម្មភាពការជំរុញ ការផ្សព្វផ្សាយ ការងារកិច្ចសន្យាកសិកម្ម (Contract Farming) ការងារអប់រំ ការចងក្រងសហគមន៍កសិករ និងកម្មវិធីនានា ដែលជួយដល់និរន្តរភាពលើការអនុវត្តការដាំដុះ បច្ចេកទេសដាំដុះរបស់ប្រជាជន ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ និងសន្តិសុខស្បៀង ក្នុងប្រទេស។
- គណៈកម្មាធិការ ត្រូវធ្វើរបាយការណ៍ទៀតទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ចំពោះករណី ការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើរសុំដល់ក្រុមប្រឹក្សាភិបាលតាមរយៈគណៈកម្មាធិការផលិតភាពផលិតកម្ម និងការកែច្នៃឲ្យអនុញ្ញាតសម្រេចជាមុនសិន។
- ក្នុងករណីចាំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និងទីប្រឹក្សាសំរាប់គណៈកម្មាធិការ ទៅក្រុមប្រឹក្សាភិបាលសហព័ន្ធ។

ក្រៅពីនេះ គណៈកម្មាធិការបានរៀបចំជំនួបពិភាក្សាការងារជាមួយក្រសួង និងដៃគូ

ឯកជនដើម្បី ជជែករកការសហការការងារអភិវឌ្ឍវិស័យស្រូវអង្កររួមគ្នា។ ជំនួបនោះមានដូចជា៖ ជំនួបពិភាក្សាការងារជាមួយ ឯកឧត្តម **អ៊ុក រ៉ាប៊ុន** អតីតរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីជាន់ខ្ពស់ផ្នែកជំនាញផ្សេងៗទៀតរបស់ក្រសួង។ គោលបំណង នៃជំនួបនេះគឺ ស្នើរសុំកិច្ចសហការការងាររវាងសហព័ន្ធស្រូវអង្ករកម្ពុជា នឹង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេ សាទទៅលើការងារ បច្ចេកទេសដាំដុះស្រូវ និងពង្រីកផលិតកម្មពូជស្រូវ និងចែករំលែកពត៌មានជា ដើម ។ល។ ក្រោយពីជំនួបនោះ សហព័ន្ធស្រូវអង្ករកម្ពុជា ជំនួបជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ដើម្បីពិភាក្សាទៅលើចំណុច ៣ មានដូចជា៖

ទី១ កំណត់ពូជស្រូវជាអាទិភាព

ទី២ ការចាប់ផ្តើមកិច្ចសហការរវាងស្ថាប័នទាំងពីរ និង

ទី៣ ការចុះជួបជាមួយក្រុមហ៊ុនផលិតស្រូវដែលជាសមាជិកផ្សេងៗទៀត។

## សកម្មភាពការងារកន្លងមក៖

ចាប់តាំងពីបានបង្កើតមក គណកម្មាធិការនេះបានជួបប្រជុំលើកទី១ នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥ ដោយកំណត់នូវប្រធានបទសំខាន់ដូចខាងក្រោម៖

- ការស្វាគមន៍ចំពោះការបង្កើតថ្មីនៃគណៈកម្មាធិការ និងការណែនាំខ្លួនរបស់ សមាជិក
- ធ្វើការពិនិត្យលើផែនការយុទ្ធសាស្ត្ររបស់សហព័ន្ធពាក់ព័ន្ធស្រូវអង្កររយៈពេលវែងដែលពាក់ព័ន្ធទៅលើ ផលិតកម្មស្រូវ និងពូជ ដើម្បីបំបែកផែនការសំខាន់ៗជាអាទិភាពសម្រាប់ដាក់ចេញនូវផែនការប្រតិបត្តិរបស់គណៈកម្មាធិការ។

## លទ្ធផលសម្រេចបាន៖

ក្រោយពីបានជួបប្រជុំជាបន្តបន្ទាប់ គណៈកម្មាធិការបានធ្វើការសម្រេចនូវលទ្ធផលមួយចំនួន ដើម្បីពង្រឹងកិច្ចការរបស់ខ្លួន។

- គណៈកម្មាធិការបានពិភាក្សាសម្រេចលើការកំណត់យកប្រភេទពូជជាអាទិភាពចំនួន សម្រាប់ផ្សព្វផ្សាយ និង ពង្រីកការដាំដុះ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារអន្តរជាតិដូចជា៖

  ១- ស្រូវប្រណិតមានប្រភេទពូជស្រូវ៖ រំដួល ផ្កាម្លិះ សូម៉ាលីវស្សា រំដេង និង រមៀត

  ២- ស្រូវវស្សា មានប្រភេទពូជ៖ នាងម៉ិញ នាងខុន នាងស រាំងជ័យ

  ៣- ស្រូវឡើងទឹក មានប្រភេទពូជ៖ វាសរ និង វាគ្រាប់វែង (សម្រាប់តម្រូវការក្នុងស្រុក)

  ៤- ស្រូវមិនប្រកាន់រដូវ មានប្រភេទពូជ៖ សែនក្រអូប សែនពិដោរ ជលសា អ៊ីអ៊ែ៦៦ អ៊ីអ៊ែ ៨៥ និង នាងក្រអូប

  ក្នុងចំណោមពូជស្រូវទាំងអស់ខាងលើ ពូជស្រូវសែនក្រអូបជាពូជមួយដែលមានការគាំទ្រពីទីផ្សារ និងសមាជិកយើងចង់បាន។ ដោយបច្ចុប្បន្ននេះយើងកំពុងធ្វើការជំរុញជាមួយភាគីដែលពាក់ព័ន្ធ ដើម្បីស្រាវជ្រាវរកប្រវត្តិសារតាពិតប្រាកដរបស់ពូជស្រូវទាំងនោះ ដើម្បីឈានទៅរកការបន្សុទ្ធ និងចុះឈ្មោះផ្លូវការ សម្រាប់គំរូឲ្យមានការផលិតចែកចាយសម្រាប់គោលបំណងពាណិជ្ជកម្ម។ កិច្ចការនេះសង្ឃឹមថានឹងបានបញ្ចប់ក្នុងឆ្នាំ ២០១៦ នេះ។

- សាកល្បងតភ្ជាប់ទីផ្សារស្រូវរបស់កសិករបានមួយចំនួនទៅតាមរោងម៉ាស៊ីន ក្នុងនោះមាន ការភ្ជាប់ទីផ្សារស្រូវ សែនក្រអូបបានចំនួនប្រហែល ៣00តោន សហគមន៍អភិវឌ្ឍកសិកម្មខេត្ត កំពង់ធំ ទៅរោងម៉ាស៊ីនហាក់សែ និងភ្ជាប់ទីផ្សារស្រូវរំដួលពីសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិតខេត្តកំពង់ធំ ទៅរោងម៉ាស៊ីនក្រុមហ៊ុនអប្សរា ក្នុងបរិមាណជាង ៥00តោន។
- បានសម្រេចសហការជាមួយគម្រោង SCCRP ដើម្បីធ្វើការទៅលើពីរចំណុចរួមមាន៖

  ១-/ កិច្ចគាំទ្រសម្របសម្រួលកិច្ចសន្យាកសិកម្មរវាងរោងម៉ាស៊ីន និង កសិករ

  ២ -/ បង្កើតប្រព័ន្ធលក់ស្រូវរួមគ្នា ដើម្បីតភ្ជាប់ទីផ្សាស្រូវដល់កសិករទៅរោងម៉ាស៊ីនផ្ទាល់ដើម្បីបង្កើនប្រសិទ្ធភាពទីផ្សារប្រមូលទិញស្រូវក្នុងស្រុក

- នៅថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៦ បានសហការជាមួយក្រុមការងារគម្រោង SCCRP រៀបចំសិក្ខាសាលាផ្គូរផ្គងដៃគូរកិច្ចសន្យាកសិកម្មដើម្បីផលិតស្រូវ។
- កំពុងបន្តធ្វើការជំរុញអោយមានការសហការគ្នារវាងស្ថាប័នពាក់ព័ន្ធដើម្បីបង្កើតការងាររួមគ្នាក្នុងការបង្កើតសកម្មភាពរួមមួយដើម្បីអភិវឌ្ឍផលិតកម្មស្រូវ និងពូជ៕



*រូបភាពមួយចំនួនពេលកិច្ចប្រជុំរបស់គណៈកម្មការ FMP ExCo នេះ*

# សមិទ្ធផលការងារ របស់គណៈកម្មាធិការ ប្រតិប្រត្តិឥណទាន ជាមួយធនាគារ (Banking and Finance Solutions ExCo)



រូបភាពកិច្ចប្រជុំរបស់គណៈកម្មាធិការនេះ



**សមាសភាពគណកម្មាធិការទាំង ០៩ រូបៈ**

១.ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធាន
២.ឧកញ៉ា **ហ៊ុន ឡាក់** អនុប្រធាន
៣. ឧកញ៉ា **ត្វ ពុយ** សមាជិក
៤. ឧកញ៉ា **ច្រាយ សុន** សមាជិក
៥. លោក **លឹម យ៉ារ៉េត** សមាជិក
៦.លោក **ឌិត សុចល** សមាជិក
៧. តំណាង **ធនាគារកាណាឌីយ៉ា**
៨. តំណាង **ធនាគារអេស៊ីលីដា**
៩.តំណាង **ធនាគារអភិវឌ្ឍន៍ជនបទ**

អ្នកសម្របសម្រួល
លោក **ហ៊ីន ឆារ៉ា**

## I- គោលបំណង

គណៈកម្មាធិការនេះ ត្រូវបានបង្កើតឡើងដើម្បីជួសមុខឲ្យសហព័ន្ធ ក្រុមប្រឹក្សាភិបាល ក្នុងការចរចារជាមួយក្រសួងពាក់ព័ន្ធ ស្ថាប័នហិរញ្ញវត្ថុ ក្នុងការស្វែងរកយន្តការដោះស្រាយលើមធ្យោបាយផ្តល់ឥណទានដែលមានអត្រាការប្រាក់សមរម្យ និងលក្ខណៈសម្បទានសម្រាប់វិស័យស្រូវអង្ករ។ គណៈកម្មាធិការនេះក៏មានតួនាទីសិក្សាប្រភពឥណទានដែលមានអត្រាការប្រាក់ទាប និងរៀបចំយុទ្ធសាស្ត្រនិងគំរូឥណទានដ៏ល្អប្រសើរមួយក្នុងការផ្តល់ឥណទានដល់កសិករ ម៉ាស៊ីនកិនស្រូវនិងអ្នកនាំចេញអង្ករកម្ពុជា។

## II-បញ្ហាប្រឈម សកម្មភាពនិងលទ្ធផល

**១**- អត្រាការប្រាក់កម្ចីនៅធនាគារពាណិជ្ជ គឺនៅខ្ពស់ដែលមិនទាន់ឆ្លើយតបល្អគ្រប់គ្រាន់សម្រាប់ការធ្វើពាណិជ្ជកម្មទំនិញជួញដូរនៅក្នុងប្រទេសកម្ពុជា ខណៈដែលប្រាក់ចំណេញនៅស្តួចស្តើង ហើយចំណាយប្រតិបត្តិការនៅខ្ពស់។

**១.១**- ធ្វើការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធ ដើម្បីធ្វើហិរញ្ញប្បទានបន្ថែម ក្នុងការផ្តល់នូវឥណទានដែលមានអត្រាការប្រាក់អនុគ្រោះសម្រាប់វិស័យស្រូវអង្ករ។ គណៈកម្មាធិការបានបានជួបចរចារជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីស្នើសុំឲ្យក្រសួងហិរញ្ញប្បទានបន្ថែមតាមរយៈធនាគារអភិវឌ្ឍន៍ជនបទជួយដល់វិស័យស្រូវអង្ករ។

លទ្ធផលៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានទម្លាក់ថវិកាបន្ថែមចំនួនប្រមាណពី ២០ ទៅ ៣០លានដុល្លារ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ ដែលធ្វើឲ្យធនាគារនេះ មានថវិកាប្រមាណជាង ៥០លានដុល្លា ក្នុងការផ្តល់កម្ចីដែលមានអត្រាការប្រាក់ពិសេស សម្រាប់វិស័យស្រូវអង្ករ។ គណៈកម្មាធិការ នឹងបន្តការចរចារជាមួយស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ហិរញ្ញប្បទានបន្ថែមក្នុងវិស័យនេះ។

**១.២**- ស្វែងរកនូវប្រភពទុនដែលមានអត្រាការប្រាក់ទាបតាមរយៈកំចីពីភាគីអ្នកផ្តល់ជំនួយ ឬតាមធនាគារពាណិជ្ជនៅក្រៅប្រទេស និងប្រើប្រាស់កំចីនោះ សម្រាប់ផ្តល់ឥណទានក្នុងអត្រាការប្រាក់ទាប ដល់វិស័យអង្ករ ក្រោម៧ភាគរយ។

តាមរយៈវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន ចរចារជាមួយរាជរដ្ឋាភិបាលក្នុងការជួយចរចារជាមួយភាគីផ្តល់ជំនួយ ក្នុងការផ្តល់ឥណទានដែលមានការប្រាក់អនុគ្រោះ សម្រាប់វិស័យស្រូវអង្ករ។

**១-៣**- គណៈកម្មាធិការ បាននិងកំពុងសិក្សាជាមួយអ្នកជំនាញក្នុងការបង្កើតជាសម្ព័ន្ធដៃគូវិនិយោគ

(Rice Investment Consortium) ដែលនេះនឹងជំរុញនូវការទុកចិត្តពីស្ថាប័នហិរញ្ញវត្ថុ និងអ្នកទិញ សម្រួលដល់ទុនបង្វិល និងធានាបាននូវនិរន្តភាពក្នុងការប្រមូលស្រូវស្តុកទុក និងការផ្គត់ផ្គង់។ (គម្រោងនេះកំពុងសិក្សានៅឡើយ)

## ២. ជម្រុញឲ្យទទួលបាននូវបញ្ចាំស្តុកតាមរយៈការដាក់បញ្ចាំស្រូវ

**២.១**- កង្វះនូវទ្រព្យបញ្ចាំ សម្រាប់ទទួលឥណទានក្នុងការប្រមូលទិញក្នុងពេលប្រមូលផលដែលធ្វើឲ្យយើងគ្មានស្រូវគ្រប់គ្រាន់សម្រាប់ស្តុកទុក និងកិនសម្រាប់នាំចេញ នៅពេលមានតម្រូវការពីក្រៅប្រទេស

**២.១.១**- ចរចារជាមួយធនាគារពាណិជ្ជក្នុងស្រុក ដើម្បីផ្តល់នូវប្រាក់កម្ចី ពិសេសលក្ខណៈជាក្រុម ទៅដល់សមាជិក ស.អ.ក ក្នុងអត្រាតម្លៃប្រកួតប្រជែងសមរម្យ។ កំចីលក្ខណៈជាក្រុម មានអនុវត្តចំពោះកំចីនៅតាមមីក្រូហិរញ្ញវត្ថុ តែតាមធនាគារពាណិជ្ជក្នុងស្រុក មិនទាន់អនុវត្តនៅឡើយ។ ចំណុចនេះ មិនទាន់បានទទួលការឆ្លើយតបជាវិជ្ជមានពីធនាគារពាណិជ្ជនៅឡើយ។ គណៈកម្មាធិការនឹងបន្តចរចារជាមួយធនាគារពាណិជ្ជក្នុងការរកគំរូណាមួយ ដើម្បីឲ្យសមាជិកសហព័ន្ធអាចទទួលឥណទានក្នុងលក្ខណៈជាក្រុម។

**២.១.២**- ជំរុញការការទទួលឥណទានតាមរយៈបញ្ចាំស្តុកដែលធនាគារពាណិជ្ជខ្លះបានអនុវត្តជាមួយរោងម៉ាស៊ីនមួយចំនួនរួចមកហើយ និងបន្តការបញ្ចុះបញ្ចូល ជាមួយធនាគារពាណិជ្ជកម្ម ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ដើម្បីជំរុញឱ្យមានការអនុវត្ត ច្បាប់ប្រតិបត្តិការដែលមានកិច្ចធានា ច្បាប់ភតិសន្យា ដើម្បីអោយធនាគារអាចទទួលយកគោលការណ៍យកស្តុកមកបញ្ចាំ និងអនុវត្តឲ្យបានទូលំទូលាយ។

ប្រធានសហព័ន្ធបានចូលរួមជាមួយក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានទៅទស្សនកិច្ចនៅប្រទេសចិន ដើម្បីសិក្សាអំពីការសង់ឃ្លាំងតាមរយៈកំចីរបស់ចិន។ យើងបាននិងកំពុងសិក្សាផងដែរអំពីលទ្ធភាពចងក្រងសមាជិកសហព័ន្ធ ក្នុងការអនុវត្តការបញ្ចាំស្តុកស្រូវដើម្បីទទួលបានឥណទាន ដោយប្រើប្រាស់ឃ្លាំងរបស់សមាជិក និងធនាគារឯកជនដែលទទួលអនុវត្តនូវការបញ្ចាំស្តុកនេះ។

**២.២**- ឥណទានសម្រាប់កសិករ ក្នុងការធ្វើផលិតកម្មស្រូវ ក្នុងអត្រាការប្រាក់សមរម្យ សម្រាប់ទិញនូវ ធាតុចូលផ្សេងៗក្នុងផលិតកម្ម ដូចជាជី ថ្នាំ ពូជ និងបច្ចេកទេសកសិកម្ម ។ល។

**២.២.១**- ជម្រុញការបង្កើតនូវមីក្រូហិរញ្ញវត្ថុសម្រាប់កសិករតាមរយៈសហគមន៍កសិកម្ម ក្នុងអត្រាការប្រាក់ និងលក្ខខ័ណ្ឌអនុគ្រោះជាងមីក្រូហិរញ្ញវត្ថុទូទៅ ដោយផ្តោតកំចីឥណទាន ផ្សារភ្ជាប់និងអ្នកផ្គត់ផ្គង់ធាតុចូលទាំងនោះ ដូចជាកំចីសម្រាប់ទិញជី ថ្នាំ ពូជស្រូវ ។ល។



*រូបភាពកិច្ចប្រជុំនៅសាលប្រជុំធនាគារអភិវឌ្ឍន៍ជនបទ*

# សមិទ្ធផលការងារ របស់គណៈកម្មាធិការ ប្រតិបត្តិវិន័យ និងក្រមសីលធម៌

## (Code of Conduct and Ethics ExCo)



លោក នង ឆាសនា ប្រធានគណៈកម្មាធិការ

**មានវិន័យគឺមានសេចក្តីថ្លៃថ្នូរ!** នេះជាសុភាសិតខ្មែរ ហើយ នេះក៏ជាប្រយោគដែលមានអត្ថន័យប្រកបដោយភាពសត្យានុម័តមួយសម្រាប់គ្រប់វិស័យ គ្រប់ស្ថាប័ន គ្រប់អង្គភាព និង គ្រប់ក្រុមគ្រួសារ ទោះធំឬតូច។

វិន័យនិងក្រមសីលធម៌របស់សហព័ន្ធស្រូវអង្ករគឺជាផ្នែកមួយដ៏សំខាន់ក្នុងការលើកស្ទួយការប្រតិបត្តិរបស់សមាជិកសហព័ន្ធប្រកបដោយសុចរិតភាព សេចក្តីថ្លៃថ្នូរ ការគោរព និង ការទទួលស្គាល់ប្រកបដោយភាពទូលំទូលាយនៅកម្រិតជាតិនិងកម្រិតអន្តរជាតិ។ ការប្រតិបត្តិតាមក្រមសីលធម៌ជាមធ្យោបាយតែមួយគត់ក្នុងការនាំនូវកិត្យានុភាពជូនអង្ករកម្ពុជា ដែលប្រមុខរាជរដ្ឋាភិបាល ឬថា ប្រតិបត្តិករទាំងអស់ក្នុងវិស័យស្រូវអង្ករ ទទួលស្គាល់ថាជា«មាសស»កម្ពុជា។



គណៈកម្មាធិការនេះអាចចាត់ថាជាកូនពៅក្នុងចំណោមគណៈកម្មាធិការទាំង៥ ព្រោះសហព័ន្ធស្រូវអង្ករកម្ពុជាបានសម្រេចបង្កើតឡើងនៅថ្ងៃទី ថ្ងៃទី ០១ ខែកញ្ញាឆ្នាំ ២០១៥។ គណៈកម្មាធិការនេះមានសមាជិក ចំនួន ១ ៥ រូប ដោយមានគោលបំណងច្បាស់លាស់គឺដើម្បីទប់ស្កាត់ការនាំអង្ករពីប្រទេសជិតខាងដែលមិនត្រឹមត្រូវតាមច្បាប់ និងការពារដល់រោងម៉ាស៊ីនកិនស្រូវ ក្នុងស្រុក ដែលកំពុងប្រឈមនិងការបិទទ្វារ ដែលបណ្តាលមកពីការនាំចូលអង្ករពីប្រភពផ្សេងរួចនាំចេញតាមច្រកកម្ពុជា។

ក្រោយអង្ករកម្ពុជាទទួលបានការបញ្ជាទិញកាន់តែច្រើនពីទីផ្សារបរទេស ជាពិសេសបំផុតគឺ បន្ទាប់ពីអង្ករកម្ពុជាបានឈ្នះពានរង្វាន់ជាអង្ករឆ្ងាញ់បំផុតក្នុងពិភពលោកបីឆ្នាំជាប់ៗគ្នា ពោលគឺនៅឆ្នាំ២០១២ ២០១៣ និង ឆ្នាំ២០១៤ ក្រុមហ៊ុននាំអង្ករចេញជាច្រើនបានបង្កើតឡើងជាបន្តបន្ទាប់ ដើម្បីចូលរួមចំណែកក្នុងចលនាទីផ្សារអង្ករនៅកម្ពុជា។

ជាមួយបញ្ហាប្រឈមដែលគេតែងឮនិងជួបប្រទះក្នុងវិស័យស្រូវអង្ករ សហព័ន្ធស្រូវអង្ករកម្ពុជា ដែលជាស្ថាប័នតែមួយគត់តំណាងឲ្យវិស័យឯកជនក្នុងវិស័យស្រូវអង្ករ បានសម្រេចចិត្តបង្កើតនូវគណៈកម្មាធិការ ថ្មីមួយដែលមានឈ្មោះថា គណៈកម្មាធិការវិន័យនិងក្រមសីលធម៌។ គណៈកម្មាធិការនេះគឺជាការឆ្លើយតបទៅនឹងភាពចាំបាច់ របស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការលើកកម្ពស់ការអនុវត្តន៍ប្រកបដោយតម្លាភាព និង ភាពស៊ីសង្វាក់គ្នាក្នុងចំណោមក្រុមហ៊ុននាំចេញទាំងអស់ ដោយជៀសឲ្យបាននូវការនាំអង្ករពីបរទេសចូលមកកាន់កម្ពុជា រួចនាំចេញបន្តដោយសំអាងថានោះជាអង្ករកម្ពុជា។

គណៈកម្មាធិការវិន័យនិងក្រមសីលធម៌នេះ មិនមែនអាចធ្វើការងារខ្លួនប្រកបដោយភាពរលូនបាននោះទេ ខណៈដែលបញ្ហាបានចាក់ឫសចាក់គល់ជាយូរមកហើយ។ បញ្ហាទាំងនោះគឺក្រុមហ៊ុនខ្លះដែលមានចំណងទាក់ទងយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុនក្នុងស្រុកក្នុងការនាំអង្ករចូលមកកម្ពុជាហើយទិញស្រូវត្រឡប់ចេញទៅវិញ គឺជៀសមិនផុតពីការនាំអង្ករចូលរួមរួចនាំចេញនោះទេ។

ដោយសារប្រទេសកម្ពុជាជាប្រទេសក្រីក្រមួយ ការទទួលបានការអនុញ្ញាតពីសហភាពអឺរ៉ុបក្នុងការនាំអង្ករចេញទៅដោយរួចពន្ធ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការរួមចំណែកបង្កើតការងារធ្វើក្នុងស្រុក បង្កើនជីវភាពរបស់ប្រជាកសិករ និង បង្កើនប្រាក់ចំណូលរបស់ប្រជាកសិករខ្មែរ។ តែបើការនាំអង្ករចូលពីប្រទេសជិតខាង គឺច្បាស់ណាស់ថា កម្ពុជានៅតែប្រឈមការងារលំបាកៗជាច្រើនតទៅទៀត។

គណៈកម្មាធិការវិន័យនិងក្រមសីលធម៌នេះ អាចចាត់ទុកថាជាផ្នែកដ៏សំខាន់មួយក្នុងការធានានូវភាពស្អាតស្អំចំពោះសមាជិក ដែលបានចុះហត្ថលេខាទទួលស្គាល់នូវលក្ខន្តិកៈទាំងឡាយណាដែលបានដាក់ចេញ ដើម្បីធានានូវភាពស្អាតស្អំរបស់អង្ករកម្ពុជា ក្នុងទីផ្សារជាតិនិងអន្តរជាតិ។ ជាការពិតណាស់ វិន័យតែងនាំមកនូវសេចក្តីថ្លៃថ្នូរ។ ដូចនេះ ការគោរពវិន័យនិងក្រមសីលធម៌គឺជាដំណើរការដ៏សំខាន់ក្នុងការលើកស្ទួយអង្ករកម្ពុជានៅទីផ្សារអន្តរជាតិ បន្ទាប់ពីការ ក្រុមហ៊ុនឯកជនទាំងអស់បានឯកភាព

**សមាសភាពគណកម្មាធិការទាំង ១៥ រូបៈ**

| | | |
|---|---|---|
| ១. | លោក **នង ឆាសនា** | ប្រធាន |
| ២. | លោក **ភាន់ គន្ធី** | អនុប្រធាន |
| ៣. | លោក **ចាន់ សុឃាំង** | សមាជិក |
| ៤. | លោក **ហេង ផេង** | សមាជិក |
| ៥. | លោក **ហ៊ាង គីមស្នួរ** | សមាជិក |
| ៦. | លោក **រិន សីហា** | សមាជិក |
| ៧. | លោក **ឡាយ ឈុនហួ** | សមាជិក |
| ៨. | លោក **ចាន់ ឧុទ្ធី** | សមាជិក |
| ៩. | លោក **សៃ ឡាឡៃន** | សមាជិក |
| ១០. | លោក **រស់ សុផារិទ្ធ** | សមាជិក |
| ១១. | លោក **ឈុន ធំ** | សមាជិក |
| ១២. | លោក **អែល សោត** | សមាជិក |
| ១៣. | លោក **លិម ពីស៊ាន** | សមាជិក |
| ១៤. | លោក **យន់ ហុង** | សមាជិក |
| ១៥. | លោក **ចន្ទ្យ ឈិច** | សមាជិក |

អ្នកសម្របសម្រួល
លោក **យ៉ាន ពេជ្រ**

គ្នាជាផ្លូវមួយក្នុងការបង្កើតឡើងនូវសហព័ន្ធស្រូវអង្ករជាផ្លូវការ។

សហព័ន្ធស្រូវអង្ករកម្ពុជា បានថែងយ៉ាងច្បាស់ថា គណៈកម្មាធិការមានភារៈកិច្ចអនុវត្តការងារដោយស្ម័គ្រចិត្ត លើកិច្ចការនៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងផែនការសកម្មភាព ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលសហព័ន្ធ។ ភារកិច្ចរបស់គណៈកម្មាធិការនេះមានដូចខាងក្រោម៖


រូបភាពកិច្ចប្រជុំលើកទី២របស់គណៈកម្មាធិការ COCE នេះ

- ជួសមុខអោយសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ធ្វើការរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាព និងអនុវត្តវិធានការជម្រុញការទប់ស្កាត់ការនាំអង្ករពីប្រទេសជិតខាង ដែលបាននាំចូលមិនស្របច្បាប់ ក្នុងការផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក និងកែច្នៃដើម្បីនាំ ចេញទៅកាន់ទីផ្សារអន្តរជាតិ។
- ទទួលបន្ទុកការងារវិន័យ និងអធិការកិច្ចនៃក្រមសីលធម៌ ដោយជំរុញអោយគ្រប់សមាជិកទាំងអស់អនុវត្ត និងគោរព តាមក្របខណ្ឌក្រមសីលធម៌និងគោលការណ៍នៃការងារ រួមមាន សុចរិតភាព តម្លាភាព ការអនុវត្តន៍ជាក់ស្តែង ភាពជឿនលឿន សាមគ្គីភាព និង រក្សាឲ្យបាននូវក្រមសីលធម៌ខ្ពស់បំផុតក្នុងសកម្មភាពជំនួញជាមួយភាគីពាក់ព័ន្ធទាំងអស់។
- កំណត់ពីផែនការ និងនីតិវិធីក្នុងការដាក់ពិន័យចំពោះសមាជិកណាដែលមិនបានអនុវត្តតាមក្រមសីលធម៌ បទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈរបស់សហព័ន្ធស្រូវអង្ករកម្ពុជា។
- ជួសមុខអោយសហព័ន្ធ ក្រុមប្រឹក្សាភិបាលសហព័ន្ធ ក្នុងការចរចារជាមួយក្រសួងពាក់ព័ន្ធ ស្ថាប័នជាតិ ភ្នាក់ងារពាក់ព័ន្ធនានា ក្នុងការស្វែងរកនូវវិធានការទប់ស្កាត់និងការដាក់ពិន័យដល់អ្នកដែលនាំអង្ករពីប្រទេសជិតមិនត្រឹមត្រូវតាមច្បាប់ និងការធ្វើសកម្មភាពជំរុញការផ្សព្វផ្សាយ ការងារអប់រំពន្យល់ដល់អ្នកពាក់ព័ន្ធអំពីផលប៉ះពាល់ក្នុងការនាំអង្ករពីប្រទេសជិតខាងទាំងការប្រើប្រាស់ក្នុងស្រុក និងកែឆ្នៃដើម្បីនាំចេញបន្តទៅកាន់ទីផ្សារអន្តរជាតិ ក្រោមរូបភាពម៉ាកអង្ករកម្ពុជា។
- គណៈកម្មាធិការ ត្រូវធ្វើរបាយការណ៍ទៀងទាត់ជូនដល់ក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។ ចំពោះករណីការងារណាដែលមិនមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាព គណៈកម្មាធិការត្រូវស្នើសុំដល់ក្រុមប្រឹក្សាភិបាលឲ្យអនុញ្ញាតសម្រេចជាមុនសិន។
- ក្នុងករណីចាំបាច់ គណៈកម្មាធិការអាចស្នើសុំបន្ថែមសមាជិក និងទីប្រឹក្សាសំរាប់គណៈកម្មាធិការ ទៅក្រុមប្រឹក្សាភិបាលសហព័ន្ធ។


រូបភាពកិច្ចប្រជុំលើកទី២របស់គណៈកម្មាធិការ COCE នេះ

បើទោះបីគណៈកម្មាធិការនេះទើបកើតឡើងក្រោយគេ ក៏ពិតមែនតែថ្នាក់ដឹកនាំនិងសមាជិករបស់គណៈកម្មាធិការមួយនេះ បានខិតខំប្រឹងប្រែងជួបប្រជុំគ្នាចំនួនពីរលើករួចមកហើយ ដើម្បីស្វាបស្ទង់កម្លាំងការងារដែលខ្លួនត្រូវទទួលរាប់រង។

កិច្ចប្រជុំទាំងពីរលើកនោះមាន ការយកចិត្តទុកដាក់ចូលរួមពីសំណាក់ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ថ្នាក់ដឹកនាំ និងសមាជិករបស់គណៈកម្មាធិការប្រតិបត្តិផ្ទាល់ ដោយសម្រេចបាននូវលទ្ធផលខ្លះគួរឲ្យកត់សំគាល់។

ក្រមសីលធម៌ដែលបានតាក់តែងឡើងក្នុងពេលកន្លងមក គឺជាគោលដៅរួមសម្រាប់ការប្រតិបត្តិរួមក្នុងចំណោមសមាជិករបស់សហព័ន្ធ ជាពិសេសគឺក្រុមហ៊ុននាំអង្ករចេញតែម្តង។៖


រូបភាពពេលប្រជុំរបស់គណៈកម្មាធិការនេះ

## ខាងក្រោមនេះគឺជាខ្លឹមសាររបស់ក្រមសីលធម៌ទាំងស្រុង៖

**សហព័ន្ធស្រូវអង្ករកម្ពុជា**

យើងខ្ញុំឈ្មោះ ……………………………មានតួនាទីជា ……………………

*រោងម៉ាស៊ីនកិនស្រូវ* ……………………………………………………………
អាសយដ្ឋាន ……………………………………………………………………

**ក្រមសីលធម៌**

**I. មុខកថា**

**១-១** ក្រមសីលធម៌នៃសហព័ន្ធស្រូវអង្ករកម្ពុជាត្រូវបានចែងក្នុងគុណតម្លៃចំនួន៨។ គោលការណ៍គន្លឹះដែលគ្រប់សមាជិកទាំងអស់បានអនុម័តនិងយល់ព្រមអនុវត្តតាមនៅក្នុងរាល់សកម្មភាពជំនួញ ជាមួយភាគីដែលពាក់ព័ន្ធទាំងអស់ មិនថាជា អ្នកទិញ អ្នកផ្គត់ផ្គង់ ដៃគូ និយោជិក ឬសហគមន៍។

**១-២** ដោយសារកម្ពុជាក្លាយជាប្រទេសនាំចេញអង្ករ ទៅកាន់ទីផ្សារអន្តរជាតិ អតិថិជន របស់យើងពឹងនូវការបំពេញអោយបាននូវកាតព្វកិច្ចដ៏តឹងរឹងលើផ្នែកគុណភាពនៃទំនិញនិងសេវាកម្មដែលយើងផ្តល់ ទោះបីជា មានការគោរពផល់ ចិរភាពបរិស្ថាននិងសង្គមនៅក្នុងសង្វាក់ផលិតកម្ម។ក្នុងន័យនេះ ក្រមសីលធម៌ បានដើរតួក្នុងការគាំទ្រក្នុងការសម្រេចអោយបាននូវទស្សនវិស័យនិងបេសកកម្មរបស់យើង។

**១-៣** ក្រមសីលធម៌នេះមិនមានអទិភាពលើច្បាប់នានារបស់រដ្ឋនោះទេ តែមានគោលបំណងកំណត់នូវស្តង់ដារប្រតិបត្តិមួយដែលគ្រប់សមាជិកទាំងអស់ត្រូវពិច

1

ថាពិនិត្យដោយស្មារតីយកចិត្តទុកដាក់។

**១-៤** សមាជិកណាមួយដែលរកឃើញថាធ្វើផ្ទុយឬបំពានបទប្បញ្ញត្តិនៃក្រមសីលធម៌នេះនឹងត្រូវទទួលនូវការអនុវត្តវិន័យផ្សេងៗ ដោយរាប់ទាំងការព្យួរឬលុបចោលនូវសមាជិកភាពនៃស.អ.ក។ ការអនុវត្តវិន័យបែបនេះនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ

**II. ទស្សនវិស័យ**

"ផ្តល់អង្ករដែលមានលក្ខណៈប្រកួតប្រជែងនិងគុណភាពខ្ពស់បំផុតទៅពិភពលោក"

**III. បេសកកម្ម**

យើងនឹងសម្រេចអោយបាននូវទស្សនវិស័យរបស់យើងដោយប្តេជ្ញានឹងខំប្រឹងប្រែងដោយឥតឈប់ឈរក្នុងការធ្វើអោយប្រសើរឡើង នូវផលិតភាពនៃបច្ចេកទេសនៃការដាំដុះនិងកែច្នៃស្រូវអង្ករ ដោយបន្ថយនូវការចំណាយនានា នៃដំណើរការនាំចេញនិងគោរពតាមក្របខ័ណ្ឌនៃវិស័យមួយដែលមានក្រមសីលធម៌ដែលផ្តល់តម្លៃ សុចរិតភាព តម្លាភាព ការអនុវត្តជាក់ស្តែង លទ្ធផល ភាពលឿន សាមគ្គីភាព ការវិនិយោគលើផលប៉ះពាល់ និងអត្ថប្រយោជន៍ទៅសមាជិកទាំងអស់ ព្រមជាមួយគ្នានោះ រក្សាអោយបាននូវស្តង់ដារសីលធម៌ខ្ពស់បំផុតនៅក្នុងសកម្មភាពជំនួញជាមួយភាគីពាក់ព័ន្ធទាំងអស់ដើម្បីការពារនូវគុណភាពក្នុងរយៈពេលវែង កិត្តិយស និងនិរន្តរភាពនៃម៉ាកអង្ករកម្ពុជា។

**IV. គុណតម្លៃស្នូលទាំង៨**

គុណតម្លៃស្នូលទាំង៨របស់យើងតំណាងអោយតម្លៃនៃក្រមសីលធម៌និងគោលការណ៍នៃការងារដែលជំរុញនូវរាល់សកម្មភាពរបស់សមាជិក បុគ្គលិក និងថ្នាក់ដឹកនាំនៃសហព័ន្ធស្រូវអង្ករកម្ពុជា។
តម្លៃនៃក្រមសីលធម៌និងគោលការណ៍នៃការងារទាំងនោះរួមមាន៖

**សុចរិតភាព**

យើងនឹងមិននិយាយ ធ្វើ ឬ ប្រកាស អ្វីមួយដែលមិនមែនជាការពិតឬនាំអោយភ័ន្ត

2

ច្រឡំ។ យើងជឿជាក់ថា លទ្ធផលដ៏ល្អចុងក្រោយមិនអាចស៊ីសងគ្នាជាមួយនឹងអំពើអាក្រក់ដែលយើងធ្វើដើម្បីសម្រេចលទ្ធផលនោះទេ ហើយអំពើខុសឆ្គងពីរក៏មិនអាចបង្កើតបានជាអំពើល្អមួយដែរ។ យើងក៏ជឿជាក់ថាការព្រងើយអំពីច្បាប់ពុំអាចប្រើដោះសារសំរាប់ការបំពានច្បាប់បានទេ។

**តម្លាភាព**

យើងនឹងបង្ហាញនូវព័ត៌មានទៅសមាជិកនិងភាគីពាក់ព័ន្ធទាំងអស់ ក្នុងមូលដ្ឋានពេលវេលាពិតប្រាកដ។

**ការអនុវត្តជាក់ស្តែង**

រាល់សកម្មភាពទាំងអស់នឹងត្រូវជំរុញទៅមុខដោយការពិចារណាដោយជាក់ស្តែង ហើយយើងនឹងចៀសវាងនូវវិធីសាស្ត្រដោះស្រាយដែលស្មុគស្មាញនិងប្រើពេលច្រើនទៅនឹងបញ្ហាណាមួយ។

**ការផ្តោតលើលទ្ធផល**

គ្រប់យុទ្ធសាស្ត្រ គោលនយោបាយ និងសកម្មភាពរបស់យើងនឹងផ្តោតដោយម៉ត់ចត់ទៅលើលទ្ធផល។

**សាមគ្គីភាព**

យើងនឹងរក្សានូវសាមគ្គីគ្នាក្នុងការសម្រេចអោយបាននូវគោលដៅរួមរបស់យើង និងចៀសវាងការទាស់ទែងគ្នាតាមរយៈពាក្យសំដីនិងអំពើនានា។

**ភាពលឿន**

យើងនឹងមិនពន្យាពេលដែលធ្វើអោយយឺតយ៉ាវការសម្រេចចិត្តនានារបស់យើងទេ ដោយយកគោលការណ៍ពេលវេលាជាមាសប្រាក់។

**វិនិយោគលើផលប៉ះពាល់**

រាល់សកម្មភាពរបស់យើងទាំងអស់ត្រូវគោរពនូវការទទួលខុសត្រូវចំពោះសង្គមនិងបរិស្ថាន នៅក្នុងសង្វាក់ផលិតកម្មស្រូវអង្ករ។

3

**អត្ថប្រយោជន៍ទៅសមាជិកនិងសហគមន៍**

គ្រប់សកម្មភាពទាំងអស់នឹងត្រូវផ្តល់ប្រយោជន៍ទៅសមាជិកទាំងអស់និងសហគមន៍ដែលយើងធ្វើការជាមួយ។




**៥-១** សមាជិករបស់ ស.អ.ក ត្រូវបានលើកទឹកចិត្តអោយគិតគូរពីកិច្ចការរបស់ខ្លួនតាមមាត្រានៃសមាគមក្នុងការបង្កើននូវគោលបំណង ប្រយោជន៍ និងកត្តិយសនៃសមាគមទៅដល់កំរិតនៃសមត្ថភាពរបស់ពួកគេ។

**៥-២** សមាជិកនៃ ស.អ.ក ត្រូវបាន លើកទឹកចិត្តអោយគោរពតាម ការអនុវត្តដ៏ល្អបំផុត ច្បាប់ បទប្បញ្ញត្តិគ្រប់ប្រភេទទាក់ទងទៅនឹង សកម្មភាពពាណិជ្ជកម្ម ការធ្វើអាជីវកម្ម ចំណាត់ថ្នាក់ ការថ្លឹងថ្លែង ការវេចខ្ចប់ ការដឹកជញ្ជូន និងការដឹកទំនិញ ។

4

៤-៣ សមាជិក ស.អ.ក ជាអ្នកទទួលខុសត្រូវចំពោះ អំពើនៃបុគ្គលិក ឬ អ្នកម៉ៅការបន្ត ឬ (និង) អ្នកផ្គត់ផ្គង់របស់ខ្លួនដែលអាចកំពុងតំណាងអោយពួកគេ ហើយដែលផ្ទុយនឹង បទប្បញ្ញត្តិណាមួយ នៃក្រមសីលធម៌នេះ។

៤-៤ សមាជិក ស.អ.ក ត្រូវប្តេជ្ញាចិត្តដើម្បីរក្សា ពាក្យសំដី របស់ខ្លួន ដោយ-សំដីដែលសន្យាមិនត្រូវក្រឡាស់-។

V. **ការអនុវត្ត**

៥-១ សមាជិកណាមួយដែលប្រព្រឹត្តល្មើសលើតម្លៃសីលធម៌នៃក្រមសីលធម៌នេះ នៅក្នុងអាជីវកម្មរបស់គេ នឹងត្រូវទទួលរកនូវការដាក់ទណ្ឌកម្ម។ តម្លៃសីលធម៌ចំបងគឺ សុចរិតភាព តម្លាភាព ការវិនិយោគលើផលប៉ះពាល់ និងអត្ថប្រយោជន៍ ទៅគ្រប់សមាជិកនិងសហគមន៍។

៥-២ ការដាក់ទណ្ឌកម្មទៅលើសមាជិកនឹងត្រូវអនុវត្តដោយគណៈកម្មាធិការវិន័យ ដែលមានសមាជិកចំនួន៦(ប្រាំមួយ)រូបនៃក្រុមប្រឹក្សាភិបាល។ សមាជិកទាំង៦នៃគណៈកម្មាធិការវិន័យនឹងត្រូវជ្រើសរើសតាមរយៈការចាប់ឆ្នោតដោយចៃដន្យ សំរាប់ករណីនិមួយៗ។
អ្នកជាប់ចោទនិងដៃគូពាណិជ្ជកម្មណាមួយ ឬសាច់ញាតិ មានសិទ្ធិទទួលបាន ត្រូវបានរួមបញ្ចូល នៅក្នុងការចាប់ឆ្នោត។

៥-៣ គណៈកម្មាធិការវិន័យ ត្រូវមានសវនាការដើម្បីអនុញ្ញាតឱ្យអ្នកជាប់ចោទពន្យល់ពីខ្លួនឯង ដោយមានភស្តុតាងសំរាប់បង្ហាញ។

៥-៤ ដោយអាស្រ័យលើភាពធ្ងន់ធ្ងរនៃការល្មើសនិងភស្តុតាង គណៈកម្មាធិការវិន័យនឹងសម្រេចចិត្តក្នុងការចេញសាលក្រមណាមួយ រួមមាន " មិនមានកំហុស " "ព្រមាន" "ផ្អាកសមាជិកភាព" សម្រាប់ពេលកំណត់មួយ ឬ " លុបចោលសមាជិកភាព" ។

៥-៥ ការអនុវត្តនៃក្រមសីលធម៌នេះត្រូវអនុវត្តលើបញ្ហាល្មើសនៃសីលធម៌ ដោយរាប់បញ្ចូលក្រមសីលធម៌របស់សហភាពអឺរ៉ុប (European Union Code of Conduct, EUCoC) ដែលចុះហត្ថលេខារវាង ស.អ.ក និងក្រសួងពាណិជ្ជកម្ម នៅឆ្នាំ ២០១៩ ហើយទោះបី EUCoC មានយន្តការអនុវត្តជាក់លាក់របស់ខ្លួន នៅពេលដែលភាពជាប់ទាក់ទងទៅនឹងការរំលោភបំពានសិទ្ធិប្រភពដើមនៃអង្ករដែលត្រូវបានដឹកតាំងដោយ។

ហត្ថលេខា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ......................ខែ កញ្ញាឆ្នាំ ២០១៩

ឈ្មោះ ..................................................

តួនាទី ..................................................

រោងម៉ាស៊ីនកិនស្រូវ ..................................................

6

( រហូតមកដល់ពេលនេះក្រុមហ៊ុនអ្នកនាំចេញ និងរោងម៉ាស៊ីនកិនស្រូវចំនួន **៥៦** ហើយដែលបានចុះហត្ថលេខាលើក្រមសីលធម៌របស់ ស.អ.ក )

## ក្រុមហ៊ុនដែលបានចុះហត្ថលេខាលើក្រមសីលធម៌

| ល/រ | ឈ្មោះក្រុមហ៊ុន |
|---|---|
| ០១ | Soma Group ( President ) |
| ០២ | Nikoline Investment |
| ០៣ | Battambang Rice Investment |
| ០៤ | Carma Rice Limited |
| ០៥ | Ean Heang Import Export |
| ០៦ | City Rice Import Export Co., ltd |
| ០៧ | H.S Rice Co. , Ltd |
| ០៨ | Kampong Thom Rice Mill Limited |
| ០៩ | Sok Keo Import Export Co., Ltd |
| ១០ | Bayong Cereal Co., Ltd |
| ១១ | T .O.T ( trust our Trade Co., Ltd |
| ១២ | Hung Hiep Cambodia Co., Ltd |
| ១៣ | Thmor Korl Rice Import Export Co., Ltd |
| ១៤ | Indochina Rice Mill Limited |
| ១៥ | W.K.R Trading |
| ១៦ | Vong Bun Heng Import Export Co., Ltd |
| ១៧ | Uni-Natural Co., Ltd |
| ១៨ | Amru Rice Cambodia Co., Ltd |
| ១៩ | Amru and hanwa international Co., Ltd |
| ២០ | Mekong Oryza Traing |
| ២១ | CK rice Trading Co., Ltd |
| ២២ | Signature of Asia Co., Ltd |
| ២៣ | Cambodia Lisshine International Co., Ltd |
| ២៤ | Golden Daun Keo rice Mill Co., Ltd |
| ២៥ | Jasmine Factory Co., Ltd |
| ២៦ | Cavifood Cambodia Co., Ltd |
| ២៧ | Golden Rice Cambodia Co., Ltd |
| ២៨ | Mekong Agro (kh) Industrial Limited |
| ២៩ | SScorp Cambodia Co., Ltd |
| ៣០ | Men Sarun Import Export Co., Ltd |
| ៣១ | Crystal Rice Kampuchea Co., Ltd |
| ៣២ | Lim Heng Leap Trading Co., ltd |
| ៣៣ | Palm Rice Co., Ltd |
| ៣៤ | Baitan Kampuchea Co., Ltd |
| ៣៥ | Lork Eak Heng Sek Meas Rice Co., Ltd |
| ៣៦ | Tech Soon Agro-Industry Co., Ltd |
| ៣៧ | Kong Hour Rice Mill Limited |
| ៣៨ | Camshin Xin Xi Group |

| ល/រ | រោងម៉ាស៊ីនកិនស្រូវ |
|---|---|
| ៣៩ | រោងម៉ាស៊ីនកិនស្រូវឈិត ប៊ុន ថន |
| ៤០ | រោងម៉ាស៊ីនកិនស្រូវឈុន ធំ |
| ៤១ | រោងម៉ាស៊ីនកិនស្រូវ នង់ស្រីម |
| ៤២ | រោងម៉ាស៊ីនកិនស្រូវ យិនម៉ាន់ |
| ៤៣ | រោងម៉ាស៊ីនកិនស្រូវ ភាគ ឈួយ |
| ៤៤ | រោងម៉ាស៊ីនកិនស្រូវ ស៊ីវ ឡាយ |
| ៤៥ | រោងម៉ាស៊ីនកិនស្រូវ កៅ ង៉ែត |
| ៤៦ | រោងម៉ាស៊ីនកិនស្រូវ ចាំង ម៉េង |
| ៤៧ | រោងម៉ាស៊ីនកិនស្រូវ ភួកុក គី |
| ៤៨ | រោងម៉ាស៊ីនកិនស្រូវ ហ៊ួយ មាន |
| ៤៩ | រោងម៉ាស៊ីនកិនស្រូវ ថនជា |
| ៥០ | សហគមន៍អភិវឌ្ឍកសិកម្ម និគម ព្រះសិហនុ |
| ៥១ | រោងម៉ាស៊ីនកិនស្រូវ ជិនមី |
| ៥២ | រោងម៉ាស៊ីនកិនស្រូវ ជា ហ៊ាប |
| ៥៣ | សម្ព័នសមាគមសហគ្រាសធុនតូចនឹងមធ្យមកម្ពុជា |
| ៥៤ | រោងម៉ាស៊ីនកិនស្រូវ ង៉ូវហ៊ួង |
| ៥៥ | រោងម៉ាស៊ីនកិនស្រូវ លី ស៊ាង ឈាន |
| ៥៦ | រោងម៉ាស៊ីនកិនស្រូវ ហួង ឡេង |

## កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នថ្នាក់ជាតិ

សហព័ន្ធស្រូវអង្ករកម្ពុជាជាស្ថាប័នឯកជន និង ជាដៃគូតែមួយគត់ សម្រាប់ការពិភាក្សាគោលនយោបាយស្រូវអង្ករជាមួយរាជរដ្ឋាភិបាល។ ដោយសារប្រកាន់យកនូវតួនាទីស្នូលគឺ ការផ្តល់នូវអង្ករដែលមានតម្លៃប្រកួតប្រជែង និងគុណភាពខ្ពស់បំផុតដល់ពិភពលោក ព្រមទាំងការសន្យានឹងលះបង់ជានិច្ចដើម្បីធ្វើឲ្យប្រសើរឡើងនូវផលិតភាពនៃបច្ចេកទេសកសិកម្ម ការកិនកែច្នៃអង្ករ សហព័ន្ធស្រូវអង្ករកម្ពុជាក្នុងអាណត្តិទី១ នេះ បានធ្វើសកម្មភាពយ៉ាងច្រើនក្នុងការបង្កើនទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការផ្សេងៗជាមួយក្រសួងនិងស្ថាប័នរដ្ឋជាច្រើនដែលពាក់ព័ន្ធ។

ក្នុងអាណត្តិទីមួយនេះសហព័ន្ធស្រូវអង្ករកម្ពុជាបង្កើតឡើងជារូបរាងឡើង និង បានបង្កើតលេខាធិការដ្ឋានឲ្យដំណើរការដើម្បីបំពេញតួនាទីជាភ្នាក់ងារភ្ជាប់ទំនាក់ទំនងជាមួយ ក្រសួង និង ស្ថាប័នជាតិសំខាន់ៗក្នុងបំណងស្វែង រកដំណោះស្រាយជូនដល់វិស័យស្រូវអង្ករដែលបម្រើឲ្យតម្រូវការចាំបាច់របស់កសិករខ្មែរយ៉ាងច្រើនលើសលប់ និង ជាផ្នែកមួយដ៏មានសក្តានុពលក្នុងការរក្សាកំណើន និង សន្តិសុខស្បៀងប្រកបដោយចិរភាព។

ក្រសួងដែលសហព័ន្ធស្រូវអង្ករកម្ពុជា បានធ្វើជំនួបជាបន្តបន្ទាប់ក្នុងពេលកន្លងមក ចាប់ផ្តើមពីដើមអាណត្តិរហូតដល់ចុងអាណត្តិទី១នេះរួមមាន៖

- **ក្រសួងពាណិជ្ជកម្ម៖**
  ជាក្រសួងដែលបានជួយជ្រុមជ្រែងខ្លាំងក្លាបំផុត ដល់ដំណើរការសហព័ន្ធស្រូវអង្ករកម្ពុជា តាំងពីចាប់បដិសន្ធិតរៀងមក។ ប្រធានបទដ៏សំខាន់មួយ ដែលក្រសួងពាណិជ្ជកម្ម ដែល កាលនោះ ដឹកនាំដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល**-គឺតែងតែបាន ស្នើឲ្យអ្នកពាក់ព័ន្ធក្នុងវិស័យស្រូវអង្ករ សិក្សាលម្អិតទៅតម្លៃផលិតអង្ករនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីប្រមូលផលរហូតដល់ការនាំចេញ។
  ឆ្លើយតបបញ្ហានេះ សហព័ន្ធស្រូវអង្ករតែងតែយក ចិត្តទុកដាក់ជានិច្ចក្នុងការប្រមូលទិន្នន័យពីប្រភពរោងម៉ាស៊ីនកិនស្រូវអ្នកនាំចេញអង្ករ។ យើងទទួលស្គាល់ថា កិច្ចការទាំងនេះគឺ ជារឿងមួយដែលពិបាកនឹងធ្វើ និង ទទួលបាននូវតម្លៃជាក់លាក់ និង ផ្លូវការខ្លាំងណាស់ ដោយសារការចំណាយរបស់រោងម៉ាស៊ីនកិនស្រូវ និង អ្នកនាំចេញអង្ករគឺខុសៗគ្នា ទៅតាមការចចារនាំចេញរៀងៗខ្លួន។ ទោះជាបែបណាក៏ដោយគណៈកម្មាធិការប្រតិបត្តិ ថ្លៃដើម តែងតែខិតខំរកវិធីដើម្បីទទួលបាននូវព័ត៌មានពាក់ព័ន្ធតម្លៃស្រូវអង្ករនេះ។ ក្រសួងពាណិជ្ជកម្មនិងសហព័ន្ធស្រូវអង្ករកម្ពុជា បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាមួយដើម្បីមានឱកាសទទួលបានការផ្តល់ហិរញ្ញប្បទាន ទ្រទ្រង់ដល់វិស័យស្រូវអង្ករនៅកម្ពុជា។ ជាមួយគ្នានេះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** បានមានប្រសាសន៍ សំណូមដល់សមាជិករបស់សហព័ន្ធស្រូវអង្ករទាំងអស់ត្រូវបន្តសហការគ្នាឲ្យបានល្អ និង ជិតស្និទ្ធក្នុងការបំពេញការងារលើកកម្ពស់គុណភាពអង្ករ និមិត្តសញ្ញាកម្ពុជា និងកិច្ចការជាច្រើនទៀត។



*ឯកឧត្តម ទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** និង ឯកឧត្តម **សុខ ពុទ្ធីវុធ***



*ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** ថ្លែងបិទកម្មវិធីវេទិកាស្រូវអង្ករ*

- **ក្រសួងរ៉ែនិងថាមពល៖** ក្រសួងនេះជាផ្នែកមួយ ដ៏សំខាន់ក្នុងការជួយសម្រួលការប្រើប្រាស់ថាមពលអគ្គិសនីឲ្យមានតម្លៃទាបក្នុងសង្វាក់ផលិតកម្មកិននិងកែច្នៃអង្ករ ដើម្បីធានានូវភាពប្រកួតប្រជែងលើតម្លៃថ្លៃដើម ដែលជាបន្តបន្ទាប់ ថ្នាក់ដឹកនាំក្រសួងនេះបានបន្តសន្យាជួយលើវិស័យស្រូវអង្ករកម្ពុជា។ លើសពីនេះទៀត វិស័យថាមពលគឺជាប្រធានបទចំបាច់មួយដែលត្រូវបន្តពិភាក្សារកគន្លឹះដោះស្រាយបន្តទៀត ដើម្បីឆ្លើយតបពិតប្រាកដដល់តម្រូវការរបស់សមាជិករបស់សហព័ន្ធ។ តម្លៃអគ្គិសនីខ្ពស់ បង្កឲ្យថ្លៃដើមផលិតនិងកែច្នៃអង្ករខ្ពស់ និង ប្រឈមការប្រកួតប្រជែងខ្ពស់។


រូបភាពជំនួបប្រជុំនៅទីស្ដីការក្រសួងរ៉ែនិងថាមពល

- **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖** ចាប់តាំងពីការបង្កើតសហព័ន្ធស្រូវអង្ករមក អ្វីដែលវិស័យឯកជនចង់បានបំផុតគឺ ការទទួលបានហិរញ្ញប្បទានសម្រាប់បង្កើនប្រតិបត្តិការក្នុងសង្វាក់ផលិតកម្មរបស់ខ្លួន ជាពិសេសរោងម៉ាស៊ីនចង់បានហិរញ្ញប្បទានដែលមានអត្រាការប្រាក់ទាប រួមចំណែកដល់ភាពប្រកួតប្រជែង។ ទោះបីជាលទ្ធផលមិនទាន់ទទួលបានជាដុំកំភួន ធ្វើឲ្យវិស័យឯកជនក្នុងវិស័យស្រូវអង្ករ តាមរយៈសហព័ន្ធស្រូវអង្ករ មិនទាន់សប្បាយចិត្តតែថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែងតែបង្កលក្ខណៈងាយស្រួល និង បើកទូលាយសម្រាប់ការពិភាក្សាទ្វេភាគីលើបញ្ហាប្រឈមនានា លើលទ្ធភាពទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងកញ្ចប់ណាមួយ។


រូបភាពជំនួបប្រជុំនៅទីស្ដីការគណៈរដ្ឋមន្ត្រី

- **ក្រសួងសាធារណការនិងដឹកជញ្ជូន៖**
ការដឹកជញ្ជូនជាកាតាលីករមួយដ៏សំខាន់ក្នុងការរុញច្រាន ឱកាសប្រកួតប្រជែងបានកាន់តែប្រសើរឡើងសម្រាប់វិស័យជំនួញអង្ករទៅកាន់ទីផ្សារអន្តរជាតិ។ ថ្នាក់ដឹកនាំក្រសួងសាធារណការនិងដឹកជញ្ជូន តែងបង្កលក្ខណៈងាយស្រួលដល់ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជាដើម្បីជួបពិភាក្សាជាមួយផ្នែកដែលពាក់ព័ន្ធរបស់ក្រសួង មានដូចជា កំពង់ផែភ្នំពេញ និង កំពង់ផែខេត្តព្រះសីហនុ ដែលជាច្រកដ៏សំខាន់ក្នុងការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ។ លើសពីនេះទៅទៀត ក្នុងជំនួបជាបន្តបន្ទាប់ ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជាតែងតែស្នើឡើងនូវបញ្ហាប្រឈមខ្លះពាក់ព័ន្ធវិស័យដឹកជញ្ជូន។ បើទោះបីតម្លៃនៃការដឹកជញ្ជូនមិនទាន់ចុះទាប តាមអ្វីដែលផ្នែកឯកជនចង់បាន តែមានផ្នែកខ្លះក៏អ្នកនាំចេញអង្ករកម្ពុជាដែលជាសមាជិករបស់សហព័ន្ធទទួលបានប្រយោជន៍គឺការបញ្ចុះតម្លៃលើការដឹកទំនិញអង្ករ។ សហព័ន្ធស្រូវអង្ករកម្ពុជា ជឿជាក់ថា នៅមានកិច្ចការជាច្រើនទៀតត្រូវធ្វើ ដើម្បីដោះស្រាយឲ្យបានសមស្របនិងបង្កើនការប្រកួតប្រជែងជាមួយបណ្ដាប្រទេសជិតខាង។

- **ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ៖** ក្រសួងនេះជាក្រសួងចំបងដែលសហព័ន្ធត្រូវធ្វើការងារជាមួយ តាំងពីចាប់ផ្ដើម ព្រោះមូលដ្ឋាននៃការផលិតស្រូវគឺផ្ដើមចេញពីក្រសួង ដែលធ្វើការងារផ្ទាល់ជាមួយកសិករអាជ្ញាធរមូលដ្ឋានផ្ទាល់។ ដើម្បីឆ្លើយតបតម្រូវការទីផ្សារអន្តរជាតិ ក្នុងជំហានដំបូងៗ សហព័ន្ធស្រូវអង្ករកម្ពុជា បានបង្កើនការពិភាក្សាជាមួយថ្នាក់ដឹកនាំក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ដើម្បីស្វែងយល់ពី ផលិតកម្មស្រូវ ការប្រើប្រាស់ពូជ ព្រោះពេលខ្លះការផលិតស្រូវនៅកម្ពុជាមិនទាន់ឆ្លើយតបតម្រូវការទីផ្សារអន្តរជាតិជាក់ស្ដែងនោះទេ។


រូបភាពជំនួបប្រជុំនៅទីស្ដីការក្រសួងកសិកម្ម

- **ក្រសួងឧស្សាហកម្មនិងសិប្បកម្ម៖** ក្រសួងឧស្សាហកម្មនិងសិប្បកម្មក៏នឹងដើរតួនាទីសំខាន់ ក្នុងការកំណត់គុណភាពថ្នាក់ជាតិ សម្រាប់អង្ករកម្ពុជា។ ដើម្បីឆ្លើយតបរឿងគុណភាព សហព័ន្ធស្រូវអង្ករកម្ពុជាធ្លាប់បានធ្វើសំណើរសុំជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំរបស់ក្រសួង ឧស្សាហកម្មនិងសិប្បកម្ម។

- ក្រៅពីធ្វើសវនាការជាមួយថ្នាក់ដឹកនាំក្រសួងសំខាន់ៗ ថ្នាក់ដឹកនាំរបស់សហព័ន្ធស្រូវអង្ករកម្ពុជាបានជួបពិភាក្សាការងារជាមួយស្ថាប័នជំនាញរបស់ក្រសួងមួយចំនួន ដើម្បីបង្កើនការសហការឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត៕


រូបភាពជំនួបប្រជុំនៅទីស្ដីការក្រសួងឧស្សាហកម្មនិងសិប្បកម្ម

# កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

វិស័យស្រូវអង្ករជាវិស័យមួយដែលមានការពាក់ព័ន្ធនឹងតួអង្គជាច្រើនក្នុងសង្វាក់ផលិតកម្ម ដែលរួមមានកសិករ អ្នកប្រមូលទិញស្រូវ រោងម៉ាស៊ីន អ្នកនាំចេញ ក្រុមហ៊ុនដឹកជញ្ជូន ស្ថាប័នហិរញ្ញវត្ថុ ជាដើម។ល។ ដើម្បីលើកស្ទួយវិស័យនេះអោយបានរីកចម្រើន ការពង្រឹងសង្វាក់ផលិតកម្មស្រូវអង្ករអោយបានរឹងមាំ ជាការចាំបាច់ ដែលនេះ ក៏ផ្តើមចេញផងដែរពីការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នរដ្ឋ និងដៃគូអភិវឌ្ឍន៍នានាផងដែរ។ ក្នុងនាមជាតំណាងសំលេងតែមួយគត់នៃវិស័យស្រូវអង្ករផ្នែកឯកជន សហព័ន្ធស្រូវអង្ករកម្ពុជាបានធ្វើការជាច្រើនដើម្បីពង្រឹងសហប្រតិបត្តិការនេះ តាមរយៈការជួបពិភាក្សាផ្ទាល់របស់ក្រុមប្រឹក្សាភិបាលរបស់សហព័ន្ធ ឬតាមរយៈគណៈកម្មាធិការប្រតិបត្តិជាមួយថ្នាក់ដឹកនាំនៃស្ថាប័ននីមួយៗ ក៏ដូចជាមន្ត្រីផ្នែកបច្ចេកទេសផងដែរ។

ក្នុងរយៈពេល២ឆ្នាំនៃអាណត្តិទី១នេះ យើងបានជួបពិភាក្សាជាមួយស្ថាប័នជាច្រើនទាំងរដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍សំដៅស្វែងរកកិច្ចសហការគ្នាក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងវិស័យស្រូវអង្ករ និងលើកស្ទួយវិស័យនេះអោយកាន់តែរីកចម្រើន។

សម្រាប់ការពិភាក្សាជាមួយស្ថាប័នរដ្ឋ យើងបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាណិជ្ជកម្ម ក្នុងការរៀបចំស្ថាប័នលេខាធិការដ្ឋានរបស់សហព័ន្ធ ការស្វែងរកទីផ្សារ និងលើកស្ទួយកេរ្តិ៍ឈ្មោះអង្ករកម្ពុជានៅលើឆាកអន្តរជាតិ។ យើងបានចូលរួមជាមួយក្រសួងក្នុងការផ្គូផ្គងពាណិជ្ជកម្ម ការចូលរួមពិព័រណ៌ពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស(ដូចជានៅសហរដ្ឋអាមេរិច បារាំង អាឡឺម៉ង់ អ៊ីតាលី ចិន គុយវ៉ែត ថៃ ជាដើម) និងការបង្កើតនូវម៉ាកសញ្ញារួមរបស់អង្ករកម្ពុជាជាដើម។ល។ ការលើកស្ទួយម៉ាកសញ្ញាអង្ករកម្ពុជានេះ យើងក៏បានធ្វើការសហការផងដែរជាមួយក្រសួងទេសចរណ៍ និងដៃគូអភិវឌ្ឍន៍ផងដែរ ដូចជាជាមួយ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង(AFD) អង្គការកម្មសិទ្ធបញ្ញាពិភពលោក(WIPO) ក្នុងការបង្កើតនូវពាណិជ្ជសញ្ញា ការសិក្សាលើទីផ្សារទាក់ទិននឹងការដាក់ឈ្មោះ ការរៀបចំយុទ្ធសាស្ត្រ និងបទដ្ឋានផ្សេងៗក្នុងការគ្រប់គ្រងម៉ាកសញ្ញាបន្ទាប់ពីចុះបញ្ជីរួច។

តាមរយៈការឈ្នះនូវជ័យលាភីជាអង្ករដែលល្អជាងគេបំផុតរបស់អង្ករកម្ពុជាចំនួន៣ឆ្នាំជាប់ៗគ្នា (២០១២-២០១៣-២០១៤) និងសកម្មភាពពិព័រណ៍ផ្សេងៗរបស់យើង អង្ករកម្ពុជាត្រូវបានគេស្គាល់កាន់តែច្រើនឡើងៗនៅលើឆាកអន្តរជាតិ។ នៅឆ្នាំ២០១៣ ការនាំចេញរបស់យើងសម្រេច បានប្រមាណ៣៧ម៉ឺនតោន ហើយនៅឆ្នាំ២០១៥ ការនាំចេញបានកើនឡើងទៅដល់ ៥៣ម៉ឺនតោន។ ជាមួយគ្នានេះ សម្រាប់ការកែច្នៃ យើងក៏បានពង្រីកផងដែរនូវសមត្ថភាពកិននិងប៉ូលារបស់រោងម៉ាស៊ីនយើងកាន់តែខ្លាំង (សមត្ថភាពកិនសរុប ជាង៧០០តោនស្រូវក្នុងមួយម៉ោង និងប៉ូលា ជាង៥០០តោនក្នុងមួយម៉ោង)។ សមិទ្ធផលនេះ អាចសម្រេចទៅបានដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយស្ថាបន័រដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានាផងដែរ។

ជាមួយនឹងការស្វែងរកទីផ្សារ និងការពង្រីកសមត្ថភាពកែច្នៃ យើងក៏បានពង្រឹងផងដែរនូវការប្រកួតប្រជែងថ្លៃដើមរបស់អង្ករកម្ពុជា តាមរយៈការធ្វើការជាមួយក្រសួងមន្ទីរនិងស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងសាធារណៈការនិងដឹកជញ្ជូន កំពង់ផែក្រុងព្រះសីហនុ កំពង់ផែភ្នំពេញ អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ អគ្គនាយកដ្ឋានកសិកម្ម វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាដើម។ ជាលទ្ធផល យើងបានទទួលការបញ្ចុះថ្លៃលើកដាក់ ការបញ្ចុះថ្លៃកុងធីណឺរ ការបញ្ចុះថ្លៃភ្លើងអគ្គិសនី ការលើកពន្ធលើតម្លៃបន្ថែម។ល។ តាមរយៈក្រុមការងារទី៩ទាក់ទងនឹងវិស័យស្រូវអង្ករ យើងនឹងបន្តការស្នើសុំការគាំទ្រពីរាជរដ្ឋាភិបាល បន្ថែមទៀតក្នុងការជំរុញវិស័យស្រូវអង្កររបស់យើងអោយកាន់តែមានភាពប្រកួតប្រជែង និងឈានមុខ។

ជាមួយដៃគូអភិវឌ្ឍន៍ សហព័ន្ធកាន់តែមានពង្រឹងតួនាទីរបស់ខ្លួនក្នុងការធ្វើជាដៃគូដ៏មានសក្តានុពល។ យើងបានជួបពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ដែលធ្វើការទាក់ទងនឹងវិស័យស្រូវអង្ករ ហើយស្វែងយល់ពីគម្រោងនីមួយៗ និងក៏បានស្នើសុំដៃគូអភិវឌ្ឍន៍ទាំងអស់នោះក្នុងការបង្កើតនូវគណៈកម្មាធិការផ្តល់យោបល់មួយ ដើម្បីងាយស្រួលទទួលបាននូវមតិយោបល់ និងកិច្ចសហប្រតិបត្តិការផ្សេងៗ ពីរាល់គម្រោងនានា ដែលបាននិងកំពុងអនុវត្ត មកដល់សហព័ន្ធ ដើម្បីបង្កើនប្រសិទ្ធផលនៃគម្រោងទាំងនោះ ទៅដល់សមាជិក និងវិស័យស្រូវអង្ករទាំងមូល។

IFC International Finance Corporation World Bank Group

afd AGENCE FRANÇAISE DE DÉVELOPPEMENT

WIPO WORLD INTELLECTUAL PROPERTY ORGANIZATION

# កិច្ចសហការ និងការយកចិត្តទុកដាក់ចំពោះសមាជិក

សមាជិកទាំងអស់នៃសហព័ន្ធស្រូវអង្ករកម្ពុជា សុទ្ធតែមានតួនាទីសំខាន់មិនអាចខ្វះបានក្នុងសង្វាក់ផលិតកម្ម រាប់ចាប់ពីការផលិតគឺការដាំដុះ ការកែច្នៃ រហូតដល់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។ ការផ្តួចផ្តើមគំនិតចងក្រងសហព័ន្ធនេះឡើង គឺកើតឡើងដោយសារសារៈសំខាន់នៃសមាជិកនីមួយៗនៅមូលដ្ឋាន។

ក្រោយការបដិសន្ធិសហព័ន្ធស្រូវអង្ករកម្ពុជា កាលពីខែឧសភាឆ្នាំ២០១៤ ដោយកើតចេញពីការបោះឆ្នោតយ៉ាងសេរី សម្ងាត់ និង ផ្តល់លទ្ធផលគួរជាទីទុកចិត្ត ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា បានចាប់ផ្តើមចូលខ្លួនមកបម្រើវិស័យកសិកម្ម ផ្តោតលើស្រូវអង្ករ ដែលកន្លងមក គ្មានតំណាងផ្លូវការណាមួយ បំពេញការងារដោយភាពឯករាជ្យសម្រាប់ ធ្វើការងារផ្ទាល់ ចម្រុះ និង ក្តោបលើវិស័យទាំងមូលនោះទេ។

កិច្ចសហប្រតិបត្តិការជាមួយសមាជិក គឺជាករណីកិច្ចចាំបាច់ និង ជាកិច្ចការស្នូលមួយដើម្បីធានានូវការរួបរួមគ្នាកាន់តែល្អប្រសើរនិងស្អិតរមួត ព្រមទាំងការយោគយល់គ្នាកាន់តែច្រើនក្នុងចំណោមថ្នាក់ដឹកនាំ និង សមាជិកថ្នាក់មូលដ្ឋាន ដើម្បីស្វែងរកដំណោះស្រាយដល់ស្ថាប័នឯកជនដ៏ធំមួយនេះ។

ក្នុងចំណោមសមាជិកស្ថាបនិករបស់សហព័ន្ធស្រូវអង្ករកម្ពុជាទាំង ២១៣រូប ដែលមានតំណាងមកពី សហគមន៍កសិករ សមាគមរោងម៉ាស៊ីនកិនស្រូវនានា ក្រុមហ៊ុននាំចេញអង្ករ ក្រុមហ៊ុនដឹកជញ្ជូន វិស័យហិរញ្ញវត្ថុ ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះសមាជិកគ្រប់រូប។ ក្នុងអាណត្តិទី១ នេះ សមាជិករបស់សហព័ន្ធបានកើនឡើងជា៣០ក្រុមហ៊ុន សហគមន៍កសិកម្ម ដែលធ្វើឲ្យចំនួនសមាជិករបស់សហព័ន្ធកើនដល់ **២៤៨នាក់**។

ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា ដឹកនាំដោយ ឯកឧត្តម **សុខ ពុទ្ធិវុធ** បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងបង្រួបបង្រួមអ្នកប្រកបរបរ ក្នុងវិស័យស្រូវអង្ករដើម្បីកសាងស្ថាប័នឯកជនមួយនេះ ឲ្យមានភាពរឹងមាំ សាមគ្គីភាពផ្ទៃក្នុងនិងធ្វើការងារប្រកបដោយប្រសិទ្ធភាព ឈានឆ្ពោះទៅរកការប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ ប្រកបដោយថាមភាពនិងឆ្លើយតបទៅលើតម្រូវការរបស់សមាជិករបស់សហព័ន្ធដែលតែងតែខិតខំប្រឹងប្រែងក្នុងការធ្វើការងារនូវមូលដ្ឋាន ក៏ដូចជាអន្តរជាតិ ដើម្បីលើកកម្ពស់កិត្តិយសស្រូវ អង្ករ ដែល កើតចេញពីញើសឈាមរបស់ប្រជាកសិករខ្មែរ ហើយត្រូវបានគេប្រសិទ្ធនាមថាជា «**មាសស**» នាពេលបច្ចុប្បន្ន។



*រូបភាពប្រធានសហព័ន្ធពេលចុះទៅសំណេះសំណាលជាមួយសមាជិក*

ក្នុងអាណត្តិទីមួយនេះ ថ្វីបើសហព័ន្ធមិនទាន់ធ្វើការងារបានប្រកបដោយប្រសិទ្ធភាពឆ្លើយតបទៅនឹងតម្រូវការរបស់សមាជិកជាពិសេសប្រជាកសិករនៅតាមសហគមន៍ តែពិតណាស់ សហព័ន្ធបានបំពេញកិច្ចការជាច្រើនតាមរយៈលេខាធិការដ្ឋានរបស់ខ្លួន ដែលបានបង្កើនឡើងដោយការសម្រេចរបស់ក្រុមប្រឹក្សាភិបាលរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ហើយ ជាបន្តបន្ទាប់កិច្ចការជាច្រើនគឺទទួលបានការគាំទ្រពីស្ថាប័នពាក់ព័ន្ធ។ *(សូមមើលសមិទ្ធផលនានាតាមផ្នែករបស់គណៈកម្មាធិការប្រតិបត្តិទាំង៥)*

ចាប់តាំងពីទទួលបានការទុកចិត្តពីសមាជិក តាមរយៈការបោះឆ្នោតនៅថ្ងៃទី១៩ខែឧសភា ឆ្នាំ២០១៤ ប្រធាននិងអនុប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាលចំនួន១៧រូប បានមើលឃើញនូវតម្លៃនៃការរួបរួមគ្នា និងធ្វើការងារជាមួយគ្នាដើម្បីឲ្យមានភាពប្រសើរឡើង ស្វែងរកដំណោះស្រាយឲ្យសមាជិករបស់ខ្លួនដើម្បីកាត់បន្ថយថ្លៃដើម បង្កើនភាពប្រកួតប្រជែង។

ជានិច្ចជាកាល ថ្នាក់ដឹកនាំសហព័ន្ធ តែងតែចាត់ទុករោងម៉ាស៊ីនកិនស្រូវ និង សហគមន៍កសិកម្មគឺជាតួអង្គដ៏សំខាន់បំផុតក្នុងការផលិតស្រូវកែច្នៃស្រូវសម្រាប់នាំចេញ។ ក្រោយពីជាប់ឆ្នោតមិនដល់ប៉ុន្មានខែផង ឯកឧត្តម **សុខ ពុទ្ធិវុធ** បានដឹកនាំអនុប្រធាន រួមមានលោក ឧកញ៉ា **គឹម សាវុធ** លោកឧកញ៉ា **ហ៊ុន ឡាក់** និង សមាជិកក្រុមប្រឹក្សាភិបាលមួយចំនួនទៀត បានចុះពិនិត្យ និងស្តាប់ព័ត៌មានទូទៅពីសមាជិកតាមបណ្តាខេត្ត។

កាលពីថ្ងៃទី៧ ខែកក្កដាឆ្នាំ២០១៤ ក្រោយការជាប់ឆ្នោតនិងការតែងតាំងជាផ្លូវការ ឯកឧត្តម សុខ ពុទ្ធិវុធ បានដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា

បានដឹកនាំថ្នាក់កណ្ដាលចុះទៅកាន់ខេត្តចំនួន ៤ គឺ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ និង ខេត្តសៀមរាប ក្នុងបំណងសំខាន់ស្វែងយល់ពីបញ្ហាប្រឈមនានា ដែលពួកគាត់កំពុងជួបប្រទះ។ គេដឹងថា ខេត្តទាំងបួននោះជាជង្រុកស្រូវដ៏សំខាន់ភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ជាមួយគ្នានេះដែរ រោងម៉ាស៊ីនកិនស្រូវ និង ក្រុមហ៊ុនកែច្នៃអង្ករក៏មានមូលដ្ឋាននៅទីទាំងខាងលើដែរ។



*រូបភាពអនុស្សាវរីយ៍ជាមួយសមាជិកទាំងបួនខេត្ត*

គ្រាន់តែក្នុងខេត្តបាត់ដំបងមួយ សមាជិករបស់សហព័ន្ធមានរហូតដល់៥ ៦ ដែលក្នុងនោះ ភាគច្រើនជារោងម៉ាស៊ីនកិនស្រូវ ហើយមួយចំនួនតូចទៀត ជាក្រុមហ៊ុននាំចេញនិងសហគមន៍កសិកម្ម។ ខេត្តដែលសហព័ន្ធស្រូវអង្ករមានសមាជិកច្រើនស្ថិតនៅភាគពាយព្យប្រទេស គឺខេត្តបន្ទាយមានជ័យ ដែលមានសមាជិកស្ថាបនិកសរុបចំនួន២៦ ដោយភាគច្រើនលើសលប់ជារោងម៉ាស៊ីនកិនស្រូវ។



*លោក **សេន រិទ្ធ** ម្ចាស់រោងម៉ាស៊ីនសេងរិទ្ធ (សមាជិក ស.អ.ក)*

ក្រៅពីទៅជួបក្នុងខេត្ត ខាងលើថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជាបានចុះទៅកាន់ខេត្តផ្សេងៗទៀត ដូចជាខេត្តកំពង់ធំ កំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង តាកែវ កំពត កំពង់ស្ពឺ ជាដើម ក្នុងបំណងពង្រឹងសាមគ្គីភាព និង លើកទឹកចិត្តដល់សមាជិកឲ្យបន្តសកម្មភាពរបស់ខ្លួន ដើម្បីលើកកម្ពស់ការកែច្នៃអង្ករនាំចេញទៅកាន់ទីផ្សារបរទេស។

ក្រៅពីការចុះជួបជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវ ឯកឧត្តម **សុខ ពុទ្ធិវុធ** និង ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករផ្សេងទៀតក៏ផ្ដោតការយកចិត្តទុកដាក់ចំពោះការចុះជួបសហគមន៍កសិកម្មនានា ដើម្បីឈ្វេងយល់ពីវិធីអនុវត្តក្នុងពេលកន្លងមក ដែលសហគមន៍កសិកម្មបានអនុវត្តជាមួយដៃគូរអភិវឌ្ឍន៍នានា។

កាលពីថ្ងៃទី២៦ខែមីនាឆ្នាំ២០១៦ ឯកឧត្តម **សុខ ពុទ្ធិវុធ** បានចុះទៅពិនិត្យផ្ទាល់ការចងក្រងសហគមន៍កសិកម្មនៅឃុំដូនពេង ស្រុកអង្គរជុំ ខេត្តសៀមរាប ជាមួយការចូលរួមរបស់ប្រជាកសិករប្រមាណ១០០នាក់។

ក្នុងឱកាសនោះ លោក បណ្ឌិត **ភខ ច័ន្ទតារារ័ត្ន** ប្រធានក្រុមការងារពិសេសរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលបានរៀបចំនៅពិធីជួបជុំគ្នាជាលើកទីមួយនេះបានអះអាងថា ការជួបជុំសហគមន៍កសិករនោះក្នុងបំណងសំខាន់លើកទឹកចិត្តកសិករក្នុងការដាំដុះ និងបង្កើនការទុកចិត្តលើការងាររបស់សហព័ន្ធស្រូវអង្ករកម្ពុជានៅថ្ងៃអនាគត។



លោក បណ្ឌិត លើកឡើងថា ក្នុងចំណោមកសិករជិត១០០នាក់នោះ មានសមាសភាពមកពី ៧ សហគមន៍កសិកម្មផ្សេងៗគ្នានៃឃុំជិតខាងគ្នា ដើម្បីចែករំលែកនូវរាល់បទពិសោធន៍ជោគជ័យក្នុងការដាំដុះ និង ការដឹកនាំសហគមន៍កសិកម្មប្រកបដោយសាមគ្គីភាព។

ក្រោយមក ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា ដឹកនាំដោយឯកឧត្តម **សុខ ពុទ្ធិវុធ** បានដឹកនាំក្រុមការងារចុះទៅពិនិត្យផ្ទាល់ការប្រមូលផលរបស់ សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត នៅស្រុកសន្ទុក ខេត្តកំពង់ធំ។


*អ្នកស្រី **រ៉ុម សារឿន** ប្រធានសហគមន៍ស្ទឹងជីនិត*

អ្នកស្រី **រ៉ុម សារឿន** ប្រធានសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត នៅស្រុកសន្ទុក ខេត្តកំពង់ធំ បានរៀបរាប់ថា សហគមន៍កសិករដែលមានសមាជិកជិត៣០០០គ្រួសារ និង មានផ្ទៃដីជាង ២៨០០ហិកតា ធ្លាប់បានរោងម៉ាស៊ីននិងក្រុមហ៊ុនធំៗទៅសហការដោយបង្កើតកិច្ចសន្យាកសិកម្ម។ ជាទូទៅ ការអនុវត្តន៍តាមកិច្ចសន្យាកសិកម្ម គឺមានភាពងាយស្រួលដល់កសិករផលិត និង ងាយរកទីផ្សារជាង។

អ្នកស្រី និយាយថា តាមរយៈកិច្ចសន្យាកសិកម្មនោះកសិករបានលក់ផលិតផលរបស់ខ្លួនក្នុងតម្លៃថ្លៃ ជាងតម្លៃដែលឈ្មួញកណ្ដាលចុះទៅទិញនិងបន្ទាបតម្លៃរបស់កសិផលកសិករ។



រហូតមកដល់ពេលនេះ សហគមន៍កសិកម្មដែលជាសមាជិករបស់សហព័ន្ធស្រូវអង្ករកម្ពុជាមានចំនួនតិចតួចនៅឡើយបើប្រៀបធៀបចំនួនសមាជិក ដែលបានចុះបញ្ជីនៅក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដែលមានប្រមាណ៧០០សហគមន៍កសិកម្ម។

សហគមន៍កសិករគឺ ជាកម្លាំងចលករដ៏សំខាន់បំផុតក្នុងការធានានូវទិន្នផលស្រូវសម្រាប់ ការកែច្នៃរបស់រោងម៉ាស៊ីននៅទូទាំងប្រទេស ដូចនេះ សហគមន៍កសិកម្មកាន់តែមានបច្ចេកទេសខ្ពស់ទិន្នផលស្រូវដែលផលិតបានក៏ខ្ពស់ ធានាបាននូវនិរន្តរភាពនៃការកែច្នៃនៅតាមរោងម៉ាស៊ីន និង ទីផ្សារសកលលោក។

ចំពោះសមាជិកដែលមិនបានចុះទៅជួបផ្ទាល់នៅរោងម៉ាស៊ីន ឬតាមសហគមន៍ លេខាធិការដ្ឋានក៏តែងរៀបចំឲ្យមានជំនួបនៅតាមខេត្តនានា ដើម្បីក្ដាប់ពីសភាពបង្កបង្កើនផល ក៏ដូចជា ដឹងពីតម្រូវការចាំបាច់ របស់សមាជិក និង ប្រជាសហគមន៍កសិករ។

ជាក់ស្ដែងណាស់ កាលពីថ្ងៃទី៤ខែឧសភាឆ្នាំ២០១៦ សហគមន៍កសិកម្មនៅតាមបណ្ដាខេត្តមួយចំនួន ត្រូវបានសហព័ន្ធស្រូវអង្ករអញ្ជើញចូលរួមក្នុងសិក្ខាសាលាមួយ ស្ដីពី ការអនុវត្ត «កិច្ចសន្យាផលិតកម្មកសិកម្ម» ដែលមានឈ្មោះជាភាសាអង់គ្លេសថា «Contract Farming»


*រូបភាពអនុស្សាវរីយ៍បន្ទាប់ពីបញ្ចប់សិក្ខាសាលា កិច្ចសន្យាផលិតកម្មកសិកម្ម*

ដែលមានម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអង្គការអភិវឌ្ឍន៍ដែលមានគម្រោងពាក់ព័ន្ធវិស័យកសិកម្មចូលរួមពិភាក្សាគ្នាស្វែងរកគន្លឹះអភិវឌ្ឍន៍។ សហគមន៍កសិកម្មដែលមកពីបណ្ដាខេត្តនានា បានមើលឃើញនូវផលប្រយោជន៍ខ្លះពីការអនុវត្តកិច្ចសន្យាកសិកម្មក្នុងពេលកន្លងមក។ ផលប្រយោជន៍ដែលសំខាន់និងធំបំផុត គឺការធានាបាននូវតម្លៃស្រូវខ្ពស់ និង មានទីផ្សារស្រាប់តែម្ដង។



*លោក **ភុយ សាម៉ន** ប្រធានសហគមន៍កសិកម្មស្រម៉ុកសុខសែនជ័យ*

ធ្វើដំណើរមកពី ឃុំពន្លៃស្រុក អង្គរបុរី ខេត្តតាកែវ លោក **ភុយ សាម៉ន** ប្រធានសហគមន៍កសិកម្មស្រម៉ុកសុខសែនជ័យ បានរៀបរាប់ថា សហគមន៍កសិកម្មរបស់លោកដែលបានប្រមូលផ្តុំកសិករជិត១០០ គ្រួសារដោយបង្កើតឡើងកាលពីឆ្នាំ២០១២ ធ្លាប់បានសហការណ៍ជាមួយរោងម៉ាស៊ីនកិនស្រូវមួយចំនួនទទួលបានជោគជ័យក្នុងមួយឆ្នាំឬពីរឆ្នាំដំបូង តែក្រោយមកកិច្ចសន្យានេះមិនទទួលបានការចាប់អារម្មណ៍ទៀតឡើយ ពេលដែលតម្លៃស្រូវធ្លាក់ចុះ។ សហគមន៍កសិកម្មដែលមានផ្ទៃដីជាង ២២០ ហិកតានេះ ចង់ឃើញការសហការនេះបន្តទៅទៀត ពីក្រុមហ៊ុននិងរោងម៉ាស៊ីនកិនស្រូវ ដើម្បីធានានូវតម្លៃនិងទីផ្សារសម្រាប់ផលិតផលស្រូវ ព្រមទាំងជាផ្នែកមួយដ៏សំខាន់នៃការលើកទឹកចិត្តកសិករឲ្យបន្តធ្វើស្រែចំការ។

លោក **ភុយ សាម៉ន** និយាយថា៖ «យើងខ្ញុំខិតខំស្កាត់មកចូលរួមក្នុងសិក្ខាសាលានេះ គោលបំណងរបស់ខ្ញុំ គឺ ចង់ទំនាក់ទំនងក្រុមហ៊ុន និង រោងម៉ាស៊ីននាំអង្ករចេញ ដើម្បីរកដំណោះស្រាយមួយទំនាក់ទំនង ដោយស្នើឲ្យក្រុមហ៊ុនចុះជួបជាមួយសហគមន៍ ក្នុងបំណងរៀបចំកិច្ចសន្យានោះឡើងវិញ»។

នៅព្រឹកថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៥ ប្រធានសហពន្ធ័ស្រូវអង្ករកម្ពុជា ឯកឧត្តម **សុខ ពុទ្ធិវុធ** បានដឹកនាំដំណើរទស្សនកិច្ចសិក្សាទៅមជ្ឈមណ្ឌលផលិតពូជស្រូវរបស់ក្រុមហ៊ុន អិលប៊ីអិន (LBN Group) នៅស្រុកស្ទោង ខេត្តកំពង់ធំ ដោយបានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់ លោកឧញ៉ា **លីម ប៊ុណា** ដែលជាប្រធាន LBN group។



*រូបភាពដំណើរទស្សនកិច្ចសិក្សាមជ្ឈមណ្ឌលផលិតពូជស្រូវរបស់ក្រុមហ៊ុន LBN Group*

សូមបញ្ជាក់ ថាមជ្ឈមណ្ឌលនេះកំពុងដំណើរការផលិតពូជស្រូវ ដើម្បីឆ្លើយតបទៅនឹង តម្រូវការទីផ្សារអង្ករកម្ពុជា ជាពិសេសឆ្លើយតបទៅនឹងគោលនយោបាយនាំចេញរបស់រាជរដ្ឋាភិបាល។

នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៦ នេះ សហព័ន្ធស្រូវអង្ករកម្ពុជា ដឹកនាំដោយ ឯកឧត្តម **សុខ ពុទ្ធិវុធ** និងសមាជិកក្រុមប្រឹក្សាភិបាល ព្រមទាំងលេខាធិការដ្ឋាន បានចុះទស្សនកិច្ច និងសំណេះសំណាលនៅមូលដ្ឋានដាំដុះស្រូវបែបផែនធម្មជាតិរបស់ក្រុមហ៊ុន អេង ឌីប៉ូ អភិវឌ្ឍន៍ ជាសមាជិកថ្មីរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ដែលមានផ្ទៃដីដាំដុះជាង ១,៦៩០ហិកតា នៅឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល។
ឯកឧត្តមប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា មានការកោតសរសើរចំពោះគំនិតផ្តួចផ្តើមអភិវឌ្ឍន៍វិស័យកសិកកម្ម ជាពិសេសដំណាំស្រូវក្រអូបនៅក្នុងរដូវប្រាំង ដោយមានប្រព័ន្ធគ្រប់គ្រងទឹកច្បាស់លាស់ ដើម្បីទទួលបានទិន្នផលខ្ពស់បន្ថែមទៀត។
ក្នុងឱកាសនោះ តំណាងក្រុមហ៊ុន អេង ឌីប៉ូ អភិវឌ្ឍន៍ បានបញ្ជាក់ថា ទោះបីទើបតែជាសមាជិកថ្មីរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ប៉ុន្តែក្រុមហ៊ុននឹងសហការគាំទ្រយ៉ាងជិតស្និទ្ធ ដើម្បីខិតខំលើកស្ទួយវិស័យស្រូវអង្ករ និងលើកស្ទួយសេដ្ឋកិច្ចកម្ពុជា។ លោកបានបន្ថែមទៀតថា នេះជាគម្រោងទី១ ដោយក្រុមហ៊ុននឹងមានគម្រោងទី២ទៀត ដែលមានផ្ទៃដីជាង ១0,000ហិចតា៕





*រូបភាពដំណើរទស្សនកិច្ចមូលដ្ឋានដាំដុះស្រូវបែបផែនធម្មជាតិរបស់ក្រុមហ៊ុន អេង ឌីប៉ូ អភិវឌ្ឍន៍ ដែលជាសមាជិកថ្មីរបស់សហព័ន្ធ*

# ព្រឹត្តិការណ៍ធំៗដែលសហព័ន្ធស្រូវអង្ករកម្ពុជាបានរៀបចំ

ក្រោយពីការរួបរួមគ្នាបង្កើតសហព័ន្ធស្រូវអង្ករជាផ្លូវការ ដោយមានសមាសភាពមកពីគ្រប់ភាគី សហព័ន្ធស្រូវអង្ករកម្ពុជា បានរៀបចំព្រឹត្តិការណ៍ធំៗជាច្រើន ដើម្បីលើកកម្ពស់វិស័យស្រូវអង្ករនៅកម្ពុជា ឲ្យមានការទទួលស្គាល់ទូលំទូលាយ ទាំងតម្លៃនិងគុណភាព។

កាលពីឆ្នាំ២០១៤ សហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមរៀបចំនិងបង្កើតពិធីបុណ្យអង្ករលើកទី២បន្ទាប់ពីការប្រារព្ធលើកទី១ ប្រកបដោយភាពជោគជ័យ នៅខេត្តសៀមរាប ដោយមានការឧបត្ថម្ភពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលស្ថិតក្រោមគម្រោងជួយវិស័យស្រូវអង្ករ។ តាមរយៈព្រឹត្តិការណ៍នោះ កម្ពុជាអ្នកជំនាញក្នុងវិស័យស្រូវអង្ករ ក៏កាន់តែមានជំនាញក្នុងការជ្រើសរើសអង្ករប្រកបដោយគុណភាព សម្រាប់ការប្រកួតប្រជែងគុណភាពអង្ករលើឆាកអន្តរជាតិ។

## ព្រឹត្តិការណ៍អន្តរជាតិនៅកម្ពុជា

ក្នុងឆ្នាំជាមួយគ្នានៃការរួបរួមគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធក្នុងវិស័យស្រូវអង្ករទាំងអស់ សហព័ន្ធស្រូវអង្ករកម្ពុជា បានសហការជាមួយស្ថាប័នពាក់ពាក់ព័ន្ធជាច្រើនទៀតនៅក្រៅប្រទេស ជាពិសេសក្រសួងពាណិជ្ជកម្ម និង ក្រុមហ៊ុនឯកជនធំដាប់ពិភពលោក មួយឈ្មោះ The Rice Trader មានមូលដ្ឋាននៅរដ្ឋកាលីហ្វ័រនីញ៉ានៃសហរដ្ឋអាមេរិក បានរៀបចំព្រឹត្តិការណ៍ សប្តាហ៍អង្ករ «Rice Week» ដោយរួមមានព្រឹត្តិការណ៍ធំៗពាក់ព័ន្ធវិស័យស្រូវអង្ករ ដូចជា ពិធីបុណ្យអង្ករ វេទិកាស្រូវអង្ករប្រចាំឆ្នាំ និង សន្និសិទពិភពលោកស្តីពីស្រូវអង្ករលើកទីមួយនៅកម្ពុជា ដែលមានភ្ញៀវជាតិនិងអន្តរជាតិមកពីជុំវិញពិភពលោកចូលរួមប្រមាណជាច្រើនពាន់នាក់។




សន្និសីទពិភពលោកស្តីពីស្រូវអង្ករដែលមានក្រុមហ៊ុនឯកជនមួយឈ្មោះ The Rice Traders មានមូលដ្ឋាននៅរដ្ឋកាលីហ្វ័រនីញ៉ានៃសហរដ្ឋអាមេរិក បានកៀងគរក្រុមហ៊ុនផ្គត់ផ្គង់អង្ករលំដាប់ពិភពលោករាប់រយក្រុមហ៊ុន មកកាន់ទឹកដីកម្ពុជាដើម្បីសិក្សាពីឱកាសវិនិយោគ និង សង្វាក់ផលិតកម្មនៅកម្ពុជា។

តាមរយៈព្រឹត្តិការណ៍សន្និសីទនោះ អ្វីដែលគេទន្ទឹងរង់ចាំអ៊ុតលទ្ធផលយ៉ាងអន្ទះសារបំផុតនោះគឺ លទ្ធផលនៃការប្រកួតគុណភាពអង្ករពិភពលោក ដែលតែងតែរៀបចំឡើងក្នុងមួយឆ្នាំ១ដង។




សន្និសីទស្រូវអង្ករអន្តរជាតិ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនេះ បានកើតឡើងក្រោយព្រឹត្តិការណ៍កីឡាបាល់ទាត់ពិភពលោក (World Cup) តែបីទៅបួនខែប៉ុណ្ណោះ ហើយ អ្នកប្រកបអាជីវកម្មក្នុងវិស័យស្រូវអង្ករខ្លះបាននិយាយបែបកំប្លែងលាយការពិតខ្លះថា « កម្ពុជាមិនត្រូវធ្វើដូចជាប្រទេសប្រេស៊ីលនោះទេ ធ្វើជាម្ចាស់ផ្ទះនៃព្រឹត្តិការណ៍បាល់ទាត់ តែត្រូវគេយកពានទៅបាត់»។

មិនខកចិត្តនោះទេសម្រាប់អង្ករកម្ពុជា។ ជាលទ្ធផល អង្ករកម្ពុជាពិតជាមានគុណភាពខ្ពស់រហូតទទួលបានចំណាត់ថ្នាក់លេខ១ ជាអង្ករល្អផ្តាច់គេក្នុងពិភពលោកក្នុងព្រឹត្តិការណ៍ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។
តាមរយៈចំណាត់ថ្នាក់នេះ អង្ករកម្ពុជាបានទទួលចំណាត់ថ្នាក់ជា អង្ករឆ្ងាញ់ផ្តាច់គេក្នុងពិភពលោករយៈពេលបីឆ្នាំជាប់គ្នា គឺ ជាប់ចំណាត់ថ្នាក់លេខ១ កាលពីឆ្នាំ២០១២ នៅការប្រកួតប្រជែងនៅកោះបាលីក្នុងប្រទេសឥណ្ឌូនេស៊ី នៅឆ្នាំ២០១៣ នៅទីក្រុងហុងកុង ហើយនៅឆ្នាំ២០១៤ គឺប្រទេសកម្ពុជាខ្លួនឯងតែម្តង។



## ព្រឹត្តិការណ៍ជាតិចុងក្រោយ ដែលសហព័ន្ធស្រូវអង្ករៀបចំ



***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រគល់ពានកិត្តិយសដល់ ឯកឧត្តម **សុខ ពុទ្ធិវុធ***

ព្រឹត្តិការណ៍រៀបចំវេទិកាស្រូវអង្ករលើកទី៥រយៈពេលពីរថ្ងៃ ២៥-២៦ ខែមករាឆ្នាំ២០១៦ កន្លងទៅនេះ ដោយសហការរៀបចំឡើងដោយសហព័ន្ធស្រូវអង្ករកម្ពុជា និង សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា ដោយមានវត្តមានដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គ - មហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

អ្នកពាក់ព័ន្ធនៅក្នុងវិស័យស្រូវអង្ករប្រមាណ ៧០០ នាក់ ដោយក្នុងនោះ មានតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ សហគមន៍កសិកម្ម ក្រុមហ៊ុននាំចេញអង្ករ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនដឹកជញ្ជូន តំណាងដៃគូអភិវឌ្ឍន៍ និស្សិតភ្ញៀវជាតិ និងអន្តរជាតិ បានចូលរួមវេទិកាស្រូវអង្ករកម្ពុជាលើកទី៥នេះ ដើម្បីទទួលព័ត៌មាន និង ពិភាក្សាលើបញ្ហាក្នុងវិស័យស្រូវអង្ករ។

វេទិកាស្រូវអង្ករប្រចាំឆ្នាំលើកទី៥នេះ ហាក់បានដើរតួនាទីសំខាន់បំផុត ព្រោះសម្តេចប្រមុខរាជរដ្ឋាភិបាល បានប្រើប្រាស់វេទិកាមួយនេះ ត្រួត-ពិនិត្យ និងវាយតម្លៃឡើងវិញនូវគោលនយោបាយស្រូវអង្ករបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញកាលពីឆ្នាំ២០១០ គឺរយៈពេល៥ឆ្នាំនៃការដាក់ចេញឲ្យអនុវត្តគោលនយោបាយមួយនេះ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងសន្ទរកថាគន្លឹះបើកវេទិកាស្រូវអង្ករប្រចាំឆ្នាំនេះ ដោយបានគូសបញ្ជាក់នូវ បញ្ហាប្រឈមជាច្រើន ដែលកម្ពុជាកំពុងជួបប្រទះមួយចំនួន តែជាទូទៅគោលនយោបាយស្រូវអង្ករទទួលបានជោគជ័យខ្លាំងផ្អែកលើផលិតកម្មស្រូវ សមត្ថភាពកែច្នៃអង្ករនាំចេញជាដើម។

សម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ថា គោលនយោបាយជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករដែលរាជរដ្ឋាភិបាលបានប្រកាសដាក់ចេញកាលពីឆ្នាំ២០១០ ដោយមានគោលដៅធំពីរ គឺ ទី១ ជំរុញការផលិតស្រូវឲ្យបានច្រើនជាង៤លានតោន ដោយក្នុងនោះ បរិមាណអង្ករសម្រាប់នាំចេញ ត្រូវសម្រេចឲ្យបានយ៉ាងតិចមួយលានតោន និង ទី២ លើកកេរ្តិ៍ឈ្មោះអង្ករ កម្ពុជានៅលើឆាកអន្តរជាតិ។

សម្តេច **ហ៊ុន សែន** បានអះអាងថា « យើងសម្រេចគោលដៅទី២ នេះ យ៉ាងត្រចះត្រចង់ ដោយកម្ពុជាបាននាំអង្ករទៅកាន់ទីផ្សារនានានៅលើពិភពលោក ជាង៦០ប្រទេស។ ជាមួយគ្នានេះ អង្ករកម្ពុជាត្រូវបានជាប់ចំណាត់ថ្នាក់ អង្ករឆ្ងាញ់បំផុតនៅលើពិភពលោកជាបន្តបន្ទាប់។ ចំណែក គោលដៅទី១ យើងសម្រេចបានប្រមាណពាក់កណ្តាល។ បរិមាណអតិរេកស្រូវ បានកើនពី៣.៥លានតោនក្នុងឆ្នាំ២០០៩ មកដល់ ៤.៧លានតោន នៅឆ្នាំ២០១៥។ ចំណែកគោលដៅនាំចេញ កម្ពុជាសម្រេចបាន ពាក់កណ្តាល ដោយនាំចេញអង្ករជាង៥៣ម៉ឺនតោននៅឆ្នាំ២០១៥ នៃគោលដៅ១លានតោន»។

សម្តេច **ហ៊ុន សែន** បានបញ្ជាក់ថា៖ «សរុបមក យើងអាចសម្រេចបានជាង ៨៧,៥០%នៃគោលដៅ ដែលយើងបានដាក់ចេញ ដែល

អាចចាត់ទុកថា ជាលទ្ធផលល្អប្រសើរគួរជាទីមោទនៈ»។

តាមការអះអាងរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី មានកត្តាពីរយ៉ាងដែលបណ្តាលឲ្យគោលនយោបាយស្រូវអង្ករមិនទទួលបានជោគជ័យ១០០% តាមមហិច្ឆតារបស់គោលដៅដែលបានដាក់ចេញ។ កត្តាទាំងពីរនោះគឺ កត្តាអត្តនោម័ត ដែលសំដៅលើកត្តាផ្ទៃក្នុង និង កត្តាសត្យានុម័ត ដែលសំដៅលើឥទ្ធិពលពីខាងក្រៅ។

សម្តេចតេជោ **ហ៊ុន សែន** បានគូសបញ្ជាក់ថា កត្តាអត្តនោម័ត ដោយសារកម្ពុជាមិនទាន់អាចដោះស្រាយបានគ្រប់គ្រាន់នៅឡើយលើបញ្ហាប្រឈមមួយចំនួន ដូចជាបញ្ហាការផ្គត់ផ្គង់ទឹក ការប្រើប្រាស់ពូជសុទ្ធ បច្ចេកទេសបន្សុទ្ធពូជ បច្ចេកទេសកសិកម្មទំនើប កង្វះទុនបង្វិល ឃ្លាំងស្តុក និងទីផ្សារ។ល។ ដែលធ្វើឲ្យបរិមាណស្រូវមួយចំនួនត្រូវនាំចេញទៅកាន់ប្រទេសជិតខាង មុនការកែច្នៃនៅកម្ពុជា។

សម្តេច **ហ៊ុន សែន** បានបន្ថែមថា កត្តាសត្យានុម័តវិញ គឺប្រទេសនានាទាំងក្នុងតំបន់និងក្នុងពិភពលោក ក៏ជាប្រទេសផលិតស្រូវដូចកម្ពុជាដែរជាពិសេសបណ្តាប្រទេសនៅក្នុងតំបន់ទន្លេមេគង្គ មាន វៀតណាម ថៃ ឡាវ និង មីយ៉ាន់ម៉ា។
ការបញ្ចេញផលិតផលនៃប្រទេសទាំងនោះបាននាំឲ្យទីផ្សារអង្កររបស់ពិភពលោកចុះខ្សោយ ហើយ អង្ករកម្ពុជាក៏ធ្លាក់ថយដូចគ្នា។

សម្តេច **ហ៊ុន សែន** លើកទឹកចិត្តថា៖« ទន្ទឹមនឹងសមិទ្ធិផលដែលសម្រេចបាននៅពេលនេះ កិច្ចការសំខាន់ដែលកម្ពុជាត្រូវបន្តគឺរក្សាលទ្ធផលដែលយើងសម្រេចបាន ជាមួយនឹងការខិតខំស្វែងរក វិធីសាស្ត្រ និង សកម្មភាពបន្ថែមទៀត ដើម្បីជំរុញការងារផលិតកម្មស្រូវ និងការនាំចេញអង្កររបស់កម្ពុជា ជាពិសេសក្នុងបរិយាកាសនៃការវិវត្តយ៉ាងលឿន នៃស្ថានភាពសកលលោកនាពេលបច្ចុប្បន្ននេះ»។

ក្នុងឱកាសនោះ សម្តេចតេជោ **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាល បានកោតសរសើរចំពោះ ក្រសួងបី និង ស្ថាប័នឯកជនមួយ ដែលខិតខំប្រឹងប្រែងក្នុងការអនុវត្តគោលនយោបាយស្រូវអង្ករដែលបានដាក់ចេញ តាមរយៈការងារបង្កើនផលិតកម្មស្រូវ និង ជំរុញការនាំចេញ។ ក្រសួងបីនិងស្ថាប័នឯកជននោះរួមមានៈ
1.ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ ដែលជាផ្នែកផលិតកម្មស្រូវ
2.ក្រសួងពាណិជ្ជកម្ម ដែលជាផ្នែកនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ
3.ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាផ្នែកផ្តល់ហិរញ្ញប្បទាន
4.សហព័ន្ធស្រូវអង្ករកម្ពុជា ជាផ្នែកដែលជំរុញការទទួលស្គាល់ជាអន្តរជាតិ៕



***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** *កំពុងទស្សនាស្តង់ពិព័ណ៌របស់សហព័ន្ធស្រូវអង្ករកម្ពុជា*

## គម្រោងកំណត់ទីតាំងភូមិសាស្ត្រ និង ណែនាំបច្ចេកវិទ្យាថ្មីៗ

ក្នុងអាណត្តិទីមួយនេះ សហព័ន្ធស្រូវអង្ករកម្ពុជាបានអនុវត្តនូវការងារស្នូលជាច្រើនលើវិស័យស្រូវអង្ករដូចជា ការរកយុទ្ធសាស្ត្របង្កើនការនាំចេញអង្ករទៅទីផ្សារអន្តរជាតិ ការកាត់បន្ថយថ្លៃដើម ការទប់ស្កាត់ការនាំអង្ករចូលពីបរទេស ការចុះបញ្ជីម៉ាកអង្ករជាដើម។ ក្នុងចំណោមការងារអាទិភាពខាងលើ សហព័ន្ធក៏បានធ្វើការលើផ្នែកផែនទី និងភូមិសាស្ត្រ និងការស្រាវជ្រាវរកបច្ចេកទេសថ្មីៗដើម្បីរួមចំណែកកាន់តែងាយយល់ ងាយចងចាំ លើវិស័យកសិកម្មបន្ថែមទៀត ដើម្បីជួយជំរុញ និងពង្រឹងការគ្រប់គ្រងកសិកម្មឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ នៅចុងអាណត្តិទីមួយនេះ សហព័ន្ធកំពុងសិក្សានិងសាកល្បងប្រើប្រាស់កម្មវិធី Sirrus និង SST Submit នៅក្នុងកសិដ្ឋាន និងជាមួយសហគមន៍ផលិតពូជនានាដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងកសិកម្មបែបទំនើប។

### ផលប្រយោជន៍នៃបច្ចេកវិទ្យាដោយប្រើប្រាស់កម្មវិធី Sirrus និង SST Submit

- កម្មវិធី Sirrus គឺជាកម្មវិធីមួយសំរាប់វិស័យកសិកម្ម ដែលមានមុខងារវាស់វែងទំហំដី ការកត់ត្រាទុកនូវព័ត៌មានពីសត្វល្អិតបំផ្លាញ ការគ្រប់គ្រងដំណាំ និងការដាក់ជី និងការធ្វើសំណាកដី -ល- ដោយប្រើប្រាស់ប្រព័ន្ធ GPS សំរាប់ភ្ជាប់ទីតាំងនៃការអនុវត្តន៍ជាក់ស្តែង ដើម្បីបង្ហាញដល់អ្នកជំនាញ ឬកសិករពីទីតាំងដែលបានអនុវត្ត ឬកើតមានឡើងកន្លងមក។
- កម្មវីធី SST Submit គឺជាកម្មវិធីគ្រឹះមួយក្នុងការទាញយកទិន្នន័យពីកម្មវិធី Sirrus សម្រាប់វិភាគអំពីបញ្ហា និងកែតម្រូវរាល់ទីតាំងដែលជួបប្រទះនូវបញ្ហានានាដូចជា កង្វះដី សារធាតុចិញ្ចឹមផ្សេងៗ សត្វល្អិតបំផ្លាញ និងកម្រិតជាតិអាស៊ីតក្នុងដី( p H ) ជាដើមដែលកត្តាទាំងអស់នេះសុទ្ធតែជះឥទ្ធិផលលើទិន្នផលនៃដំណាំ។ កម្មវិធី SST Submit នេះនឹងបំលែងទិន្នន័យដែលបានវិភាគរួច ទៅប្រើប្រាស់ជាមួយត្រាក់ទ័រ ឬគ្រឿងចក្រកសិកម្មផ្សេងទៀត ដែលភ្ជាប់ដោយប្រព័ន្ធ GPS និង Controller ក្នុងការបាញ់នូវសារធាតុចិញ្ចឹម ឬ ថ្នាំសំលាប់សត្វល្អិតនានាទៅតាមចំណុះ ទីតាំងជាក់ស្តែង និងស្ថានភាពដែលតំបន់នោះត្រូវការ។

កម្មវីធីទាំងពីរនេះពិតជាជួយឱ្យការអនុវត្តន៍ និងការគ្រប់គ្រងកសិដ្ឋាន ឬកសិកម្មកាន់តែមានប្រសិទ្ធភាពខ្ពស់ ហើយក៏ជាចំណែកមួយនៃការធ្វើទំនើបកម្មកសិកម្មនៅកម្ពុជាផងដែរ។

### គិតត្រឹមខែមេសា ឆ្នាំ២០១៦នេះ សហព័ន្ធស្រូវអង្ករកម្ពុជាបានធ្វើនូវការងារមួយចំនួនរួមមាន៖

- បណ្តុះបណ្តាលនិស្សិត និងយុវជនអំពីរបៀបនៃការគូសផែនទីដូចជា ផែនទីសហគមន៍ ផែនក្បាលដីស្រែរបស់ប្រជាកសិករ ក្នុងគោលបំណងកំណត់អោយបានច្បាស់ពីទីតាំង ទំហំ និងម្ចាស់ដីស្រែនីមួយៗ
- បណ្តុះបណ្តាលនិស្សិត និងយុវជនអំពីការប្រើប្រាស់កម្មវិធី Surris និងកម្មវិធី SST Submit និងគុណប្រយោជន៍នៃការដាក់បញ្ចូលប្រព័ន្ធបច្ចេកវិទ្យាក្នុងវិស័យកសិកម្ម ក្នុងគោលបំណងសម្រួលដល់ការគ្រប់គ្រងព័ត៌មាន និងបង្កើននូវប្រសិទ្ធភាព ក៏ដូចជាការបន្ថយនូវពេលវេលាអនុវត្ត
- ផលិតនូវផែនទីមួយចំនួនដូចជា ទីតាំងរោងម៉ាស៊ីន សមត្ថភាពកិនរបស់រោងម៉ាស៊ីន និងទីតាំងសហគមន៍ផលិតពូជស្រូវនៅទូទាំងប្រទេស
- បន្តស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្ស ព្រមទាំងផ្សព្វផ្សាយបច្ចេកវិទ្យាថ្មីៗលើវិស័យកសិកម្ម ដើម្បីរួមចំណែកក្នុងការសម្រួល និងធ្វើទំនើបបនីយកម្មកសិកម្មរបស់កម្ពុជា ដូចជាការប្រើប្រាស់ GPS ជាមួយត្រាក់ទ័រ និងប្រព័ន្ធផ្កាយរណបជាដើមជារួម សហព័ន្ធស្រូវអង្ករកម្ពុជានឹងបន្តសិក្សាស្រាវជ្រាវលើការងារផែនទី និងភូមិសាស្ត្របន្តទៀតដើម្បីជួយជំរុញ និងដាក់បញ្ចូលប្រព័ន្ធបច្ចេកទេសទំនើបលើវិស័យកសិកម្ម និងតាមដាននូវបម្រែបម្រួលនៃផ្ទៃដីកសិកម្ម ជាពិសេសផ្ទៃដីដែលមប្រើឱ្យដំណាំស្រូវបន្តទៀត ខណៈកំណើនសេដ្ឋកិច្ច កំណើនប្រជាជន និងបម្រែបម្រួលអាកាសធាតុបាននឹងកំពុងជះឥទ្ធិពលដល់ការថយចុះនៃផ្ទៃដីកសិកម្មនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងអនាគត៕

*(រូបភាពខាងក្រោមនេះ ជាការលទ្ធផលដែលក្រុមការងាររបស់សហព័ន្ធរៀបចំឡើង ដោយប្រើប្រាស់បច្ចេកវិទ្យានៃ កម្មវិធី Sirrus និង SST Submit)*









## ការបែងចែកការគ្រប់គ្រងតាមតំបន់ធំៗទាំងប្រាំ ( 5 Zones )

### សហព័ន្ធស្រូវអង្ករកម្ពុជា
### ( សេចក្តីព្រាង )
### ស្តីពី
### ការបង្កើតរចនាសម្ព័ន្ធ តំបន់ទាំង៥

**១. សេចក្តីផ្តើម៖**

សហព័ន្ធស្រូវអង្ករកម្ពុជា ត្រូវបានបង្កើតឡើង ដោយសមាជិកស្ថាបនិកចំនួន ២១៣រូប ដែលតំណាងឲ្យសហព័ន្ធអ្នកនាំចេញអង្ករ សហព័ន្ធកសិករ សមាគមរោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនដឹកជញ្ជូន។ រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់សហព័ន្ធស្រូវអង្ករកម្ពុជាជាដៃគូតែមួយគត់សម្រាប់ការពិភាក្សាគោលនយោបាយ ជាអ្នកតំណាងលើវិស័យមួយដើម្បីលើកកម្ពស់វិស័យអង្ករក្នុងឆាកជាតិ និងអន្តរជាតិ។

សហព័ន្ធស្រូវអង្ករកម្ពុជាមានតួនាទីដ៏សំខាន់គឺផ្តល់ការគាំទ្រគ្រប់ទិដ្ឋភាពទាំងអស់ ដោយរួមបញ្ចូលទាំងគោលនយោបាយច្បាប់ និងការអនុវត្តន៍ដល់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងខ្សែចង្វាក់ផលិតកម្មស្រូវ ដើម្បីបង្កើននូវភាពប្រកួតប្រជែងរបស់ខ្លួនក្នុងការផលិត និងផ្គត់ផ្គង់អង្ករប្រកបដោយគុណភាពទៅកាន់ទីផ្សារក្នុងស្រុក និងអន្តរជាតិ។

**២. វិសាលភាព៖**

នាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ សហព័ន្ធស្រូវអង្ករកម្ពុជាបានរៀបចំដំណើរការកិច្ចប្រជុំភិបាលដឹកនាំដោយប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា។ កិច្ចប្រជុំបានផ្តោតការពិភាក្សាលើការបែងចែកតំបន់ការងារ និងការទទួលខុសត្រូវរបស់ថ្នាក់តំបន់។ សហព័ន្ធស្រូវអង្ករកម្ពុជា បានកំណត់បែងចែកតំបន់គោលដៅការងារជាប្រាំតំបន់ដោយផ្អែកទៅលើលក្ខណៈភូមិសាស្ត្រ និងសក្តានុពលភាពនៅក្នុងវិស័យស្រូវអង្ករ៖

- **តំបន់១៖** មានខេត្តគោលដៅចំនួន៦ខេត្ត តាកែវ កំពត កំពង់ស្ពឺ កែប ព្រះសីហនុ និងខេត្តកោះកុង
- **តំបន់២៖** មានខេត្តគោលដៅចំនួន៤ខេត្ត កណ្តាល ត្បូងឃ្មុំ ព្រៃវែង និងខេត្តស្វាយរៀង
- **តំបន់៣៖** មានខេត្តគោលដៅចំនួន៤ខេត្ត ក្រចេះ ស្ទឹងត្រែង រតនគីរី និងខេត្តមណ្ឌលគីរី
- **តំបន់៤៖** មានខេត្តគោលដៅចំនួន៥ខេត្ត កំពង់ចាម កំពង់ធំ សៀមរាប ឧត្តរមានជ័យ និងខេត្តព្រះវិហារ
- **តំបន់៥៖** មានខេត្តគោលដៅចំនួន៥ខេត្ត កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងខេត្តប៉ៃលិន

**៣. គោលបំណង៖**

- ការបែងចែកនេះ គឺមានគោលបំណងដើម្បីបង្កើតភាពងាយស្រួលក្នុងការសម្របសម្រួលនូវគ្រប់ដំណើរការនានាក្នុងខ្សែចង្វាក់ស្រូវដែលកើតមានឡើងនៅក្នុងតំបន់ ដើម្បីធានានិរន្តរភាព និងបង្កើនប្រសិទ្ធិភាពការងារ និងឆ្លើយតបនូវសេចក្តីត្រូវការនានារបស់សមាជិកសហព័ន្ធស្រូវអង្ករកម្ពុជាបានទាន់ពេលវេលា។
- លើកកម្ពស់ជម្រុញការផ្សព្វផ្សាយគោលនយោបាល ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព របស់សហព័ន្ធស្រូវអង្ករកម្ពុជាឲ្យបានទូលំទូលាយ ដល់គ្រប់ភាគីពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន។

**៤. រចនាសម្ព័ន្ធថ្នាក់តំបន់៖**

សហព័ន្ធស្រូវអង្ករកម្ពុជា បានបង្កើតការិយាល័យតំណាងនៅក្នុងតំបន់ទាំង៥ ។ ការិយាល័យទាំងនោះមាននៅក្នុងខេត្តតាកែវ ព្រៃវែង ក្រចេះ កំពង់ធំ និងខេត្តកំពង់ឆ្នាំង៖

- ការិយាល័យតំបន់១ មានទីតាំងនៅខេត្តតាកែវ
- ការិយាល័យតំបន់២ មានទីតាំងនៅខេត្តព្រៃវែង
- ការិយាល័យតំបន់៣ មានទីតាំងនៅខេត្តក្រចេះ
- ការិយាល័យតំបន់៤ មានទីតាំងនៅខេត្តកំពង់ធំ
- ការិយាល័យតំបន់៥ មានទីតាំងនៅខេត្តកំពង់ឆ្នាំង

## រចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់តំបន់




3

### ៥. តួនាទីរបស់ក្រុមប្រឹក្សាភិបាលប្រចាំតំបន់នីមួយៗ៖

- ក្រុមប្រឹក្សាតំបន់១ មានសមាជិកក្រុមប្រឹក្សាចំនួន១២នាក់ ដែលនឹងត្រូវជ្រើសរើសជាតំណាងពីខេត្តគោលដៅទាំង៦ខេត្ត៖ តាកែវ កំពត កំពង់ស្ពឺ កែប ព្រះសីហនុ និងកោះកុង ដោយក្នុង១ខេត្តមានតំណាងពីរនាក់។ តំណាងពីរនាក់ មកពីខេត្តនីមួយៗ ត្រូវជ្រើសតាំងដោយការបោះឆ្នោត នៅក្នុងខេត្តសាមី។ ការបោះឆ្នោតធ្វើឡើងដោយមានការចូលរួមពីសហគមន៍កសិករ មន្ទីរជំនាញ វិស័យឯកជន និងតំណាងសង្គមស៊ីវិល។

- ក្រុមប្រឹក្សាតំបន់២ មានសមាជិកក្រុមប្រឹក្សាចំនួន៨នាក់ ដែលនឹងត្រូវជ្រើសរើសជាតំណាងពីខេត្តគោលដៅទាំង៤ខេត្ត៖ កណ្តាល ត្បូងឃ្មុំ ព្រៃវែង និងស្វាយរៀង ដោយក្នុង១ខេត្តមានតំណាងពីរនាក់។ តំណាងពីរនាក់ មកពីខេត្តនីមួយៗ ត្រូវជ្រើសតាំងដោយការបោះឆ្នោត នៅក្នុងខេត្តសាមី។ ការបោះឆ្នោតធ្វើឡើងដោយមានការចូលរួមពីសហគមន៍កសិករ មន្ទីរជំនាញ វិស័យឯកជន និងតំណាងសង្គមស៊ីវិល។

- ក្រុមប្រឹក្សាតំបន់៣ មានសមាជិកក្រុមប្រឹក្សាចំនួន៨នាក់ ដែលនឹងត្រូវជ្រើសរើសជាតំណាងពីខេត្តគោលដៅទាំង៤ខេត្ត៖ ក្រចេះ ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី ដោយក្នុង១ខេត្តមានតំណាងពីរនាក់។ តំណាងពីរនាក់ មកពីខេត្តនីមួយៗ ត្រូវជ្រើសតាំងដោយការបោះឆ្នោត នៅក្នុងខេត្តសាមី។ ការបោះឆ្នោតធ្វើឡើងដោយមានការចូលរួមពីសហគមន៍កសិករ មន្ទីរជំនាញ វិស័យឯកជន និងតំណាងសង្គមស៊ីវិល។

- ក្រុមប្រឹក្សាតំបន់៤ មានសមាជិកក្រុមប្រឹក្សាចំនួន ១០ នាក់ ដែលនឹងត្រូវជ្រើសរើសជាតំណាងពីខេត្តគោលដៅទាំង៥ ខេត្ត៖ កំពង់ចាម កំពង់ធំ សៀមរាប ឧត្តរមានជ័យ និងព្រះវិហារដោយក្នុង១ខេត្តមានតំណាងពីរនាក់។ តំណាងពីរនាក់ មកពីខេត្តនីមួយៗ ត្រូវជ្រើសតាំងដោយការបោះឆ្នោត នៅក្នុងខេត្តសាមី។ ការបោះឆ្នោតធ្វើឡើងដោយមានការចូលរួមពីសហគមន៍កសិករ មន្ទីរជំនាញ វិស័យឯកជន និងតំណាងសង្គមស៊ីវិល។

- ក្រុមប្រឹក្សាតំបន់៥ មានសមាជិកក្រុមប្រឹក្សាចំនួន១០នាក់ ដែលនឹងត្រូវជ្រើសរើសជាតំណាងពីខេត្តគោលដៅទាំង៥ខេត្ត៖ កំពង់ឆ្នាំង

ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិន ដោយក្នុង១ខេត្តមានតំណាងពីរនាក់។ តំណាងពីរនាក់ មកពីខេត្តនីមួយៗ ត្រូវជ្រើសតាំងដោយការបោះឆ្នោត នៅក្នុងខេត្តសាមី។ ការបោះឆ្នោតធ្វើឡើងដោយមានការចូលរួមពីសហគមន៍កសិករ មន្ទីរជំនាញ វិស័យឯកជន និងតំណាងសង្គមស៊ីវិល។




## ៦. តួនាទីភារកិច្ចរបស់បុគ្គលិកចាំតំបន់នីមួយៗ៖

- ជាអ្នកតំណាងរបស់សហព័ន្ធស្រូវអង្ករកម្ពុជា ជាអ្នកសម្របសម្រួល និងធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋានមន្ទីរជំនាញថ្នាក់ខេត្ត ដៃគូរអភិវឌ្ឍន៍ សហគមន៍កសិករ អ្នកផ្គត់ផ្គង់សម្ភារកសិកម្ម អ្នកប្រមូលទិញស្រូវរោងម៉ាស៊ីនកិនស្រូវ អ្នកនាំចេញអង្ករ ។
- សិក្សាអំពីសក្តានុពល ផ្ទៃដីផលិត និងពូជស្រូវ ដែលកសិករប្រើប្រាស់ក្នុងផលិតកម្មស្រូវវស្សា និងប្រាំង ដោយរួមបញ្ចូលទាំងការប្រមូលទិន្នន័យនៃការផលិត និងទីផ្សារស្រូវអង្ករ ។
- សម្របសម្រួល ការជ្រើសរើសសហគមន៍កសិករ និងផ្សារភ្ជាប់រវាង សហគមន៍កសិករ និងម៉ាស៊ីនកិនស្រូវ ព្រមទាំងការរៀបចំឲ្យមានការចុះកិច្ចសន្យាផលិតស្រូវ (contract farming)។
- រៀបចំបណ្តាញ និងផ្សារភ្ជាប់តួអង្គសំខាន់ៗក្នុងខ្សែចង្វាក់ផលិតកម្មស្រូវ សហគមន៍ផលិតគ្រាប់ពូជស្រូវ ក្រុមហ៊ុនផលិតគ្រាប់ពូជស្រូវ សហគមន៍កសិករ អ្នកផ្គត់ផ្គង់សម្ភារកសិកម្ម អ្នកប្រមូលទិញ រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញអង្ករ
- ចុះតាមដានសកម្មភាពនានាក្នុងមូលដ្ឋានដើម្បីតាមដានការវិវត្តន៍ និងភាពប្រឈម
- សម្របសម្រួលដំណើរការកិច្ចប្រជុំកសិករ ទិវាស្រែកសិករ និងព្រឹត្តិការណ៍នានាដែលកើតមានឡើងក្នុងតំបន់ គោលបំណងដើម្បីចែករំលែកព័ត៌មាន និងជម្រុញការផ្សព្វផ្សាយស្រូវអង្ករ ។
- ស្វែងរកការគាំទ្រពីរដ្ឋាភិបាល និង ដៃគូរអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់សហគមន៍កសិករក្នុងការបង្កើនសមត្ថភាពនៃការផលិតស្រូវ និងការអភិវឌ្ឍសមត្ថភាពរបស់សហគមន៍ ។
- តាមដាន និងធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ អំពីស្ថិតិ រោងម៉ាស៊ីនកិនស្រូវ និងសហគមន៍កសិករ
